# ការកំណត់ឲ្យអ៊ីនធឺណិតធ្វើតាម៖ ការកាត់បន្ថយការបញ្ចេញមតិដោយសេរី និងព័ត៌មានអ៊ិនឡាញនៅកម្ពុជា

ការកំណត់ឲ្យអ៊ីនធឺណិតធ្វើតាម៖ ការកាត់បន្ថយការបញ្ចេញមតិដោយសេរី និងព័ត៌មានអ៊ិនឡាញនៅកម្ពុជា



icj
International
Commission
of Jurists

សមាសភាពមានចៅក្រម និងមេធាវីល្បីៗចំនួន៦០នាក់មកពីគ្រប់តំបន់ទាំងអស់នៃពិភពលោក គណៈកម្មការអ្នកច្បាប់អន្តរជាតិ (ICJ) លើកកម្ពស់និងការពារសិទ្ធិមនុស្សតាមរយៈនីតិរដ្ឋ ដោយ ប្រើប្រាស់ជំនាញច្បាប់តែមួយគត់ដើម្បីអភិវឌ្ឍ និងពង្រឹងប្រព័ន្ធយុត្តិធម៌ជាតិ និងអន្តរជាតិ ។

បង្កើតឡើងក្នុង ឆ្នាំ១៩៥២ ហើយធ្វើការយ៉ាងសកម្មនៅលើទ្វីបចំនួន៥ ICJ មានគោលបំណងធានាការអភិវឌ្ឍរីកចម្រើន និងការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃសិទ្ធិមនុស្សអន្តរជាតិ និង ច្បាប់មនុស្សធម៌អន្តរជាតិធានាបាននូវសិទ្ធិស៊ីវិល វប្បធម៌ សេដ្ឋកិច្ច នយោបាយ និងសង្គម ការពារការបែងចែកអំណាច និងធានានូវឯករាជ្យភាពនៃវិជ្ជាជីវៈ តុលាការ និងវិជ្ជាជីវៈច្បាប់ ។

រូបតុក្កតាដែលបានបញ្ចូលក្នុងរបាយការណ៍នេះគូរដោយ Zuna ។

® ការកំណត់ឲ្យអ៊ីនធឺណិតធ្វើតាម ៖ ការកាត់បន្ថយការបញ្ចេញមតិដោយសេរី និងព័ត៌មានអ៊ិនទ្បាញនៅកម្ពុជា

គណៈកម្មការអ្នកច្បាប់អន្តរជាតិ

បោះពុម្ពផ្សាយនៅ ខែវិច្ឆិកា ឆ្នាំ២០២១

គណៈកម្មការអ្នកច្បាប់អន្តរជាតិ (ICJ) អនុញ្ញាតឲ្យផលិតឡើងវិញដោយឥតគិតថ្លៃនូវការ ដកស្រង់ចេញពីការបោះពុម្ពផ្សាយណាមួយរបស់ខ្លួនដោយផ្តល់នូវការទទួលស្គាល់ត្រឹមត្រូវហើយ ច្បាប់ចតចម្លងនៃការបោះពុម្ពផ្សាយដែលយកការដកស្រង់នេះត្រូវបញ្ជូនទៅការិយាល័យកណ្តាលរបស់ពួកគេតាមអាសយដ្ឋានខាងក្រោម៖

គណៈកម្មាធិការអ្នកច្បាប់អន្តរជាតិ
ប្រអប់សំបុត្រលេខ
៨១ Rue des Bains ៣៣
ទីក្រុងហ្សឺណែវ
ប្រទេសស្វីស

# **ការកំណត់ឲ្យអ៊ីនធឺណិតធ្វើតាម៖**
# ការកាត់បន្ថយការបញ្ចេញមតិដោយសេរី និងព័ត៌មានអ៊ីនឡាញនៅកម្ពុជា



របាយការណ៍សង្ខេបនេះត្រូវបានស្រាវជ្រាវ និងព្រាងដោយ Daron Tan ។ Sam Zarifi និង Sanhawan Srisod បានផ្តល់ការពិនិត្យឡើងវិញជាទូទៅ ។ Ian Seiderman បានផ្តល់ការត្រួតពិនិត្យឡើងវិញផ្នែកច្បាប់ និងគោលនយោបាយ ។

ICJ សូមអរគុណ និងទទួលស្គាល់នូវការរួមចំណែករបស់ អង្គការដូចខាងក្រោមដែល ការត្រួតពិនិត្យ ការស្រាវជ្រាវ និង ការវិភាគបានផ្តល់ជូនព័ត៌មានដល់របាយការណ៍នេះ៖

មជ្ឈមណ្ឌលសមាគមមេធាវីអាមេរិកសម្រាប់សិទ្ធិមនុស្ស
អង្គការលើកលែងទោសអន្តរជាតិ
មាត្រា១៩
មជ្ឈមណ្ឌលអាស៊ី
BSR
មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា
គណៈកម្មាធិការការពារអ្នកសារព័ត៌មាន
អង្គការ Freedom House
អង្គការ Front Line Defenders
អង្គការឃ្លាំមើលសិទ្ធិមនុស្ស
លីកាដូ
អង្គការ Reporters Without Borders

និងអ្នកសារព័ត៌មាន អ្នកស្រាវជ្រាវ មេធាវី និងអ្នកការពារសិទ្ធិមនុស្សទាំងអស់ ដែលចូលរួមការវិភាគ និងផ្តល់ព័ត៌មានដល់របាយការណ៍នេះ ។

## សេចក្តីផ្តើម និងសេចក្តីសង្ខេប

នៅខែធ្នូ ឆ្នាំ២០១៩ គណៈកម្មការអ្នកច្បាប់អន្តរជាតិ បានចេញ របាយការណ៍ របស់ខ្លួនមានចំណងជើងថា " *ការកំណត់ឲ្យអ៊ីនធឺណិតធ្វើតាម៖ ការកាត់បន្ថយការបញ្ចេញមតិ ដោយសេរី គំនិតយោបល់ និងព័ត៌មានតាមអ៊ីនធឺណិតនៅអាស៊ីអាគ្នេយ៍* " ដែលបង្ហាញ ពីលំនាំនៃការរំលោភបំពានច្បាប់ដោយរដ្ឋាភិបាលនៅទូទាំងអាស៊ីអាគ្នេយ៍ដើម្បីរឹតត្បិតសេរីភាពក្នុងការបញ្ចេញមតិ គំនិតយោបល់ និងព័ត៌មានរបស់បុគ្គល តាមអ៊ិនឡាញ ។ នៅក្នុងការវិភាគច្បាប់ និងករណីសិក្សាក្នុងតំបន់ របាយការណ៍នេះបានតាមដាននិន្នាការជាច្រើនទសវត្សរ៍នៃរដ្ឋដែលបង្កើត និងអនុវត្តច្បាប់ដែលមិនគោរពសិទ្ធិមនុស្ស ដើម្បីគ្រប់គ្រង និងសម្របសម្រួលខ្លឹមសារអ៊ិនឡាញដោយរំលោភសិទ្ធិមនុស្ស ។

នៅក្នុងរបាយការណ៍នេះ ICJ ផ្តោតលើការវិភាគរបស់ខ្លួនស្តីអំពី **ប្រទេសកម្ពុជា** ។ ព័ត៌មាន និងការវិភាគដែលបានធ្វើបច្ចុប្បន្នភាពបង្ហាញពីរបៀបដែលអាជ្ញាធររដ្ឋបានអនុម័ត និង ព្រាងច្បាប់ថ្មីដែលមិនសមស្របនឹងកាតព្វកិច្ចសិទ្ធិមនុស្សរបស់កម្ពុជា ។ អាជ្ញាធរបានប្រើប្រាស់ច្បាប់ថ្មីទាំងនេះ និង បង្កើនការរំលោភបំពានច្បាប់ មិនអនុលោមតាមសិទ្ធិមនុស្ស ដែលមានស្រាប់ដើម្បីរឹតត្បិតសិទ្ធិមនុស្សក្នុងវិស័យឌីជីថលជាពិសេសក្នុងការឆ្លើយតបទៅនឹងជំងឺរាតត្បាតកូវីដ-១៩ ។ ជាផ្នែកមួយនៃការរឹតត្បិតទាំងនេះ អ្នកប្រើប្រាស់បណ្តាញសង្គម អ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មាន កម្មវិធីប្រព័ន្ធផ្សព្វផ្សាយ ស្ត្រី និង គូប្រជែងនយោបាយដែលយល់ឃើញថាត្រូវបានគេកំណត់គោលដៅ និងដាក់ទណ្ឌកម្ម។

របាយការណ៍នេះត្រួតពិនិត្យ និង វិភាគករណីដែលបានបន្តកើតមាននៅប្រទេសកម្ពុជាចាប់តាំងពីខែធ្នូ ឆ្នាំ២០១៩ ដោយបង្ហាញពីករណីឆ្លុះបញ្ចាំងពីការរំលោភបំពានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ គំនិតយោបល់ និង ព័ត៌មានអ៊ិនឡាញ ជារឿយៗត្រូវបានអមដោយការរំលោភសិទ្ធិផ្សេងទៀត រួមទាំងសិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធី និង សុខភាព ការជំនុំជម្រះក្តីដោយយុត្តិធម៌ និងការមិនរើសអើង ។

លើសពីនេះ និន្នាការលេចធ្លោចំនួនពីរផ្តល់នូវការយកចិត្តទុកដាក់និងការផ្តល់សំណង ៖

1. ចំពេលមានការរាតត្បាតនៃជំងឺកូវីដ១៩ អាជ្ញាធរកម្ពុជាបានអនុម័ត និងតាក់តែងច្បាប់ថ្មី និងបំពានច្បាប់ដែលមានស្រាប់ ដែលមិនស្របតាមច្បាប់ និងស្តង់ដារសិទ្ធិមនុស្ស ដើម្បីរឹតត្បិតបន្ថែមទៀតនូវសេរីភាពនៃការបញ្ចេញមតិនិងការទទួលបានព័ត៌មានតាមអ៊ីនធឺណិត ។ វាត្រូវបានធ្វើឡើងក្រោមហេតុផលយុត្តិកម្មទូលំទូលាយពេកនៃការ

ទប់ស្កាត់ "ព័ត៌មានមិនពិត" ដើម្បីការពារសុខភាពសាធារណៈ ។ ខណៈពេលដែលវិធានការណ៍ពិសេស និង មានប្រសិទ្ធភាពតម្រូវឲ្យមានដើម្បីប្រយុទ្ធប្រឆាំងនឹងវិបត្តិសុខភាពដែលមិនធ្លាប់មានពីមុនមក និង ការពារសិទ្ធិទទួលបានសុខភាព វាច្បាស់ណាស់ថារដ្ឋាភិបាលបានដាក់កំហិតលើការបញ្ចេញមតិ និង ព័ត៌មានតាមប្រពន្ធ័អ៊ីនធឺណិតដែលមិនចាំបាច់ និង មិនសមាមាត្រ ផ្ទុយពីច្បាប់ និង ស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ។

2. មានការព្រួយបារម្ភអំពីវិសាលភាពដែល កម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គម ជាពិសេស Facebook បានចូលរួមជួយឲ្យការគាបសង្កត់លើប្រពន្ធ័អ៊ីនធឺណិតរបស់អាជ្ញាធរកម្ពុជានៅលើកម្មវិធីរបស់ពួកគេ ។ មិនមានតម្លាភាពគ្រប់គ្រាន់ចំពោះវិសាលភាពដែលរដ្ឋាភិបាលកម្ពុជាបានទាមទារឱ្យ Facebook រឹតត្បិតការចូលប្រើខ្លឹមសារនៅលើកម្មវិធីរបស់ខ្លួន និង របៀបឆ្លើយតបទៅនឹងការទាមទារទាំងនេះ ។ ក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយសង្គម ជាពិសេស Facebook មានទំនួលខុសត្រូវ ក្នុងការគោរពសិទ្ធិមនុស្សនៅលើកម្មវិធីរបស់ពួកគេ ដែលរួមបញ្ចូលវិធានការនៃការ ប្រុងប្រយ័ត្នត្រឹមត្រូវនៅពេលធ្វើនិយតកម្មខ្លឹមសារអ៊ីនឡាញ។

## **អនុសាសន៍សំខាន់ៗ**

អនុសាសន៍លម្អិតដែលបានបង្កើតឡើងដើម្បីដោះស្រាយការរំលោភសិទ្ធិមនុស្ស និងការរំលោភបំពានដែលបានរាយបញ្ជីខាងលើបង្ហាញនៅចុងបញ្ចប់នៃរបាយការណ៍នេះ ។ ក្នុងចំណោមនោះ ICJ គូសបញ្ជាក់ដូចខាងក្រោមសម្រាប់ការអនុវត្តជាបន្ទាន់៖

<u>ជូនចំពោះ **សភាកម្ពុជា**</u> ៖

- លុបចោលឬកែប្រែបទប្បញ្ញត្តិផ្លូវច្បាប់ដែលជួយដល់ការដាក់ទោសឬរឹតត្បិតហួសហេតុសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ព័ត៌មាន សមាគម ការចូលរួមនយោបាយ និងសិទ្ធិផ្សេងទៀត ទាំងក្នុងប្រពន្ធ័អ៊ីនធឺណិត ក៏ក្រៅប្រពន្ធ័អ៊ីនធឺណិត ។

<u>ជូនចំពោះស្ថាប័ននីតិប្រតិបត្តិនៃ**រដ្ឋាភិបាលកម្ពុជា**រួមទាំងក្រសួងព័ត៌មានផងដែរ៖</u>

- មន្ត្រីគួរតែបញ្ឈប់ការសម្លុតបំភ័យ ឬ ការធ្វើទុក្ខបុកម្នេញលើបុគ្គលគ្រប់រូបតាមរយៈការរំលោភបំពានច្បាប់ និងបទប្បញ្ញត្តិរដ្ឋបាល ដោយគ្រាន់តែអនុវត្តសិទ្ធិរបស់ពួកគេក្នុងការបញ្ចេញមតិដោយសេរី ព័ត៌មាន និងការជួបប្រជុំដោយ សន្តិវិធីតាម ប្រពន្ធ័អ៊ីនធឺណិត

<u>ជូនចំពោះ**តួអង្គក្នុងវិស័យយុត្តិធម៌**</u> ៖

- ទម្លាក់ចោលការចោទប្រកាន់ទាំងអស់ ចេញដីកាមិនចោទប្រកាន់ និងបដិសេធការចោទប្រកាន់បន្ថែម ជាពិសេសនៅពេលចាប់ផ្តើមនៃបណ្តឹងនេះ ប្រឆាំងនឹងបុគ្គលណាមួយរួមទាំងអ្នកដែលមានឈ្មោះក្នុងរបាយការណ៍នេះដែលប្រឈមមុខនឹងការកាត់ទោសពីបទរំលោភច្បាប់ដែលមិនអនុលោមតាមច្បាប់សិទ្ធិមនុស្ស ឬ ដែលត្រូវបានអនុវត្តក្នុងលក្ខណៈមិនអនុលោមតាមសិទ្ធិមនុស្ស

<u>ជូនចំពោះ **ក្រុមហ៊ុនបច្ចេកវិទ្យាក្នុងវិស័យទំនាក់ទំនង**</u> ៖

- ចាត់វិធានការចាំបាច់ និងស្របច្បាប់ទាំងអស់ ដើម្បីធានាថាកម្មវិធីរបស់ពួកគេ មិនបង្កឱ្យមានការរួមចំណែក ឬធ្វើឱ្យមានភាពស្មុគស្មាញក្នុងការរំលោភសិទ្ធិមនុស្ស រួមទាំងការធានាថា ការរៀបចំភាពជាដៃគូសាជីវកម្មគោរពសិទ្ធិមនុស្ស និងស្វែងរកការកាត់បន្ថយផលប៉ះពាល់សិទ្ធិអវិជ្ជមានណាមួយ

ព័ត៌មាននៅក្នុងរបាយការណ៍នេះគឺត្រឹមត្រូវ ត្រឹមថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១។

# តារាងមាតិកា

**I.** **សារតារ** ....................................................................................8

**II.** **ច្បាប់ និងស្តង់ដារអន្តរជាតិ** ........................................................................ 11

i. សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ គំនិតយោបល់ និងព័ត៌មាន...................... 11

ii. សិទ្ធិឯកជនភាព......................................................................................15

iii. សិទ្ធិសេរីភាពក្នុងការបង្កើតសមាគមការជួបជុំដោយសន្តិវិធី និងការចូលរួម នយោបាយ ..............................................................................................17

iv. សិទ្ធិទទួលបានសុខភាព ...........................................................................19

v. ធុរកិច្ច និងសិទ្ធិមនុស្ស ...............................................................................21

**III.** **ការអនុម័ត និងការតាក់តែងច្បាប់ថ្មីដែលផ្ទុយនឹងសិទ្ធិមនុស្ស**...........................24

i. ច្បាប់ស្តីអំពីការគ្រប់គ្រងប្រទេសជាតិក្នុងគ្រាអាសន្ន ...................................24

ii. អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ ........................................28

iii. ច្បាប់ស្តីពីវិធានការបង្ការប្រឆាំងការរីករាលដាលនៃជំងឺកូវីដ-១៩ និង ជំងឺឆ្លងធ្ងន់ធ្ងរ និងគ្រោះថ្នាក់ផ្សេងទៀត.........................................................31

iv. សេចក្តីព្រាងច្បាប់ស្តីពីសណ្តាប់ធ្នាប់សាធារណៈ .....................................33

v. សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យា...............................................35

**IV.** **ច្បាប់ដែលមានស្រាប់ ដែលមិនអនុលោមតាមច្បាប់ និងស្តង់ដារសិទ្ធិមនុស្ស** .....37

i. មាត្រា ៤២៥ នៃក្រមព្រហ្មទណ្ឌ៖ ព័ត៌មានមិនពិត ........................................37

ii. មាត្រា៤៣៧(ស្ទួន) នៃក្រមព្រហ្មទណ្ឌ៖ ច្បាប់ប្រមាថអង្គព្រះមហាក្សត្រ......39

iii. មាត្រា ៤៥៣ នៃក្រមព្រហ្មទណ្ឌ៖ បទរួមគំនិតក្បត់.......................................40

iv. មាត្រា ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌ៖ បទញុះញង់ឱ្យប្រព្រឹត្ត បទឧក្រិដ្ឋជាអាទិ៍ ឬបង្កឲ្យមានភាពវឹកវរធ្ងន់ធ្ងរ ដល់សន្តិសុខសង្គម ............. 41

v. ប្រកាសអន្តរក្រសួង........................................................................43

vi. ច្បាប់ស្តីអំពីទូរគមនាគន៍ ....................................................................44

**V. ការរិតត្បិតរបស់រដ្ឋលើការបញ្ចេញមតិ និងព័ត៌មានតាមអ៊ីនធឺណិត**....................46

i. ការកាត់ទោស និងផ្តន្ទាទោសអ្នកការពារសិទ្ធិមនុស្ស និងអ្នកប្រើប្រាស់ ប្រព័ន្ធផ្សព្វផ្សាយ សង្គមពីបទ "ញុះញង់"...............................................46

ii. ការគៀបសង្កត់លើអ្នកសារព័ត៌មាន និងកម្មវិធីប្រព័ន្ធផ្សព្វផ្សាយ..................59

iii. ការកំណត់គោលដៅលម្អៀងយេនឌ័រលើស្ត្រីនៅលើប្រព័ន្ធកម្មវិធីផ្សព្វផ្សាយសង្គម.. 64

**VI. ការឆ្លើយតបរបស់រដ្ឋចំពោះ កូវីដ-១៩ និង "ព័ត៌មានមិនពិត" ..........................68**

i. ទណ្ឌកម្មឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម..............70

ii. ការរិតត្បិតលើអ្នកសារព័ត៌មាន និងវេទិកាសារព័ត៌មាន ...............................74

iii. ការកំណត់គោលដៅបុគ្គលដែលមានទំនាក់ទំនងជាមួយ គណបក្សនយោបាយប្រឆាំង ...............................................................78

iv. ការរិតត្បិតការចូលប្រើការបញ្ចេញមតិ និងព័ត៌មានអ៊ិនឡាញដែលមិនពេញចិត្ត ..84

**VII. តួនាទីរបស់ "ក្រុមហ៊ុនបច្ចេកវិទ្យាធំៗ"** .......................................................87

**VIII. អនុសាសន៍** .........................................................................................91

# ការកំណត់ឲ្យអ៊ីនធឺណិតធ្វើតាម ៖

# ការកាត់បន្ថយការបញ្ចេញមតិដោយសេរី និងព័ត៌មានអនឡាញនៅកម្ពុជា

## I. សាវតារ

អាជ្ញាធរកម្ពុជាដូចជាមិត្តភ័ក្តិរបស់ពួកគេនៅក្នុងប្រទេសអាស៊ីអាគ្នេយ៍មួយចំនួនទៀតបានបំពានច្បាប់ជាច្រើនដែលមិនអនុលោមតាមច្បាប់ និងស្តង់ដារសិទ្ធិមនុស្សអន្តរជាតិដើម្បីរិតត្បិតសេរីភាពនៃការបញ្ចេញមតិ និង សិទ្ធិមនុស្សផ្សេងទៀតនៅក្នុងវិស័យឌីជីថល។ បទប្បញ្ញត្តិដែលមិនច្បាស់លាស់ និង ទូលំទូលាយអាចឱ្យច្បាប់ជ្រៀតជ្រែកតាមអំពើចិត្តចំពោះសេរីភាពជាមូលដ្ឋានដែលបណ្តាលឱ្យមានការផាកពិន័យយ៉ាងធ្ងន់ធ្ងរចំពោះការមិនគោរពតាមដែលជារឿយៗក្នុងនាម "សន្តិសុខជាតិ"និង"សណ្តាប់ធ្នាប់សាធារណៈ"។[1]

ប្រឈមមុខនឹងការរាតត្បាតនៃជំងឺកូវីដ-១៩អាជ្ញាធរកម្ពុជាបានរឹតបន្តឹងលើការបញ្ចេញមតិ និង ព័ត៌មាននៅក្នុងលំហអនឡាញ ក្នុងគោលបំណងរួមគ្នាដើម្បីកាត់បន្ថយ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមប្រកបដោយប្រសិទ្ធភាពដែលកាន់តែមានសារៈសំខាន់ នៅក្នុងប្រទេស។ ប្រព័ន្ធផ្សព្វផ្សាយសង្គម ជាពិសេស Facebook បានក្លាយជាប្រភពដ៏សំខាន់នៃព័ត៌មានឯករាជ្យ សម្រាប់ប្រជាជនកម្ពុជា និងជាលំហដ៏សំខាន់សម្រាប់អ្នកការពារសិទ្ធិមនុស្ស និងអង្គការនានា ក្នុងការអនុវត្តការងាររបស់ពួកគេ។[2] តាមរយៈការផ្តល់ "បណ្តាញដ៏សំខាន់នៃការចូលរួមផ្នែកនយោបាយ" ជាពិសេសសម្រាប់ប្រជាជនវ័យក្មេងរបស់ប្រទេសកម្ពុជា ប្រព័ន្ធផ្សព្វផ្សាយសង្គម បានកំណត់នូវអ្វីដែលអ្នកអត្ថាធិប្បាយមួយហៅថា "លទ្ធិប្រជាធិបតេយ្យនៃព័ត៌មាន" នៅក្នុងប្រទេសកម្ពុជា។[3]

---

[1] ICJ *ការកំណត់ឲ្យអ៊ីនធឺណិតធ្វើតាម៖ ការកាត់បន្ថយការបញ្ចេញមតិដោយសេរី មតិយោបល់ និងព័ត៌មាននៅលើអ៊ីនធឺណិតនៅអាស៊ីអាគ្នេយ៍* ខែធ្នូ ឆ្នាំ២០១៩ (របាយការណ៍ ICJ ការកំណត់ឲ្យអ៊ីនធឺណិតធ្វើតាម ឆ្នាំ ២០១៩) មាននៅ៖ https://www.icj.org/southeast-asia-icj-launches-report-on-increasing-restrictions-on-online-speech/

[2] BSR *ការវាយតម្លៃផលប៉ះពាល់សិទ្ធិមនុស្ស៖ ហ្វេសប៊ុកនៅកម្ពុជា* ខែធ្នូ ឆ្នាំ២០១៩ មាននៅ៖ https://about.fb.com/wp-content/uploads/2020/05/BSR-Facebook-Cambodia-HRIA_Executive-Summary2.pdf

[3] Mun Vong 'របៀបគិតអំពីការធ្វើសកម្មភាពផ្សព្វផ្សាយសង្គមនៅក្នុងប្រទេសកម្ពុជា' *កិច្ចសន្ទនាអាស៊ី* ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ មាននៅ ៖ https://theasiadialogue.com/2020/02/13/how-to-think-of-social-media-activism-in-cambodia/

រដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលកាន់អំណាចតាំងពី ឆ្នាំ១៩៨៥ កាន់តែមានការមិនអត់ឱនចំពោះការបញ្ចេញមតិនយោបាយហើយជាពិសេសការរិះគន់ប្រឆាំង។[4] គណបក្សប្រឆាំងដ៏សំខាន់របស់កម្ពុជា គឺគណបក្សសង្គ្រោះជាតិត្រូវបានរំលាយចោលកាលពីខែវិច្ឆិកា ឆ្នាំ២០១៧ ដោយតុលាការកំពូល ជាមួយនឹងសមាជិកជាន់ខ្ពស់ ចំនួន ១១៨រូប ដែលត្រូវបានហាមឃាត់មិនឱ្យចូលរួមនយោបាយរយៈពេល ៥ឆ្នាំ មុនការបោះឆ្នោត ឆ្នាំ២០១៨ ។[5] សកម្មជនសង្គមស៊ីវិល និង អ្នកការពារសិទ្ធិមនុស្សតែងតែត្រូវបានគេបំភិតបំភ័យ និងយាយីចំពោះការតស៊ូមតិ និង ការងាររបស់ពួកគេរួមទាំងតាមរយៈការរំលោភបំពានលើដំណើរការផ្លូវច្បាប់។[6] កម្ពុជាបានជាប់ចំណាត់ថ្នាក់លេខ ១៤៤ ក្នុងចំណោមប្រទេសចំនួន១៨០ ក្នុងសន្ទស្សន៍ សេរីភាពសារព័ត៌មានពិភពលោកឆ្នាំ២០២១[7] ចំពេលមានការព្រួយបារម្ភដែលបាន បង្ហាញអំពី "ការបន្តធ្លាក់ចុះនៃបរិយាកាស ប្រព័ន្ធផ្សព្វផ្សាយនៅក្នុងប្រទេសកម្ពុជា" ដែលបានលុបបំបាត់ការទទួលបាននូវ "លទ្ធិប្រជាធិបតេយ្យ" នៃព័ត៌មានដែលបានបង្ហាញខាងលើ។[8]

ជំងឺរាតត្បាត កូវីដ-១៩ បង្កបញ្ហាប្រឈម និងឧបសគ្គថ្មីសម្រាប់ការអនុវត្តសេរីភាពនៃការបញ្ចេញមតិ និងព័ត៌មាននៅកម្ពុជា។ ខណៈពេលដែលប្រទេសនេះត្រូវបានរួចផុតពីចំនួនខ្ពស់នៃករណី កូវីដ-១៩ ធ្ងន់ធ្ងរក្នុង ឆ្នាំ២០២០ មានករណីកើនឡើងចាប់តាំងពីខែកុម្ភៈឆ្នាំ២០២១។[9] យុទ្ធសាស្ត្រកូវីដ-១៩ របស់រដ្ឋាភិបាលកម្ពុជាបានបញ្ចូលយុទ្ធនាការ

---

[4] សារព័ត៌មាន BBC News 'លោក ហ៊ុន សែន៖ នាយករដ្ឋមន្ត្រីបុរសខ្លាំងរបស់កម្ពុជា' ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៨ មាននៅ៖ https://www.bbc.com/news/world-asia-23257699

[5] សារព័ត៌មាន Reuters ' គណបក្សប្រឆាំងដ៏សំខាន់របស់កម្ពុជាត្រូវបានរំលាយដោយតុលាការកំពូល ' ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ មាននៅ៖ https://www.reuters.com/article/us-cambodia-politics-idUSKBN1DG1BO សូមមើលផងដែរ៖ អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា *ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា* ឯកសារ UN A/HRC/42/60 ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩ កថាខណ្ឌទី៧ និង ៧៤ ។

[6] អង្គការ លើកលែងទោសអន្តរជាតិ 'ប្រទេសកម្ពុជា ឆ្នាំ២០២០' មាននៅ៖ https://www.amnesty.org/en/countries/asia-and-the-pacific/cambodia/report-cambodia/

[7] អ្នកសារព័ត៌មានគ្មានព្រំដែន 'សន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោក ឆ្នាំ២០២១' មាននៅ៖ https://rsf.org/en/ranking .

[8] សារព័ត៌មាន វិទ្យុអាស៊ីសេរី 'អង្គការក្រៅរដ្ឋាភិបាលរាប់សិបជំរុញឱ្យរដ្ឋាភិបាលកម្ពុជា ការពារអ្នកសារព័ត៌មានក្នុងទិវាសេរីភាពសារព័ត៌មានពិភពលោក' ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១ មាននៅ៖ https://www.rfa.org/english/news/cambodia/press-05032021192528.html

[9] ICJ 'កម្ពុជា៖ បញ្ឈប់ការបំបិទមាត់ការអត្ថាធិប្បាយរិះគន់អំពី កូវីដ-១៩' ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១ ('សេចក្តីថ្លែងការណ៍រួមរបស់ ICJ ស្តីពីការអត្ថាធិប្បាយរិះគន់អំពី កូវីដ-១៩') មាននៅ៖ https://www.icj.org/cambodia-stop-silencing-critical-commentary-on-covid-19/

ប្រកបដោយនិរន្តរភាពប្រឆាំងនឹងសេរីភាពនៃការបញ្ចេញមតិ និង ព័ត៌មានក្នុងវិស័យឌីជីថល ក្រោមបដានៃការគ្រប់គ្រងការរីករាលដាលនៃ "ព័ត៌មានមិនពិត" ដែលត្រូវបានចោទប្រកាន់ ដើម្បីការពារសុខភាពសាធារណៈ និងក្រោមហេតុផលនៃការបង្កចលាចលនៅក្នុងសង្គម”។

## II. ស្តង់ដារ និងច្បាប់អន្តរជាតិ

ច្បាប់និងស្តង់ដារសិទ្ធិមនុស្សអន្តរជាតិសង្កត់ធ្ងន់លើការវិភាគនៅក្នុងរបាយការណ៍នេះអំពីការប្រព្រឹត្តរបស់អាជ្ញាធរកម្ពុជាក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការត្រួតពិនិត្យកំណត់ព្រំដែន និងគៀបសង្កត់ខ្លឹមសារអ៊ីនធឺណិតដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិមនុស្សទាំងនៅលើប្រពន្ធ័អ៊ីនធឺណិតនិងក្រៅប្រពន្ធ័អ៊ីនធឺណិត។ ផ្នែកនេះកំណត់អំពីកាតព្វកិច្ចផ្លូវច្បាប់អន្តរជាតិរបស់ប្រទេសកម្ពុជា និងស្តង់ដារច្បាប់អន្តរជាតិសំខាន់ៗ ដែលគ្រប់គ្រងសិទ្ធិសេរីភាព ក្នុងការបញ្ចេញមតិ គំនិតយោបល់ ព័ត៌មាន ឯកជនភាព សុខភាព សមាគម និងការចូលរួម នយោបាយដើម្បីផ្តល់នូវចំណុចចាប់ផ្តើមនៃការវិភាគ។[10]

### *i. សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ គំនិតយោបល់ និងព័ត៌មាន*

មាត្រា១៩នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិស៊ីវិលនិងនយោបាយ(ICCPR)ដែលប្រទេសកម្ពុជាជារដ្ឋភាគីធានាសិទ្ធិរបស់បុគ្គលម្នាក់ៗក្នុងការបញ្ចេញមតិ គំនិតយោបល់ដោយសេរី។ នេះរួមបញ្ចូលទាំងសេរីភាពក្នុងការស្វែងរក ទទួល និងចែកចាយព័ត៌មាន និង គំនិតតាមរយៈប្រព័ន្ធផ្សព្វផ្សាយណាមួយ និងដោយមិនគិតពីព្រំដែន។[11]

គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិដែលជាស្ថាប័នមានភារកិច្ចបកស្រាយ និង ត្រួតពិនិត្យការអនុវត្តដោយរដ្ឋជាភាគីចំពោះ ICCPR បានកំណត់លក្ខណៈ និងវិសាលភាពនៃកាតព្វកិច្ចរបស់រដ្ឋក្នុងការគោរព និងធានានូវសិទ្ធិក្នុងការបញ្ចេញមតិដោយ

---

[10] សូមមើលផងដែរ របាយការណ៍ ICJ ការកំណត់ឲ្យអ៊ីនធឺណិតធ្វើតាម ឆ្នាំ២០១៩ ផ្នែកទី II ។

[11] មាត្រា ១៩ នៃ ICCPR ចែងថា ៖ " *១. មនុស្សគ្រប់រូបមានសិទ្ធិបញ្ចេញមតិដោយគ្មានការជ្រៀតជ្រែក។ ២.មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ សិទ្ធិនេះរួមមានសេរីភាពក្នុងការស្វែងរកទទួលនិងចែកចាយព័ត៌មាននិងគំនិតគ្រប់ប្រភេទដោយមិនគិតពីព្រំដែនទោះដោយផ្ទាល់មាត់ ការសរសេរ ឬ ការបោះពុម្ពក្នុងទម្រង់សិល្បៈ ឬ តាមរយៈប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀតតាមជម្រើសរបស់គាត់។ ៣. ការអនុវត្តសិទ្ធិដែលមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រានេះរួមជាមួយភារកិច្ច និងការទទួលខុសត្រូវពិសេស។ ដូច្នេះវាប្រហែលជាត្រូវស្ថិតនៅក្រោមការរឹតត្បិតមួយចំនួន ប៉ុន្តែទាំងនេះគ្រាន់តែជាការផ្តល់ដោយច្បាប់ហើយ ចាំបាច់ ៖ (ក) សម្រាប់ការគោរពសិទ្ធិ ឬកេរ្តិ៍ឈ្មោះរបស់អ្នកដទៃ (ខ) ដើម្បីការពារសន្តិសុខជាតិឬសណ្តាប់ធ្នាប់សាធារណៈ (ជាសាធារណៈ) ឬសុខភាពសាធារណៈឬសីលធម៌។*"

សេរីនៅក្នុងសេចក្តីពន្យល់ទូទៅ។[12] គណៈកម្មាធិការបានបញ្ជាក់ថាសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និង មតិយោបល់បង្កើតបានជា "មូលដ្ឋានគ្រឹះ" នៃសង្គមសេរីក្នុងការធានា "តម្លាភាព និងគណនេយ្យភាព" ដែលមានសារៈសំខាន់ចំពោះការលើកកម្ពស់ និងការការពារសិទ្ធិផ្សេងទៀតជាច្រើន។[13] រដ្ឋមានកាតព្វកិច្ចការពារ និងលើកកម្ពស់សេរីភាពក្នុងការចូលរួម "ការថ្លែងបញ្ចេញយោបល់ខាងនយោបាយ អត្ថាធិប្បាយអំពីកិច្ចការសាធារណៈ ការពិភាក្សាអំពីសិទ្ធិមនុស្ស សារព័ត៌មាន និង ការបញ្ចេញយោបល់ខាងសាសនា" រួមទាំងតាមរយៈមធ្យោបាយដែលមិនមែនជាពាក្យសំដី និង "របៀបបញ្ចេញមតិតាមប្រព័ន្ធអេឡិចត្រូនិក និងអ៊ីនធឺណិត"។[14] ជាមួយនឹងការរីកសាយ នៅក្នុងសម័យទំនើបនៃ "ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអេឡិចត្រូនិក និងអ៊ីនធឺណិតតាមទូរស័ព្ទចល័ត" រដ្ឋនានាត្រូវចាត់វិធានការ ដើម្បីការពារមុខងារសំខាន់ នៃប្រព័ន្ធផ្សព្វផ្សាយឯករាជ្យក្នុងប្រពន្ធ័អ៊ីនធឺណិត និងក្រៅប្រព័ន្ធអ៊ីនធឺណិតដើម្បីធានា "ការប្រាស្រ័យទាក់ទងព័ត៌មាន និងគំនិតដោយសេរីរវាងប្រជាពលរដ្ឋ បេក្ខជន និង អ្នកតំណាងដែលជាប់ឆ្នោត" និងដើម្បី "ផ្តល់មតិសាធារណៈ" ។[15]

ទាំងសន្ធិសញ្ញា និងស្តង់ដារដែលមិនផ្អែកលើសន្ធិសញ្ញាបានបញ្ជាក់ថាច្បាប់ និងស្តង់ដារអន្តរជាតិអនុវត្តនៅលើប្រពន្ធ័អ៊ីនធឺណិត ។នៅខែកក្កដា ឆ្នាំ២០១៨ ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានអនុម័តដោយការឯកភាពគ្នានូវសេចក្តីសម្រេចមួយដែលបញ្ជាក់ថា "សិទ្ធិដូចគ្នាដែលមនុស្សមាននៅក្រៅប្រពន្ធ័អ៊ីនធឺណិតក៏ត្រូវបានការពារ ដូចក្នុងប្រពន្ធ័អ៊ីនធឺណិតផងដែរជាពិសេស សេរីភាពនៃការបញ្ចេញមតិ ដែលអាចអនុវត្តបានដោយមិនគិតពីព្រំដែន និងតាមរយៈប្រព័ន្ធផ្សព្វផ្សាយណាមួយ ដែលជាជម្រើសរបស់មនុស្សម្នាក់" ។[16]

---

[12] គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប. *សេចក្តីពន្យល់ទូទៅលេខ* ៣៤ ឯកសារ UN. CCPR/C/GC/34 ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១ ( 'ឯកសារ UN CCPR/C/GC/34') កថាខណ្ឌទី២ ៣

[13] *IBID* កថាខណ្ឌទី ២ ៣

[14] *IBID* កថាខណ្ឌទី ១១

[15] *IBID* កថាខណ្ឌទី ១៣ ១៥ ១៦

[16] ក្រុមប្រឹក្សាសិទ្ធិមនុស្ស UN *ការផ្សព្វផ្សាយ ការការពារ និងការអនុវត្តសិទ្ធិមនុស្សនៅលើអ៊ីនធឺណិត* ឯកសារ UN A/HRC/38/L.10/Rev.1 ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៨ ទំព័រទី៣ កិច្ចការនេះត្រូវបានបញ្ជាក់ ស្រដៀងគ្នានៅក្នុងសេចក្តីប្រកាសរួមស្តីពីសេរីភាពបញ្ចេញមតិ និង អ៊ីនធឺណិតចេញដោយអ្នកជំនាញឯករាជ្យចំនួន ៤ មកពី UN និងប្រព័ន្ធក្នុងតំបន់ដែលគ្របដណ្តប់លើបញ្ហាសេរីភាពក្នុងការបញ្ចេញមតិនៅ ខែមិថុនា ឆ្នាំ២០១១៖ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ

*មូលដ្ឋានច្បាប់សម្រាប់រឹតត្បិតឬគាបសង្កត់សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិនិងព័ត៌មាន*

ជាបញ្ហាទូទៅសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិគឺស្ថិតនៅក្រោមការរឹតត្បិតក្រោមលក្ខខណ្ឌតឹងរ៉ឹង និងចង្អៀតដែលមានចែងក្នុងមាត្រា ១៩ (៣) នៃ ICCPR ដែលអនុវត្តចំពោះការបញ្ចេញមតិក្នុងប្រពន្ធ័អ៊ីនធឺណិត និងក្រៅប្រពន្ធ័អ៊ីនធឺណិត ។ មាត្រា១៩(៣)ចែងថា ការរឹតត្បិតណាមួយ ត្រូវតែបំពេញតាមលក្ខខណ្ឌនីត្យានុកុលភាព ភាពស្របច្បាប់ គោលបំណង ភាពចាំបាច់ សមាមាត្រ និងការមិនរើសអើង។

មាត្រា ១៩(៣) បានចែងយ៉ាងជាក់លាក់ថា សិទ្ធិដែលបានការពារក្រោមមាត្រា ១៩ អាចគ្រាន់តែជា "កម្មវត្ថុចំពោះការរឹតត្បិតជាក់លាក់" ដូចមានចែងក្នុងច្បាប់ និងចាំបាច់សម្រាប់គោលបំណងធានាការគោរពសិទ្ធិ ឬកេរ្តិ៍ឈ្មោះរបស់អ្នកដទៃ ឬ ការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាពសាធារណៈ ឬសីលធម៌ ។ ទាំងនេះគឺជាគោលបំណងស្របច្បាប់ល្អិតល្អន់ សម្រាប់ការបញ្ចេញមតិអាចត្រូវបានរឹតត្បិត។

ការរឹតត្បិតដែលត្រូវបាន "ផ្តល់ដោយច្បាប់" បំពេញតាមតម្រូវការដែលវាអនុលោមតាមគោលការណ៍នីត្យានុកូលភាព ។ គោលការណ៍នោះចែងថា ច្បាប់ដែលដាក់កំហិត លើសេរីភាពនៃគំនិត និងការបញ្ចេញមតិដោយ ត្រូវតែបង្កើតឡើងដោយមានភាពជាក់លាក់គ្រប់គ្រាន់ដើម្បី៖ (i) អនុញ្ញាតឲ្យបុគ្គលម្នាក់ៗដឹងច្បាស់ និងកែសម្រួល អាកប្បកិរិយារបស់ពួកគេ (ii) ផ្តល់ការណែនាំដល់អ្នកដែលត្រូវបានចោទប្រកាន់ ពីការអនុវត្តច្បាប់ដើម្បីធានាថាពួកគេអាចកំណត់បានយ៉ាងច្បាស់ថាប្រភេទនៃការបញ្ចេញមតិណាដែលស្ថិតនៅ

---

ស្តីអំពីទស្សនៈ និង ការបញ្ចេញមតិ តំណាងអង្គការសម្រាប់សន្តិសុខ និង សហប្រតិបត្តិការនៅអឺរ៉ុប (OSCE)
ស្តីពីសេរីភាពសារព័ត៌មានប្រព័ន្ធផ្សព្វផ្សាយ អង្គការសហរដ្ឋអាមេរិក (OAS) អ្នករាយការណ៍ពិសេសស្តីពីសេរីភាពនៃគំនិត និង ការបញ្ចេញមតិ និងគណៈកម្មការអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និង ប្រជាជន (ACHPR)
អ្នករាយការណ៍ពិសេសស្តីពីសេរីភាពនៃការបញ្ចេញមតិ និង ការទទួលបានព័ត៌មាន *សេចក្តីប្រកាសរួមស្តីពីសេរីភាពបញ្ចេញមតិ និង អ៊ីនធឺណិត* ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌទី ១ក មាននៅ៖ https: // www.osce.org/fom/78309?download= true.

ក្រោមការរិតត្បិត និងមិនប្រើ "ឆន្ទានុសិទ្ធិគ្មានដែនកំណត់" ក្នុងការរិតត្បិតសេរីភាពក្នុងការបញ្ចេញមតិ និង (iii) មិនបំពានលើច្បាប់ ឬស្តង់ដារសិទ្ធិមនុស្សអន្តរជាតិដទៃទៀត។[17]

ការរិតត្បិតណាមួយត្រូវតែអនុវត្តដោយគ្មានការរើសអើងអាស្រ័យលើស្ថានភាពដែលបានការពារ ។ [18] លើសពីនេះ នៅក្នុងលក្ខខណ្ឌជាក់លាក់នៃមាត្រា១៩(៣)ការរិតត្បិតណាមួយត្រូវតែបំពេញតាមគោលការណ៍នៃភាពចាំបាច់ និងសមាមាត្រ ទោះបីជាការរិតត្បិតត្រូវបានអនុវត្តក្នុងគោលបំណងស្របច្បាប់ក៏ដោយ។គណៈកម្មាធិការសិទ្ធិមនុស្ស UN បានបញ្ជាក់ថាការសាកល្បងភាពចាំបាច់តម្រូវឱ្យកំណត់ថា ដែនកំណត់មិនត្រូវបានកំណត់នៅលើកន្លែងណាដែល ការការពារអាចត្រូវបានផ្តល់ជូនតាមរយៈវិធានការរិតត្បិតតិចតួចបំផុត ខណៈពេលការសាកល្បងនៃភាពសមាមាត្រធានាថាដែនកំណត់គឺសមាមាត្រទៅនឹងមុខងាររបស់ពួកគេ មិនមានវិសាលភាពធំធេងពេក និង "ជាឧបករណ៍ជ្រៀតជ្រែកតិចតួចបំផុតក្នុងចំណោមវិធានការរិតត្បិតទាំងឡាយដែលអាចសម្រេចបាននូវមុខងាររបស់ខ្លួន" ។[19]

កាតព្វកិច្ចរបស់រដ្ឋក្នុងការគោរពការពារ និងបំពេញនូវសិទ្ធិក្នុងការបញ្ចេញមតិ គំនិតយោបល់ និង ព័ត៌មានដោយសេរីតាមប្រពន្ធ័អ៊ីនធឺណិត និងក្រៅប្រពន្ធ័អ៊ីនធឺណិត ត្រូវតែប្រកាន់ខ្ជាប់ដោយ គ្រប់ផ្នែករបស់រដ្ឋ - នីតិប្រតិបត្តិ នីតិប្បញ្ញត្តិ និងតុលាការ និងស្ថាប័នរដ្ឋាភិបាល ឬសាធារណៈដទៃទៀត។[20] កាតព្វកិច្ចនេះបន្ថែមទៀតថាសិទ្ធិទាំងនេះត្រូវបានការពារក្រោមច្បាប់ ក្នុងស្រុក រួមបញ្ចូលទាំងបទបញ្ញត្តិការផ្តល់សំណងនៅពេលសិទ្ធិត្រូវបានរំលោភបំពាន ។[21] ក្នុងន័យនេះ "ការយាយី ការបំភិតបំភ័យ ឬការមាក់ងាយដល់បុគ្គលរួមទាំងការចាប់ខ្លួន ការឃុំខ្លួន ការជំនុំជម្រះ ឬការដាក់ពន្ធនាគារ" ដោយគ្រាន់តែការអនុវត្តសិទ្ធិបញ្ចេញមតិដោយសេរីមានន័យថា ជាការរំលោភបំពាននិង "ទម្រង់ណាមួយនៃការខិតខំដើម្បីបង្ខំឲ្យយល់ព្រមឬមិនយល់ព្រម នៃគំនិតយោបល់ណាមួយ" ត្រូវបានហាមឃាត់ក្រោម ICCPR ។ [22]

---

[17] ឯកសារ UN CCPR/C/GC/34 កថាខណ្ឌទី ២៥ ២៦

[18] *IBID* ., កថាខណ្ឌ័ទី២៦ គណៈកម្មាធិការសិទ្ធិមនុស្ស UN *CCPR សេចក្តីពន្យល់ទូទៅលេខ ១៨៖ មិនមានការរើសអើង ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៨៩* មាននៅ៖ https://www.refworld.org/docid/453883fa8.html

[19] ឯកសារ UN CCPR/C/GC/34 កថាខណ្ឌទី៣៣ ដល់ ៣៥ ។

[20] គណៈកម្មាធិការសិទ្ធិមនុស្ស UN *សេចក្តីពន្យល់ទូទៅលេខ ៣១ [៨០]៖ លក្ខណៈនៃកាតព្វកិច្ចផ្លូវច្បាប់ទូទៅដែលបានដាក់លើភាគីរដ្ឋចំពោះកតិកាសញ្ញា* ឯកសារអង្គការសហប្រជាជាតិ CCPR/C/21/Rev.1 / Add.13 ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៤ ('ឯកសារ UN CCPR/C/21/Rev.1/Add.13') កថាខណ្ឌទី មាននៅ៖ https://www.refworld.org/docid/478b26ae2.html

[21] ឯកសារ UN CCPR/C/GC/34 កថាខណ្ឌទី៨

[22] ឯកសារ UN CCPR/C/GC/34 កថាខណ្ឌទី៩ ១០

## *កាតព្វកិច្ចក្នុងការរឹតបន្តឹងការបញ្ចេញមតិ រួមទាំងការនិយាយញុះញង់ឲ្យមានការរើសអើង អរិភាព ឬអំពើហិង្សា*

មាត្រា ២០ នៃ ICCPR មិនត្រឹមតែអនុញ្ញាតនោះទេ ប៉ុន្តែតម្រូវ ឱ្យរដ្ឋកំណត់ការរិតត្បិតជាក់លាក់លើសេរីភាពនៃការបញ្ចេញមតិផងដែរ ។ មាត្រា ២០ ចែងថា "ការឃោសនាឲ្យមានសង្គ្រាម" និង"ការតស៊ូមតិឲ្យមានការស្អប់ ជាតិ ពូជសាសន៍ ឬសាសនា ដែលបង្កើតជាការញុះញង់ឱ្យមាន ការរើសអើង អរិភាព ឬ អំពើហិង្សា" ត្រូវហាមឃាត់ដោយច្បាប់ ។[23]

គណៈកម្មាធិការសិទ្ធិមនុស្ស UN បានបញ្ជាក់យ៉ាងច្បាស់ថាមាត្រា ១៩ និង ២០ នៃ ICCPR "មានភាពស៊ីគ្នា និង បំពេញបន្ថែមគ្នាទៅវិញទៅមក" ហើយដែនកំណត់ដែលមានចែងក្នុងមាត្រា ២០ ត្រូវតែគោរពតាម និងមានភាពត្រឹមត្រូវ "អនុលោមតាមយ៉ាងតឹងរឹង" ជាមួយ មាត្រា១៩។[24] អតីតអ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពី សេរីភាពនៃការបញ្ចេញមតិបានសង្កត់ធ្ងន់ថា ច្បាប់ក្នុងស្រុកដើម្បីប្រយុទ្ធប្រឆាំងនឹងការនិយាយស្អប់ខ្ពើម ឬការញុះញង់ឱ្យមានអំពើហិង្សាតាមប្រពន្ធ័អ៊ីនធឺណិត និងក្រៅប្រពន្ធ័អ៊ីនធឺណិតត្រូវតែប្រកាន់ខ្ជាប់នូវ "តម្រូវការនីត្យានុកូលភាព ភាពចាំបាច់ សមាមាត្រ និងភាពស្របច្បាប់" និង ធានា "ការចូលរួមជាសាធារណៈដ៏រឹងមាំ" ដោយទទួលយកការណែនាំពីមាត្រា ១៩ និង ២០ នៃICCPR អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់ ការរើសអើងជាតិសាសន៍ (ICERD) និង ផែនការសកម្មភាព Rabat ស្តីពីការហាមឃាត់ ការតស៊ូមតិនាំឲ្យមានការស្អប់ ជាតិ ពូជសាសន៍ ឬសាសនាដែលបង្កើតជាការញុះញង់ ឱ្យមានការរើសអើង អរិភាព ឬ អំពើហិង្សា។[25]

### *ii. សិទ្ធិឯកជនភាព*

---

[23] មាត្រា ២០ ចែងថា៖ "១. ការឃោសនារកសង្គ្រាមណាមួយត្រូវហាមឃាត់ដោយច្បាប់។ ២. ការតស៊ូមតិណាមួយនាំឲ្យមានការស្អប់ជាតិ ពូជសាសន៍ ឬសាសនាដែលបង្កការញុះញង់ឱ្យមានការរើសអើងជាតិសាសន៍ អរិភាព ឬអំពើហិង្សាត្រូវហាមឃាត់ដោយច្បាប់" ។

[24] ឯកសារ UN CCPR/C/GC/34 កថាខណ្ឌទី៥០ ៥២

[25] *របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការលើកកម្ពស់ និងការការពារសេរីភាពនៃគំនិត និងការបញ្ចេញមតិ* ឯកសារ UN A/74/486 ថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៩ ('ឯកសារ UN A/74/486') កថាខណ្ឌ័ទី៥៧(ខ) ក្រុមប្រឹក្សាសិទ្ធិមនុស្ស *របាយការណ៍ប្រចាំឆ្នាំរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស៖ ឧបសម្ពន្ធ័* ឯកសារអង្គការ UN A/HRC/22/17/Add.4 ('ផែនការសកម្មភាព Rabat') ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ មាននៅ៖ https://www.ohchr.org/Documents/Issues/Opinion/SeminarRabat/Rabat_draft_outcome.pdf

មាត្រា ១៧ នៃ ICCPR ការពារសិទ្ធិរបស់បុគ្គលម្នាក់ៗប្រឆាំងនឹងការជ្រៀតជ្រែក តាមអំពើចិត្ត ឬដោយខុសច្បាប់ចំពោះឯកជនភាពរបស់ពួកគេ ។[26] មហាសន្និបាត UN បានបញ្ជាក់ថា កិច្ចការនេះ និងការអនុវត្តដោយសេរី និងឯករាជ្យនូវសិទ្ធិ ក្នុងការបញ្ចេញមតិ និង គំនិតយោបល់ គឺអាស្រ័យគ្នាទៅវិញទៅមក ។[27] នៅក្នុងសេចក្តីសម្រេច ឆ្នាំ២០១៣ របស់ខ្លួនស្តីពីសិទ្ធិមនុស្សក្នុងយុគសម័យឌីជីថលមហាសន្និបាត UN ក៏បានសង្កត់ធ្ងន់ថា ការរីកចម្រើនផ្នែកបច្ចេកវិទ្យាបានពង្រីកសមត្ថភាពរបស់រដ្ឋ និង តួអង្គមិនមែនរដ្ឋ រួមទាំងសហគ្រាសធុរកិច្ចក្នុងការប្រមូលផ្តុំការស៊ើបអង្កេត និង ចាប់ទិន្នន័យតាមវិធីដែលរំលោភលើសិទ្ធិឯកជនភាព និងបានបញ្ជាក់ថា រដ្ឋមានកាតព្វកិច្ចក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិដើម្បីការពារការរំលោភបំពានទាំងនេះនៅក្នុងបរិបទនៃទំនាក់ទំនងឌីជីថល។[28]

ដូចដែលក្រុមប្រឹក្សាសិទ្ធិមនុស្ស UN និងការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស UN បានបញ្ជាក់ថាគោលការណ៍នៃនីត្យានុកូលភាព ភាពស្របច្បាប់ ភាពចាំបាច់ និង សមាមាត្រត្រូវបានអនុវត្តចំពោះសិទ្ធិឯកជនភាពក្នុងលក្ខណៈដូចគ្នាទៅនឹងសេរីភាពនៃការបញ្ចេញមតិ និងសេរីភាពមូលដ្ឋានផ្សេងទៀត។[29] គោលការណ៍ទាំងនេះគឺទាក់ទងគ្នា និងអាចអនុវត្តបានទាំងក្រៅប្រពន្ធ័អ៊ីនធឺណិតនិងក្នុងប្រពន្ធ័អ៊ីនធឺណិតយោងទៅតាមគោលការណ៍នៃភាពចាំបាច់ និងសមាមាត្រ ជាពិសេសទាក់ទងនឹងបច្ចេកវិទ្យា និងបច្ចេកទេស ឃ្លាំមើលទំនាក់ទំនង។[30]

---

[26] មាត្រា ១៧ នៃ ICCPR ចែងថា "១.គ្មាននរណាម្នាក់ត្រូវទទួលរងនូវការជ្រៀតជ្រែកដោយបំពាន ឬការជ្រៀតជ្រែកដោយខុសច្បាប់ចំពោះឯកជនភាព គ្រួសារ ផ្ទះ ឬការឆ្លើយឆ្លងរបស់គាត់ ឬការវាយប្រហារដោយខុសច្បាប់លើកិត្តិយស និងកេរ្តិ៍ឈ្មោះរបស់គាត់ឡើយ។ ២. មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការការពារច្បាប់ប្រឆាំងនឹងការជ្រៀតជ្រែកឬការវាយប្រហារបែបនេះ។

[27] មហាសន្និបាត អ.ស.ប. *សិទ្ធិឯកជនភាពក្នុងយុគសម័យឌីជីថល* ឯកសារ UN A/RES/68/167 ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៣ មាននៅ៖ https://undocs.org/A/RES/68/167

[28] *Ibid*

[29] *របាយការណ៍របស់ឧត្តមស្នងការសិទ្ធិមនុស្សស្តីពីសិទ្ធិឯកជនភាពក្នុងយុគសម័យឌីជីថល* ឯកសារ UN A/HRC/39/29 ថ្ងៃទី៣ សីហា ឆ្នាំ២០១៨ កថាខណ្ឌទី១០ ក្រុមប្រឹក្សាសិទ្ធិមនុស្ស *សិទ្ធិឯកជនភាពក្នុងយុគសម័យឌីជីថល* ឯកសារ UN A/HRC/RES/34/7 ថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៧ កថាខណ្ឌទី២ ។

[30] *គោលការណ៍អន្តរជាតិដែលចាំបាច់និងសមាមាត្រលើការអនុវត្តសិទ្ធិមនុស្សក្នុងការឃ្លាំមើលការទំនាក់ទំនង ខែឧសភាឆ្នាំ ២០១៤ មាននៅ៖* https://necessaryandproportionate.org/principles ។ ICJ ក៏ជាហត្ថលេខីនៃគោលការណ៍ទាំងនេះដែរ។ នៅក្នុងរបាយការណ៍ឆ្នាំ ២០១៤ របស់ខ្លួនដែលបន្តពីសេចក្តីសម្រេចលេខ ៦៨/១៦៧ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សបានសំដៅលើគោលការណ៍ចាំបាច់ និងសមាមាត្រដោយបញ្ជាក់ជាថ្មីថា " គោលការណ៍រួមនៃនីត្យានុកូលភាព ភាពចាំបាច់ និងសមាមាត្រ" អនុវត្តចំពោះការកំណត់នៅលើ សិទ្ធិឯកជនភាពអ៊ិនឡាញ ។ សូមមើល

## *iii. សិទ្ធិសេរីភាពក្នុងការបង្កើតសមាគមការជួបជុំដោយសន្តិវិធី និង ការចូលរួមនយោបាយ*

សិទ្ធិសេរីភាពក្នុងការបង្កើតសមាគម ការជួបជុំដោយសន្តិវិធី និងការចូលរួមនយោបាយ ត្រូវបាន ការពាររៀងៗខ្លួនតាមមាត្រា ២១ ២២ និង ២៥ នៃ ICCPR ។[31] សិទ្ធិទាំងនេះ ក៏ត្រូវបានអនុវត្ត ជាញឹកញាប់តាមប្រពន្ធ័អ៊ីនធឺណិតផងដែរ ។ បទប្បញ្ញត្តិរៀងៗខ្លួនរបស់ ខ្លួនក្រោម ICCPR ផ្តល់នូវលក្ខខណ្ឌដូចគ្នានឹងមាត្រា ១៩ ថាការរិតត្បិតដែលត្រូវដាក់ លើសិទ្ធិទាំងនេះ ត្រូវតែគោរពតាមគោលការណ៍នីត្យានុកូលភាព ភាពស្របច្បាប់ ភាព ចាំបាច់ និង សមាមាត្រ ។ គោលការណ៍ មិនរើសអើង ក៏អនុវត្តចំពោះសិទ្ធិទាំងនេះដែរ ។

សិទ្ធិក្នុងការបញ្ចេញមតិដោយសេរី គំនិតយោបល់ ព័ត៌មាន និងឯកជនភាពជាញឹកញាប់ ពាក់ពន្ធ័ស្របគ្នានូវសិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធី សេរីភាពក្នុងការបង្កើតសមាគម និង ការចូលរួមនយោបាយនៅក្នុងបរិបទនៃការទំនាក់ទំនងតាមប្រពន្ធ័អ៊ិនទ្បាញ។ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប បានទទួលស្គាល់ថាការរិតត្បិតបច្ចេកវិទ្យាទំនាក់ ទំនង អាចរារាំងសិទ្ធិក្នុងការជួបប្រជុំ នៅពេលពួកគេ "ផ្តល់ឱកាសក្នុងការជួបជុំគ្នាតាម ប្រពន្ធ័អ៊ិនទ្បាញ ទាំងស្រុង ឬ មួយផ្នែកក្តី ហើយជារឿយៗដើរតួយ៉ាងសំខាន់ក្នុង ការរៀបចំ

*របាយការណ៍របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស* ឯកសារ UN A/HRC/27/37 ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤ កថាខណ្ឌទី២៣ ។

[31] មាត្រា ២១ នៃ ICCPR ចែងថា៖ "សិទ្ធិនៃការជួបជុំដោយសន្តិវិធីត្រូវបានទទួលស្គាល់។ គ្មានការរិតត្បិតណាមួយអាចត្រូវបាន អនុវត្តលើការប្រើប្រាស់សិទ្ធិនេះក្រៅពីការដាក់ឱ្យស្របតាមច្បាប់ និងដែលចាំបាច់នៅក្នុងសង្គម ប្រជាធិបតេយ្យដើម្បីផលប្រយោជន៍ សន្តិសុខជាតិ ឬ សុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ(*គោលនយោបាយសាធារណៈ*) ការការពារសុខភាពសាធារណៈ ឬ សីលធម៌ ឬ ការការពារសិទ្ធិ និង សេរីភាពរបស់អ្នកដទៃ" ។ មាត្រា ២២ ចែងថា៖ "១. មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបង្កើត សមាគមជាមួយអ្នកដទៃរួមទាំងសិទ្ធិបង្កើតសហជីពដើម្បីការពារផលប្រយោជន៍របស់គាត់។ ២. គ្មានការរិតត្បិតណាមួយ អាចត្រូវបាន អនុវត្តលើការប្រើប្រាស់សិទ្ធិនេះក្រៅពីអ្វីដែលមានចែងក្នុងច្បាប់ និងដែលចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ ដើម្បីផលប្រយោជន៍ សន្តិសុខជាតិ ឬ សុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ(*គោលនយោបាយសាធារណៈ*) ការការពារសុខភាពសាធារណៈ ឬ សីលធម៌ ឬការការពារសិទ្ធិ និង សេរីភាពរបស់អ្នកដទៃ។ មាត្រានេះ មិនត្រូវរារាំងការដាក់កំហិតដោយស្របច្បាប់ទៅលើសមាជិក កងកម្លាំងប្រដាប់អាវុធ និងប៉ូលិសក្នុងការអនុវត្តសិទ្ធិនេះឡើយ" ។ មាត្រា ២៥ ចែងថា៖ " ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិ និងឱកាស គ្មាន... ការរិតត្បិតដោយគ្មានហេតុផល៖ (ក) ចូលរួមក្នុងកិច្ចការសាធារណៈដោយផ្ទាល់ឬតាមរយៈអ្នកតំណាង ដែលបានជ្រើសរើសដោយសេរី" ។

ការចូលរួម និងការត្រួតពិនិត្យការជួបជុំគ្នាជាក់ស្តែង”។[32] ដូច្នេះរដ្ឋមិនត្រូវ "បិទ ឬ រារាំងការតភ្ជាប់អ៊ីនធឺណិតទាក់ទងនឹងការជួបប្រជុំដោយសន្តិវិធី” ឬ អនុវត្ត "បច្ចេកវិទ្យាការជ្រៀតជ្រែកជាក់លាក់តាមភូមិសាស្ត្រដែលត្រូវបានកំណត់” ដើម្បីរិតត្បិត ការតភ្ជាប់ ឬ ការចូលមើលខ្លឹមសារ។[33] រដ្ឋគួរតែធានាផងដែរថា "សកម្មភាពរបស់ក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិត និង អន្តរការីមិនរិតត្បិតការជួបប្រជុំ ឬ ឯកជនភាពរបស់អ្នកចូលរួម ក្នុងការប្រជុំឡើយ”។[34] គណៈកម្មាធិការក៏បានកត់សម្គាល់ផងដែរថា ទោះបីជាបច្ចេកវិទ្យាឃ្លាំមើល" អាចត្រូវបានប្រើដើម្បីរកការគំរាមកំហែងនៃអំពើហិង្សា ធ្វើដូច្នេះដើម្បី ការពារសាធារណជន” ក៏ដោយ ក៏ការរិតត្បិតទាំងនោះអាច "រំលោភលើសិទ្ធិឯកជនភាព និងសិទ្ធិផ្សេងទៀតរបស់ អ្នកចូលរួម និង អ្នកទស្សនាហើយមានឥទ្ធិពលគួរឱ្យភ័យខ្លាច”។ [35]

## *អ្នកការពារសិទ្ធិមនុស្ស*

សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីអ្នកការពារសិទ្ធិមនុស្សផ្តល់ការការពារជាពិសេសសម្រាប់អ្នកការពារសិទ្ធិមនុស្ស។ សេចក្តីប្រកាសនេះសង្កត់ធ្ងន់លើ "ការទទួលខុសត្រូវចម្បង" របស់រដ្ឋក្នុងការ "ការពារលើកកម្ពស់ និងអនុវត្តសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានទាំងអស់ តាមរយៈការអនុម័តនូវជំហានបែបនេះតាមការចាំបាច់ដើម្បីបង្កើតលក្ខខណ្ឌ ចាំបាច់ទាំងអស់ក្នុងវិស័យសង្គម សេដ្ឋកិច្ច នយោបាយ និងវិស័យផ្សេងៗទៀត ក៏ដូចជាការធានាផ្នែកច្បាប់ដែលតម្រូវឲ្យមានដើម្បីធានាថា មនុស្សទាំងអស់ដែលស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួន បុគ្គលម្នាក់ៗ និងក្នុងទំនាក់ទំនងជាមួយអ្នកដទៃ អាចទទួលបានសិទ្ធិ និងសេរីភាពទាំងអស់នោះក្នុងការអនុវត្ត”។[36]

---

[32] គណៈកម្មាធិការសិទ្ធិមនុស្ស UN សេចក្តីពន្យល់ទូទៅលេខ *៣៧ លើមាត្រា ២១៖ សិទ្ធិជួបជុំដោយសន្តិវិធី* ឯកសារ UN CCPR/C/GC/37 ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២០ ('CCPR/C/GC/37') កថាខណ្ឌទី១០ មាននៅ៖ https://tbinternet.ohchr.org/_layouts/15/treatybodyexternal/TBSearch.aspx?Lang=en&TreatyID=8&DocTypeID=11

[33] ឯកសារ UN CCPR/C/GC/37 កថាខណ្ឌទី៣៤

[34] *Ibid*

[35] *IBID* ., កថាខណ្ឌទី១០

[36] *សេចក្តីប្រកាសស្តីពីសិទ្ធិ និងទំនួលខុសត្រូវរបស់បុគ្គល ក្រុម និងអង្គការសង្គម ដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាសកល សេរីភាពមូលដ្ឋាន* ឯកសារ UN A/RES/53/144 ខែធ្នូ ឆ្នាំ១៩៩៨ ('សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីអ្នកការពារសិទ្ធិមនុស្ស') មាត្រា ២ មាននៅ៖ https://www.ohchr.org/Documents/Issues/Defenders/Declaration/declaration.pdf

វាបញ្ជាក់បន្ថែមថា រដ្ឋត្រូវតែដាក់ចេញនូវវិធានការច្បាប់ រដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាការការពារសិទ្ធិរបស់ពួកគេក្នុងការបង្កើតសមាគម ការជួបប្រជុំ និង ការចូលរួមផ្នែកនយោបាយ រួមជាមួយនឹងការបញ្ចេញមតិ និងសិទ្ធិឯកជនភាពរបស់ពួកគេ ទាំងក្រៅប្រពន្ធ័អ៊ីនធឺណិត និងក្នុងប្រពន្ធ័អ៊ីនធឺណិត។[37]

### *iv. សិទ្ធិទទួលបានសុខភាព*

ការបញ្ចេញមតិ និងព័ត៌មានអ៊ីនឡាញ មិនត្រឹមតែមានទំនាក់ទំនងជាមួយការអនុវត្តសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដទៃទៀតប៉ុណ្ណោះទេ ថែមទាំងការលើកកម្ពស់ និងការពារសិទ្ធិសេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌ទៀតផង។ កិច្ចការនេះរួមបញ្ចូលជាពិសេសសិទ្ធិទទួលបានសុខភាព។ នៅទីបញ្ចប់ ប្រទេសកម្ពុជា មានកាតព្វកិច្ចគោរព ការពារ និងបំពេញនូវសិទ្ធិទទួលបាន "នូវស្តង់ដារសុខភាព រាងកាយ និងផ្លូវចិត្តខ្ពស់បំផុត" ដែលជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ICESCR)។ [38]

នៅក្នុងបរិបទនៃជំងឺរាតត្បាតកូវីដ-១៩ មាត្រា ១២(១) និង ១២(២) (គ) ដល់ (ឃ) នៃ ICESCRតម្រូវឱ្យប្រទេសកម្ពុជាចាត់វិធានការដើម្បីសម្រេចបាន "ការការពារ ការព្យាបាល និងការគ្រប់គ្រង ការរីករាលដាលដែលមានដោយកន្លែង ជំងឺដែលបណ្តាលមកពីការងារ និង ជំងឺដទៃទៀត" ក៏ដូចជា "ការបង្កើតលក្ខខណ្ឌដែលនឹងធានាដល់សេវាកម្មវេជ្ជសាស្ត្រ និង ការយកចិត្តទុកដាក់ ខាងវេជ្ជសាស្ត្រក្នុងករណីមានជំងឺ" ។ [39]

គណៈកម្មាធិការអង្គការសហប្រជាជាតិ ស្តីអំពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ (CESCR) ដែលជាស្ថាប័នត្រួតពិនិត្យសម្រាប់ ICESCR បានបញ្ជាក់យ៉ាងច្បាស់ថាសិទ្ធិទទួលបានសុខភាពរួមមានកាតព្វកិច្ចធានាលទ្ធភាពទទួលបាន អាគារព្យាបាល ទំនិញ និងសេវាកម្មដល់បុគ្គលគ្រប់រូបដោយមិនរើសអើងរួមទាំងលទ្ធភាពទទួលបានព័ត៌មានជា

---

[37] *Ibid*

[38] មាត្រា ១២(១) ICESCR

[39] មាត្រា ១២(២) ចែងថា៖ "ជំហានដែលត្រូវអនុវត្តដោយរដ្ឋភាគីនៃកតិកាសញ្ញាបច្ចុប្បន្ន ដើម្បីសម្រេចបាននូវការសម្រេចពេញលេញនៃសិទ្ធិនេះ ត្រូវរួមបញ្ចូលនូវអ្វីដែលចាំបាច់សម្រាប់៖ ... (គ) ការការពារ ការព្យាបាល និងការគ្រប់គ្រងជំងឺរាតត្បាត ជំងឺឆ្លង ជំងឺកើតចេញពីការងារ និងជំងឺផ្សេងៗទៀត (ឃ) ការបង្កើតលក្ខខណ្ឌដែលនឹងធានាដល់សេវាវេជ្ជសាស្ត្រ និងការយកចិត្តទុកដាក់ផ្នែកវេជ្ជសាស្ត្រទាំងអស់ក្នុងករណីមានជម្ងឺ។

"សមាសធាតុសំខាន់នៃសិទ្ធិទទួលបានសុខភាព"។[40] នេះរួមបញ្ចូល "សិទ្ធិក្នុងការស្វែងរក ទទួល និងចែកចាយព័ត៌មាន និងគំនិតទាក់ទងនឹងបញ្ហាសុខភាព" ដោយមិនរំលោភលើសិទ្ធិក្នុងការរក្សាឯកជនភាព និងការសម្ងាត់នៃទិន្នន័យទាក់ទងនឹងសុខភាព ។[41]

ការគោរព និងការការពារសិទ្ធិសុខភាពជាកាតព្វកិច្ចប្រទេសកម្ពុជាក្នុងនាមជារដ្ឋភាគីដើម្បីធានាការមិនរើសអើង និងការទទួលបានព័ត៌មានទាក់ទងនឹងសុខភាពជាសកលអនុញ្ញាតឱ្យមនុស្ស ស្វែងរក ទទួល និងចែករំលែកគំនិតទាក់ទងនឹងបញ្ហាសុខភាព ជៀសវាងពី "ការត្រួតពិនិត្យ ការបិទបាំង ឬការបង្ហាញខុសដោយចេតនា" នូវព័ត៌មានទាក់ទងនឹងសុខភាព និងចៀសវាង ការរាំងស្ទះដល់ការចូលរួមរបស់ប្រជាជន ក្នុងបញ្ហាទាក់ទងនឹងសុខភាព។[42]

កាតព្វកិច្ចទាំងនេះមានលក្ខណៈជាក់លាក់មួយចំនួនចំពេលមានភាពអាសន្នផ្នែកសុខភាពសាធារណៈ។ CESCR បានចង្អុលបង្ហាញថាព័ត៌មានទាក់ទងនឹងកូវីដ-១៩ ត្រូវតែផ្តល់ជូនដោយអាជ្ញាធររដ្ឋ "ជាទៀងទាត់តាមទម្រង់ដែលអាចចូលទៅមើលបាន និងជាភាសាមូលដ្ឋាន និងភាសាដើមទាំងអស់" ជាវិធានការដើម្បីប្រយុទ្ធប្រឆាំងនឹងព័ត៌មានមិនពិត អំពីមេរោគនិង "ដើម្បីកាត់បន្ថយហានិភ័យនៃការចម្លងមេរោគ"។[43] រដ្ឋក៏មានកាតព្វកិច្ចធានានូវសេវាកម្មអ៊ីនធឺណិតដែលមានតំលៃសមរម្យ បច្ចេកវិទ្យាចាំបាច់សម្រាប់ការផ្សព្វផ្សាយ

---

[40] គណៈកម្មាធិអង្គការសហប្រជាជាតិស្តីអំពីសិទ្ធិ សេដ្ឋកិច្ច សង្គម និងវប្បធម៌ *សេចក្តីពន្យល់ទូទៅរបស់ CESCR លេខ ១៤៖ សិទ្ធិទទួលបានស្តង់ដារសុខភាពខ្ពស់បំផុត (មាត្រា ១២)* ឯកសារ UN លេខ E/C.12/2000/4 ថ្ងៃទី១១ ខែសីហា ឆ្នាំ២០០០ ('ឯកសារ UN E/C.12/2000/4') កថាខណ្ឌទី៣ ១១ ២១ - ២៣ ៣៤ - ៣៧ ៤៤ ។

[41] *IBID* កថាខណ្ឌ័ទី១២ (ខ)

[42] *IBID* កថាខណ្ឌទី៣ ១២ (ខ) ៣៤ ៣៥ ៤៤ ៥០។ សូមមើលផលដែរ ICJ *ការរស់នៅដូចមនុស្សស្លាប់យឺតៗៈតម្រូវការសិទ្ធិទទួលបានការឆ្លើយតបចំពោះជំងឺកូវីដ-១៩ ខែកញ្ញា ឆ្នាំ២០២០* ('របាយការណ៍សកល ICJ ឆ្នាំ២០២០ អំពី កូវីដ ១៩') ទំព័រទី២៤ ដល់២៥ មាននៅ៖ https://www.icj.org/wp-content/uploads/2020/09/Universal-Global-Health-COVID-19-Publications-Reports-Thematic-Reports-2020-ENG.pdf.

[43] គណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ *សេចក្តីថ្លែងការណ៍ស្តីពីជំងឺរាតត្បាត (COVID-19) ជំងឺរាតត្បាត និងសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌* ឯកសារ UN លេខ E/C.12/2020/1 ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ កថាខណ្ឌ ទី ១៨ មាននៅ៖ https://undocs.org/E/C.12/2020/1 សូមមើលផងដែររបាយការណ៍សកល ICJ ឆ្នាំ២០២០ អំពី កូវីដ-១៩ ទំព័រទី ១០៤ ដល់ ១០៥ ។

ព័ត៌មានប្រកបដោយប្រសិទ្ធភាព និង ចៀសវាងការបិទឬកំណត់ព្រំដែន ការចូលប្រើប្រាស់អ៊ីនធឺណិត។ [44]

អតីតអ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិបញ្ចេញមតិបានគូសបញ្ជាក់ថានៅក្នុងបរិបទនៃជំងឺកូវីដ-១៩ រដ្ឋត្រូវ៖ (i) ធានាការទទួលបានព័ត៌មាន ដែលកាន់កាប់ដោយអាជ្ញាធរពាក់ព័ន្ធនឹងវិបត្តិនេះរួមទាំងកាតព្វកិច្ច "ផ្តល់ព័ត៌មានដែលត្រឹមត្រូវ តាមដែលអាចធ្វើទៅបាន" និង "ការណែនាំច្បាស់លាស់ហើយស្មោះត្រង់" ដើម្បីអនុញ្ញាតឱ្យរដ្ឋមិនត្រឹមតែអាចយល់ពីកង្វល់របស់សាធារណជនប៉ុណ្ណោះទេ ថែមទាំងឲ្យបុគ្គលម្នាក់ៗដឹងច្បាស់ពីវិធីគ្រប់គ្រងការភ័យខ្លាចរបស់ពួកគេផងដែរ។ (ii) រក្សាការចូលប្រើអ៊ីនធឺណិតសម្រាប់ទាំងអស់គ្នា (iii) លើកកម្ពស់ និងការពារប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ដើម្បីឱ្យសាធារណជនអាចប្រើប្រាស់សិទ្ធិទទួលបានព័ត៌មានគ្រប់គ្រាន់ដើម្បី"ចាត់វិធានការសមស្របក្នុងការការពារខ្លួន និងសហគមន៍របស់ពួកគេ" (iv) គ្រប់គ្រងការរីករាលដាលនៃព័ត៌មានមិនពិតលើមេរោគតាមប្រពន្ធ័អ៊ីនធឺណិតដោយមិនរំលោភលើសិទ្ធិដែលត្រូវបានការពារក្រោមមាត្រា១៩ នៃ ICCPR និង (v) ធានាឱ្យមានការឃ្លាំមើល សុខភាពដើម្បីគ្រប់គ្រងវិបត្តិ ការពារសិទ្ធិឯកជនភាព។[45]

## *v. ធុរកិច្ច និងសិទ្ធិមនុស្ស*

*កាតព្វកិច្ចការពារសិទ្ធិមនុស្សដូចជាសេរីភាពនៃការបញ្ចេញមតិ និងព័ត៌មាន និងសិទ្ធិផ្សេងទៀតដែលបានលើកឡើងខាងលើរួមមានកាតព្វកិច្ចការពារពីការប្រព្រឹត្តរបស់អង្គភាពឯកជនរួមទាំងធុរកិច្ចដែលធ្វើឱ្យប៉ះពាល់ដល់ការប្រើប្រាស់សិទ្ធិមនុស្ស។* [46]
នេះចាំបាច់តម្រូវឱ្យមានកាតព្វកិច្ចអនុវត្តកម្រិតជាក់លាក់នៃបទប្បញ្ញត្តិរបស់ក្រុមហ៊ុន

---

[44] *Ibid*

[45] របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការលើកកម្ពស់ និងការពារសិទ្ធិសេរីភាពនៃគំនិត និង ការបញ្ចេញមតិ ។ *ជំងឺរាតត្បាត និងសេរីភាពនៃគំនិត និង ការបញ្ចេញមតិ* ឯកសារ UN A/HRC/44/49 ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០ មាននៅ៖ https://undocs.org/A/HRC/44/49.

ឯកសារ UN CCPR/C/21/Rev.1/Add.13 ') កថាខណ្ឌទី ៨ ឯកសារ UN. CCPR/C/GC/34 កថាខណ្ឌទី ៧ គណៈកម្មាធិការអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិកុមារ *សេចក្តីពន្យល់ទូទៅលេខ ១៦ (ឆ្នាំ២០១៣) ស្តីពីកាតព្វកិច្ចរបស់រដ្ឋទាក់ទងនឹងផលប៉ះពាល់នៃវិស័យធុរកិច្ចលើសិទ្ធិកុមារ* ឯកសារ UN CRC/C/GC/16 ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៣ កថាខណ្ឌ័ទី ២៨ គណៈកម្មាធិការអង្គការសហប្រជាតិស្តីអំពីសិទ្ធិ សេដ្ឋកិច្ច សង្គម និងវប្បធម៌ *សេចក្តីពន្យល់ទូទៅលេខ ២៤ (ឆ្នាំ២០១៧) ស្តីពីកាតព្វកិច្ចរដ្ឋក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌ក្នុងបរិបទនៃសកម្មភាពធុរកិច្ច* ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧ ឯកសារ UN. E/C.12/GC/24 កថាខណ្ឌទី១៤ - ២២ ។

ដូចជាទូរគមនាគមន៍ និងសេវាអ៊ីនធឺណិតដែលផ្តល់កម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គម។ ទោះយ៉ាងណាក៏ដោយ បទប្បញ្ញត្តិបែបនេះត្រូវតែធ្វើឡើងក្នុងគោលបំណងការពារ និងមិនមែនកាត់បន្ថយសិទ្ធិមនុស្សទេ។

កាតព្វកិច្ចនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងយុត្តិសាស្ត្រនៃស្ថាប័នសន្ធិសញ្ញារបស់អង្គការសហប្រជាជាតិក៏ដូចជាគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស(UNGPs)ដែលគាំទ្រដោយក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។ UNGPs រំលឹកឡើងវិញនូវព័ត៌មានលម្អិតនៃកាតព្វកិច្ចការពារទាំងនេះរបស់រដ្ឋ។ លើសពីនេះ ពួកគេផ្តល់ការទទួលខុសត្រូវដោយផ្ទាល់ និងស្របគ្នាសម្រាប់សហគ្រាសអាជីវកម្មខ្លួនឯងក្នុងការគោរពសិទ្ធិមនុស្សក្នុងបរិបទនៃប្រតិបត្តិការអាជីវកម្ម។[47]

UNGPs មានក្របខ័ណ្ឌសម្រាប់ធុរកិច្ច និងសិទ្ធិមនុស្សដែលឈរលើសសរស្តម្ភចំនួនបី ៖ (i)កាតព្វកិច្ចរបស់រដ្ឋក្នុងការការពារប្រឆាំងនឹងការរំលោភសិទ្ធិមនុស្ស (ii) ការទទួលខុសត្រូវរបស់ក្រុមហ៊ុនក្នុងការគោរពសិទ្ធិមនុស្ស និង (iii )លទ្ធភាពទទួលបានសំណងប្រកបដោយប្រសិទ្ធភាព-យុត្តិធម៌ក្នុង និង ក្រៅប្រព័ន្ធតុលាការដោយជនរងគ្រោះនៃការរំលោភបំពាន។[48]

រដ្ឋរក្សាកាតព្វកិច្ចចំបងដើម្បីអនុវត្តច្បាប់គោលនយោបាយ និងបទបញ្ជាសមស្រប និងមានប្រសិទ្ធភាព ដើម្បីធានាការការពារប្រឆាំងនឹងការរំលោភសិទ្ធិមនុស្ស និង ការរំលោភបំពានតាមប្រពន្ធ័អ៊ីនធឺណិត ដោយគោរពតាមការអនុវត្តសិទ្ធិលើកម្មវិធីដែលគ្រប់គ្រង ដោយក្រុមហ៊ុនបច្ចេកវិទ្យាឯកជន ។ [49] កាតព្វកិច្ចនេះ បន្តអនុវត្តវិធានការចាំបាច់ និងសមស្របដើម្បីធានាថានៅកន្លែងដែលមានការរំលោភច្បាប់ និងការរំលោភបំពាន ជនរងគ្រោះអាចទទួលបានសំណងប្រកបដោយប្រសិទ្ធភាព និង គ្រប់គ្រាន់តាមរយៈយន្តការតុលាការ

[47] គោលការណ៍ណែនាំត្រូវបានអនុម័តដោយក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិក្នុងឆ្នាំ២០១១ ក្នុងសេចក្តីសម្រេចលេខ ១៧/៤៖ ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិសេចក្តីសម្រេចដែលអនុម័តដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស ១៧/៤៖ *អង្គការសិទ្ធិមនុស្ស និងសាជីវកម្មឆ្លងដែន និងអង្គភាពធុរកិច្ចផ្សេងទៀត* ឯកសារ UN. A/HRC/RES/17/4 ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១១ ។

[48] OHCHR *គោលការណ៍ណែនាំUN ស្តីអំពីធុរកិច្ច និងសិទ្ធិមនុស្ស* HR/PUB/11/04 ឆ្នាំ២០១១ ('UNGPs') មាននៅ៖ https://www.ohchr.org/documents/publications/GuidingprinciplesBusinesshr_eN.pdf

[49] *IBID* ទំព័រទី៣–១១

ឬមធ្យោបាយរដ្ឋបាលច្បាប់ ឬបទប្បញ្ញត្តិផ្សេងទៀត ។[50] ខណៈពេលដែលក្រុមហ៊ុនបច្ចេកវិទ្យាមានទំនួលខុសត្រូវក្នុងការគោរពសិទ្ធិមនុស្សក្នុងដំណើរប្រតិបត្តិការអាជីវកម្មរបស់ពួកគេ និងផ្តល់ការដោះស្រាយប្រកបដោយប្រសិទ្ធភាព និងគ្រប់គ្រាន់ចំពោះការរំលោភបំពានណាមួយ រដ្ឋមានកាតព្វកិច្ចអនុវត្តការត្រួតពិនិត្យ និងតួនាទីអនុវត្តបទបញ្ញាដើម្បីធានាថាក្រុមហ៊ុនគោរពតាមកាតព្វកិច្ចទាំងនេះ។[51]

ទាក់ទងទៅនឹងកាតព្វកិច្ចរបស់ សហគ្រាសធុរកិច្ច UNGPs ផ្តល់ជូនថាក្រុមហ៊ុនទាំងអស់រួមទាំងក្រុមហ៊ុនបច្ចេកវិទ្យាមានការទទួលខុសត្រូវក្នុងការ "គោរពសិទ្ធិមនុស្ស" ដែល "មានឯករាជ្យភាពពីសមត្ថភាពរបស់រដ្ឋនិង/ឬឆន្ទៈក្នុងការបំពេញកាតព្វកិច្ចសិទ្ធិមនុស្សផ្ទាល់ខ្លួនរបស់ពួកគេហើយមិនបន្ថយកាតព្វកិច្ចទាំងនោះទេ" ។[52] នេះរួមបញ្ចូលទាំងការទទួលខុសត្រូវដើម្បី"ជៀសវាងការរំលោភបំពានសិទ្ធិមនុស្ស"រួមទាំងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងព័ត៌មាន សមាគម និងឯកជនភាព តាមប្រពន្ធ័អ៊ីនធឺណិតដើម្បី "ជៀសវាងបង្ក ឬរួមចំណែកដល់ផលប៉ះពាល់អវិជ្ជមានដល់សិទ្ធិមនុស្សតាមរយៈសកម្មភាពផ្ទាល់ខ្លួនរបស់ពួកគេ" និងដើម្បី "ចាត់វិធានការឱ្យបានគ្រប់គ្រាន់" ដើម្បី "ការពារកាត់បន្ថយ ឬកែតម្រូវ" ផលប៉ះពាល់ទាំងនោះរួមទាំងការដាក់ "គោលនយោបាយ និងដំណើរការយកចិត្តទុកដាក់ត្រួតពិនិត្យហ្មត់ចត់" ដើម្បីធានាថាសិទ្ធិត្រូវបានគោរព។[53]

---

[50] *IBID* ទំព័រទី២៧–៣៥

[51] *IBID* ទំព័រទី៤–៦

[52] *IBID* ទំព័រទី១៣–១៨

[53] *Ibid*

## III. ការអនុម័ត និងការតាក់តែងច្បាប់ថ្មី ដែលផ្ទុយនឹងសិទ្ធិមនុស្ស

អាជ្ញាធរកម្ពុជាបានអនុម័តច្បាប់ថ្មីក្នុងអំឡុងពេល និង ក្នុងការឆ្លើយតបទៅនឹងជំងឺរាតត្បាតកូវីដ-១៩ រួមមាន៖ (i) ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិក្នុងគ្រាអាសន្ន (ii) អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ និង (iii) ច្បាប់ស្តីពីវិធានការបង្ការប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងធ្ងន់ធ្ងរ និងគ្រោះថ្នាក់ផ្សេងទៀត។ អាជ្ញាធរក៏កំពុងស្ថិតក្នុងដំណើរការនៃសេចក្តីព្រាងច្បាប់ថ្មីរួមទាំងច្បាប់ស្តីពីសណ្តាប់ធ្នាប់សាធារណៈ និងច្បាប់ស្តីពី បទល្មើសបច្ចេកវិទ្យាព័ត៌មាន ដែលស្វែងរកការគ្រប់គ្រងបន្ថែមទៀតនូវការបញ្ចេញមតិ និង ព័ត៌មាននៅក្នុងវិស័យឌីជីថល។

ច្បាប់ទាំងនេះដែលត្រូវបានអនុម័ត ឬ កំពុងត្រូវបានព្រាងមានបទប្បញ្ញត្តិដែលមិនអនុលោមតាមច្បាប់ និងស្តង់ដារសិទ្ធិមនុស្ស។ ច្បាប់នេះធ្វើឱ្យពួកគេងាយរងការរំលោភបំពានដើម្បីរឹតត្បិតសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ព័ត៌មាន និងសិទ្ធិផ្សេងៗទៀត ។ ភាពខ្វះខាតនៅក្នុងច្បាប់ទាំងនេះរួមមាន៖ (i) ភាសាមិនច្បាស់លាស់ និងទូលំទូលាយពេក (ii) ទណ្ឌកម្មដែលមិនចាំបាច់ និងមិនសមាមាត្រ និង (iii) កង្វះយន្តការត្រួតពិនិត្យឯករាជ្យ។

### *i. ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិក្នុងគ្រាអាសន្ន*[54]

កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០ ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិក្នុងភាពអាសន្ន (‘ច្បាប់ស្តីពីស្ថានភាពអាសន្ន’) ត្រូវបានអនុម័តដោយរដ្ឋសភា និងព្រឹទ្ធសភារបស់កម្ពុជា។ ច្បាប់នេះផ្តល់នូវការប្រើប្រាស់អំណាចបន្ថែមរបស់រដ្ឋាភិបាលក្នុងពេលមានស្ថានភាពអាសន្នដែលអាចប្រកាសអនុលោមតាមមាត្រា ២២ នៃរដ្ឋធម្មនុញ្ញកម្ពុជា។[55]

---

[54] ICJ ធ្លាប់បានវិភាគច្បាប់នេះនៅក្នុងការបោះពុម្ពផ្សាយមុនៗរបស់ខ្លួន៖ ICJ ‘អ្នកសារព័ត៌មាន និងកម្មវិធីប្រព័ន្ធផ្សព្វផ្សាយដែលមានហានិភ័យកើនឡើងនៅក្នុងប្រទេសកម្ពុជា ថៃ និងវៀតណាម អំឡុងពេលជំងឺរាតត្បាត COVID-19’ ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២១ ទំព័រទី១-៣ មាននៅ៖ https://www.icj.org/journalists-and-media-platforms-at-increased-risk-in-cambodia-thailand-and-vietnam-during-the-covid-19-pandemic/ ICJ ‘កម្ពុជា៖ សេចក្តីព្រាងច្បាប់ស្តីពីគ្រាអាសន្ន រំលោភលើនីតិរដ្ឋ’ ថ្ងៃទី៨ ខែមេសា ឆ្នាំ២០២០ មាននៅ៖ https://www.icj.org/cambodia-state-of-emergency-bill-violates-the-rule-of-law/ ។

[55] មាត្រា ២២ នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា៖ “នៅពេលដែលប្រទេសជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រះមហាក្សត្រទ្រង់ប្រកាសជាសាធារណៈដោយដាក់ប្រទេសស្ថិតក្នុងគ្រាអាសន្ន បន្ទាប់ពីមានការព្រមព្រៀងជាឯកច្ឆ័ន្ទពីនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា”។ សូមមើលរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលមាននៅ៖ https://www.wipo.int/edocs/lexdocs/laws/en/kh/kh009en.pdf#page=10 នេះត្រូវបានលើកឡើងទៀតនៅក្នុងមាត្រា ២ និង ៣ នៃច្បាប់ស្តីពីគ្រាអាសន្ន។

មាត្រា ៥ នៃច្បាប់ស្តីពីភាពអាសន្នរបស់រដ្ឋចែងអំពីអំណាចរបស់រដ្ឋាភិបាលក្នុងការដាក់កំហិត "សមស្រប និងចាំបាច់" លើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ព័ត៌មាន និងឯកជនភាព ក្នុងអំឡុងពេលមានស្ថានភាពអាសន្នរួមមាន៖

- "ហាមប្រាម ឬកំណត់លើការចែកចាយ ឬការផ្សាយព័ត៌មានដែលអាចបង្កឱ្យមានការភ័យស្លន់ស្លោ ឬចលាចលជាសាធារណៈប៉ះពាល់ខ្លាំងដល់សន្តិសុខជាតិ ឬការភាន់ច្រលំអំពីស្ថានការណ៍ស្ថិតនៅក្រោមស្ថានភាពគ្រាអាសន្ន" និង
- "វិធានការឃ្លាំមើលដោយមធ្យោបាយណាមួយសម្រាប់ព័ត៌មានឌីជីថលក្នុងការឆ្លើយតបទៅនឹងស្ថានភាពអាសន្ន" ។[56]

យោងតាមមាត្រា៨ នៃច្បាប់ស្តីពីស្ថានភាពអាសន្ន ការខកខានដោយចេតនាក្នុង "ការគោរពវិធានការ" ដែលមានក្នុងមាត្រា ៥ អាចប្រឈមនឹងការផ្តន្ទាទោសដាក់ពន្ធនាគារពីមួយខែ ទៅមួយឆ្នាំ និងពិន័យជាប្រាក់ពី ១០០,០០០ (ប្រហែល ២៥ ដុល្លារ) ដល់ ២ លានរៀល (ប្រហែល ៥០០ ដុល្លារ)។ ប្រសិនបើការខកខាននេះ បង្កឱ្យមានភាពចលាចលជាសាធារណៈ នោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយឆ្នាំទៅប្រាំឆ្នាំ និងពិន័យជាប្រាក់ពីមួយលាន (ប្រហែល ២៥០ ដុល្លារ) ដល់ ១០ លានរៀល (ប្រហែល ២,៥០០ ដុល្លារ)។[57]

ពាក្យមិនច្បាស់លាស់ "ការភ័យស្លន់ស្លោជាសាធារណៈ" "ភាពចលាចល" "ប៉ះពាល់ខ្លាំងដល់សន្តិសុខជាតិ" និង "ការភាន់ច្រលំ" មិនត្រូវបានកំណត់ទាំងស្រុងនៅក្នុងច្បាប់ស្តីពីស្ថានភាពអាសន្ននោះទេ។ កិច្ចការនេះអនុញ្ញាតឱ្យរដ្ឋមានសក្តានុពលនៃការគ្រប់គ្រង តាមរយៈការបកស្រាយទូលំទូលាយពេកនៃគោលគំនិតទាំងនេះលើសពីបញ្ជីនៃគោលបំណងស្របច្បាប់ ដែលបានរាប់បញ្ចូលក្នុងមាត្រា ១៩(៣) នៃ ICCPR ។

ទោះបីជាការអនុម័តវិធានការមានគោលបំណងស្របច្បាប់ក្នុងមាត្រា១៩(៣) (ឧ. សុខភាពសាធារណៈ) ភាសាមិនច្បាស់លាស់ និងទូលំទូលាយពេកនៃច្បាប់ស្តីពីភាពអាសន្ន គឺមិនសមស្របនឹងគោលការណ៍នីត្យានុកូលភាពដែលតម្រូវឱ្យ

---

សូមមើលច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិក្នុងគ្រាអាសន្ន ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០ ('ច្បាប់ស្តីពីគ្រាអាសន្ន') មាននៅ៖ https://akp.gov.kh/post/detail/29564

[56] មាត្រា ៥ ច្បាប់ស្តីពីគ្រាអាសន្ន

[57] មាត្រា ៨ ច្បាប់ស្តីពីគ្រាអាសន្ន

ច្បាប់ "បង្កើតឡើងឲ្យមានភាពច្បាស់លាស់គ្រប់គ្រាន់" ហើយ "ច្បាប់អាចមិនផ្តល់នូវឆន្ទានុសិទ្ធិដោយសេរីដល់ការរឹតត្បិតសេរីភាពនៃការបញ្ចេញមតិ លើជនជាប់ចោទដែលត្រូវបានចោទប្រកាន់ពីការអនុវត្តរបស់ខ្លួននោះទេ"។[58]

អំណាចដែលបានផ្តល់ឱ្យរដ្ឋដើម្បីប្រើប្រាស់ "មធ្យោបាយណាមួយ" និងការដាក់ទណ្ឌកម្មធ្ងន់ធ្ងរចំពោះការមិនអនុលោមតាមច្បាប់ សឲ្យឃើញថា មិនសមស្របនឹងគោលការណ៍នៃភាពចាំបាច់ និងសមាមាត្រ។ ដូចដែលបានចង្អុលបង្ហាញទាក់ទងនឹង ច្បាប់ភាពអាសន្នដោយអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា "ការដាក់ទោស និងការផាកពិន័យគួរតែសមស្របទៅនឹងភាពធ្ងន់ធ្ងរនៃបទល្មើស ដែលបានប្រព្រឹត្តដោយពិចារណាលើស្ថានភាពសេដ្ឋកិច្ចរបស់បុគ្គលម្នាក់ៗ "។[59]

ច្បាប់នេះមិនផ្តល់សម្រាប់ការត្រួតពិនិត្យប្រព័ន្ធតុលាការឬរដ្ឋបាលប្រកបដោយប្រសិទ្ធភាព ឬការត្រួតពិនិត្យវិធានការនានាដែលដាក់នៅក្រោមច្បាប់ភាពអាសន្នរួមទាំងវិធានការ ដើម្បីរឹតបន្តឹងព័ត៌មាន ឬការបញ្ចេញមតិដែលមិនពេញចិត្ត ។ មាត្រា ៦ នៃច្បាប់ស្តីពីភាពអាសន្នតម្រូវឱ្យរដ្ឋាភិបាល "បន្តរាយការណ៍អំពីវិធានការក្នុងភាពអាសន្នទៅកាន់រដ្ឋសភា និងព្រឹទ្ធសភា" ហើយរដ្ឋសភា និងព្រឹទ្ធសភា "អាចស្នើសុំព័ត៌មានចាំបាច់បន្ថែមពីរាជរដ្ឋាភិបាលក្នុងក្របខណ្ឌនៃការត្រួតពិនិត្យ និងវាយតម្លៃវិធានការនានាដែល ដាក់ចេញសម្រាប់ប្រទេសជាតិ នៅពេលដែលវាមានគ្រោះថ្នាក់ស្របតាមរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា"។[60] ទោះជាយ៉ាងនេះក្តី ច្បាប់ស្តីពីភាពអាសន្នរបស់រដ្ឋមិនអាច បញ្ជាក់បន្ថែមអំពីនីតិវិធី ត្រួតពិនិត្យឯករាជ្យណាមួយច្បាស់លាស់ សម្រាប់គណនេយ្យភាព ផ្ទុយនឹងច្បាប់ និងស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ។[61]

---

[58] ឯកសារ UN CCPR/C/GC/34 កថាខណ្ឌទី ២៥

[59] OHCHR ' អ្នកជំនាញអង្គការសហប្រជាជាតិព្រមានថា ច្បាប់គ្រាអាសន្នរបស់កម្ពុជាបង្កគ្រោះថ្នាក់ដល់សិទ្ធិមនុស្ស' ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ មាននៅ៖
https://www.ohchr.org/en/NewsEvents/Pages/DisplayNews.aspx?NewsID=25801&LangID=E

[60] មាត្រា ៦ ច្បាប់គ្រាអាសន្ន។

[61] គោលការណ៍ទី៣ នៃគោលការណ៍ Tshwane តម្រូវឱ្យនៅក្នុងព្រឹត្តិការណ៍នៃការរឹតបន្តឹងលើសិទ្ធិទទួលបានព័ត៌មាន ច្បាប់ "ផ្តល់ការការពារគ្រប់គ្រាន់ប្រឆាំងនឹងការរំលោភបំពាន រួមទាំងការត្រួតពិនិត្យភ្លាមៗ ពេញលេញ អាចចូលដំណើរការបាន និងមានប្រសិទ្ធភាពនៃសុពលភាពនៃការរឹតបន្តឹងដោយអាជ្ញាធរត្រួតពិនិត្យឯករាជ្យ និងការត្រួតពិនិត្យពេញលេញដោយតុលាការ"សូមមើល *គោលការណ៍សកលស្តីពីសន្តិសុខជាតិ និងសិទ្ធិទទួលបានព័ត៌មាន (គោលការណ៍ Tshwane)* ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៣

[138] AL KHM 8/2020, ទំព័រទី ៨ គាត់ត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅមណ្ឌលអប់រំកែប្រែភ្នំពេញ ១ ហើយពាក្យសុំនៅក្រៅឃុំរបស់គាត់ត្រូវបានបដិសេធនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១។ អ្នកការពារជួរមុខ 'ការសុំនៅក្រៅឃុំត្រូវបានបដិសេធចំពោះអ្នកការពារសិទ្ធិ ៧នាក់' ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ មាននៅ៖ https://www.frontlinedefenders.org/en/case/bail-denied-seven-human-rights-defenders-1

ដែលបង្ហោះលើយ៉ូធូបអំពីការបាត់បង់ទឹកដីទៅប្រទេសវៀតណាម និងស្ថានភាព សេដ្ឋកិច្ចរបស់ប្រទេស។[139] ឡុង ពុទ្ធារ៉ា ត្រូវបានតុលាការកាត់ទោសឲ្យជាប់ពន្ធនាគារ ៥ខែ។[140] លោក គា សុគន្ធ ត្រូវបានសាលាឧទ្ធរណ៍ខេត្តបាត់ដំបង សម្រេចផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេល ១ឆ្នាំកន្លះ នៅខែមិថុនា ឆ្នាំ២០២១។[141] នៅខែឧសភា ឆ្នាំ២០២១ មានសេចក្តីរាយការណ៍ថាតុលាការខេត្តប៉ៃលិនបានកាត់ទោស **យុង សូដា** គ្រូបង្រៀនម្នាក់ត្រូវជាប់ពន្ធនាគារ១ឆ្នាំ តាមមាត្រា៤៩៤ និង៤៩៥ ពាក់ព័ន្ធនឹងការអត្ថាធិប្បាយលើ Facebook ដែលគាត់បានបង្ហោះកាលពីខែកញ្ញា ឆ្នាំ២០២០ ដោយបង្កប់ន័យថា "ស្តូបមិត្តភាពកម្ពុជា-វៀតណាមក្នុងអតីតបន្ទាយខ្មែរក្រហមដ៏រឹងមាំនៃខេត្តប៉ៃលិន ជានិមិត្តរូបនៃការបន្តគាំទ្ររបស់កម្ពុជាចំពោះប្រទេសវៀតណាម"។[142]

---

[139] សេចក្តីថ្លែងការណ៍របស់ ICJ ខែកញ្ញា ឆ្នាំ២០២០ សារព័ត៌មាន The Diplomat 'អ្នកចម្រៀងរ៉េបពីរនាក់ដែលត្រូវបានកាត់ទោសពីបទ "ញុះញង់" នៅកម្ពុជា' ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ មាននៅ៖ https://thediplomat.com/2020/12/two-rappers-convicted-of-incitement-in-cambodia/ វិទ្យុអាស៊ីសេរី 'អ្នកចម្រៀងរ៉េបកម្ពុជា ត្រូវបានកាត់ទោសឲ្យជាប់គុកយូរឆ្នាំចំពោះការនិយាយរិះគន់រដ្ឋាភិបាល' ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ មាននៅ៖ https://www.rfa.org/english/news/cambodia/rappers-12222020160950.html

[140] *Ibid*

[141] *Ibid* សារព័ត៌មាន VOD 'ការកាត់ទោសដាក់ពន្ធនាគាររបស់ Rapper ដោយសាលាឧទ្ធរណ៍បាត់ដំបង' ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១ មាននៅ៖ https://vodenglish.news/rappers-jail-sentence-upheld-by-battambang-appeal-court/

[142] វិទ្យុអាស៊ីសេរី 'គ្រូបង្រៀនខ្មែរត្រូវជាប់គុកពីបទរិះគន់ស្តូបមិត្តភាពកម្ពុជា-វៀតណាម' ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១ មាននៅ៖ https://www.rfa.org/english/news/cambodia/teacher-05252021213609.html

*សកម្មនិយមសិទ្ធិបរិស្ថាន*

នៅខែឧសភា ឆ្នាំ២០២១ **ភួន កែវរស្មី ឡុង គន្ធា** និង **ថុន រដ្ឋា** សកម្មជនមកពីអង្គការមាតាធម្មជាតិកម្ពុជា ត្រូវបានតុលាការក្រុងភ្នំពេញរកឃើញថា មានពិរុទ្ធពីបទញុះញង់តាមមាត្រា ៤៩៤ និង ៤៩៥។[143] លោក ថុន រដ្ឋា ត្រូវបានតុលាការផ្តន្ទាទោសឲ្យជាប់ពន្ធនាគារចំនួន ២០ខែ និងពិន័យជាប្រាក់ចំនួន ៤ លានរៀល (ប្រហែល ១,០០០ ដុល្លារ) ចំណែក ភួន កែវរស្មី និង ឡុង គន្ធា ត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារ ១៨ខែ និងពិន័យជាប្រាក់ ៤ លានរៀល (ប្រហែល ១,០០០ ដុល្លារ)។[144]

សហសេវិកពីរនាក់របស់ពួកគេ **លោក Alejandro Gonzalez-Davidson** និង **ជា គន្ទីន** ក៏ត្រូវបានកាត់ទោស *កំបាំងមុខ* ផងដែរចំពោះបទចោទដូចគ្នា ដោយមានដីកាចេញសម្រាប់ការចាប់ខ្លួន។ លោក Alejandro Gonzalez-Davidson ស្ថាបនិក ចលនាបរិស្ថានមាតាធម្មជាតិ ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារចំនួន ២០ខែ ខណៈដែល ជា គន្ទីន ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេល ១៨ខែ។ ពួកគេក៏ត្រូវបានផាកពិន័យចំនួនបួនលានរៀលផងដែរ (ប្រហែល ១,០០០ ដុល្លារ) ក្នុងម្នាក់ៗ ។[145]

សកម្មជនបរិស្ថានត្រូវបានកាត់ទោសពីបទ "ញុះញង់" សម្រាប់ការតវ៉ាការបំពេញបឹងតាមោក ក្នុងរាជធានីភ្នំពេញ ដោយសារតែមានការព្រួយបារម្ភអំពីផលប៉ះពាល់នៃទឹកជំនន់នៅក្នុងទីក្រុង។ កាលពីថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២១ ឡុង គន្ធា ភួន កែវរស្មី និង ថុន រដ្ឋា ត្រូវបានចាប់ខ្លួនភ្លាមៗបន្ទាប់ពីបានប្រកាសនៅលើ Facebook អំពីផែនការរបស់ក្រុមឱ្យ ឡុង គន្ធា ធ្វើបាតុកម្មដោយមនុស្សតែម្នាក់ដែលពួកគេមានបំណង ផ្សាយផ្ទាល់

[143] សេចក្តីថ្លែងការណ៍របស់ ICJ ខែកញ្ញា ឆ្នាំ២០២០ សារព័ត៌មាន VOD 'អ្នកការពារបរិស្ថានមាតាធម្មជាតិត្រូវបានរកឃើញថាមានទោសពីបទញុះញង់' ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២១ មាននៅ៖ https://vodenglish.news/mother-nature-environmentalists-found-guilty-of-incitement/ អង្គការលើកលែងទោសអន្តរជាតិ 'កម្ពុជា៖ "ហួសហេតុ" ការកាត់ទោសសកម្មជនបរិស្ថានប្រាំនាក់ ត្រូវតែទំលាក់ចោល' ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២១ មាននៅ៖ https://www.amnesty.org/en/latest/news/2021/05/cambodia-outrageous-conviction-of-five-environmental-activists-must-be-overturned/ សារព័ត៌មាន The Diplomat, 'យុវជនកម្ពុជាបីនាក់ជាប់ពន្ធនាគារសម្រាប់សកម្មភាពនិយមខាងបរិស្ថាន' ថ្ងៃទី ៦ ខែឧសភា ឆ្នាំ២០២១ មាននៅ៖ https://thediplomat.com/2021/05/trio-of-cambodian-youth-imprisoned-for-environmental-activism/

[144] *Ibid*

[145] *Ibid*

តាមអ៊ីនធឺណិត។[146] ពាក់ព័ន្ធនឹងការចាប់ខ្លួន ការឃុំខ្លួន និងការចោទប្រកាន់សកម្មជនបរិស្ថានទាំងបីនាក់ និង អ្នកការពារសិទ្ធិមនុស្សផ្សេងទៀត ក្រុមអ្នកជំនាញនៃក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ រួមទាំងក្រុមការងារស្តីពីការឃុំខ្លួនតាមអំពើចិត្ត អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា អ្នករាយការណ៍ពិសេសស្តីពីការលើកកម្ពស់ និង ការពារសិទ្ធិសេរីភាពនៃគំនិត និង ការបញ្ចេញមតិ អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និង ការបង្កើតសមាគម អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពអ្នកការពារសិទ្ធិមនុស្ស និង ក្រុមការងារស្តីពីការរើសអើងលើស្ត្រី និង កុមារី បានសម្តែងនូវ "ក្តីកង្វល់យ៉ាងធ្ងន់ធ្ងរទាក់ទងនឹង វិធីដាក់ទោសព្រហ្មទណ្ឌដល់ អ្នកការពារសិទ្ធិមនុស្សដែលអនុវត្តការងាររបស់ពួកគេ" រួមទាំង "ធ្វើការតស៊ូមតិតាមអ៊ីនធឺណិតតាមរយៈកម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គម" ។[147] ពួកគេក៏បានសម្តែងការព្រួយបារម្ភអំពីការប្រើប្រាស់មាត្រា ៤៩៤ និង ៤៩៥ ដើម្បីដាក់ទោស ចំពោះការងាររបស់អ្នកការពារសិទ្ធិមនុស្ស និងសកម្មជន "ដែលគ្រាន់តែអនុវត្តសិទ្ធិសេរីភាពក្នុងការជួបប្រជុំ សមាគម និង សេរីភាពនៃការបញ្ចេញមតិ" ជាពិសេស បុគ្គល "មិនគួរត្រូវបានចាប់ខ្លួនឬកាត់ទោសព្រហ្មទណ្ឌចំពោះការចូលរួមក្នុងការប្រជុំដោយសន្តិវិធីរបស់ពួកគេនោះទេ"។[148]

---

[146] *Ibid*

[147] AL KHM 8/2020 ទំព័រទី១១ គួរកត់សម្គាល់ថា ទោះបីជារដ្ឋាភិបាលកម្ពុជាបានឆ្លើយតបទៅនឹងការទំនាក់ទំនង របស់អ្នកជំនាញនៃក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិក៏ដោយ ប៉ុន្តែពួកគេមិនបានលើកឡើងពីកង្វល់បន្ថែមដែលលើកឡើងដោយពួកគេនោះទេ ហើយផ្ទុយទៅវិញបានលើកឡើងម្តងទៀតនូវអ្វីដែលបានចែករំលែករួចហើយទាក់ទងនឹងករណីរបស់លោក រ៉ុង ឈុន នៅក្នុងការឆ្លើយតបរបស់រដ្ឋាភិបាលកម្ពុជា AL KHM 6/2020 សូមមើល *បេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជាប្រចាំការិយាល័យអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិដទៃទៀត នៅទីក្រុងហ្សឺណែវ* លេខ 2021/01/104 ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ មាននៅ៖ https://spcommreports.ohchr.org/TMResultsBase/DownLoadFile?gId=35930

[148] AL KHM 8/2020 ទំព័រទី១១

លើសពីនេះ ICJ មានការព្រួយបារម្ភអំពីមូលដ្ឋានភស្តុតាងដែលការកាត់ទោស ត្រូវបានធ្វើឡើង ដែលជាមូលដ្ឋានគ្រឹះនៃនីតិរដ្ឋ និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ យោងតាមអង្គការលីកាដូ ដែលជាអង្គការក្រៅរដ្ឋាភិបាលសិទ្ធិមនុស្សនៅកម្ពុជា ការកាត់ក្ដី "ភាគច្រើនមានសំណួរទាក់ទងនឹងគណនីហ្វេសប៊ុករបស់មាតាធម្មជាតិ ដែលជា អ្នកផ្តល់មូលនិធិដល់អ្នកការពារសិទ្ធិបរិស្ថាន និងការបង្ហោះតាមប្រព័ន្ធផ្សព្វផ្សាយសង្គម ទាំងអស់នោះមិនត្រូវបានចាត់ទុកថាជាភស្តុតាងនៃការញុះញង់នោះទេ"។ .[149]

មានការចោទប្រកាន់គួរឱ្យទុកចិត្តផងដែរ ទាក់ទងនឹងការរំលោភសិទ្ធិឯកជនភាពរបស់សកម្មជន ដែលនាំឱ្យមានការចាប់ខ្លួន និងការផ្តន្ទាទោសជាបន្តបន្ទាប់។ យោងតាមព័ត៌មានដែលទទួលបានដោយក្រុមអ្នកជំនាញនៃក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិខាងលើ ពេលដែល ថន រដ្ឋា ត្រូវបានមន្ត្រីនគរបាលចំនួន ២៥ នាក់ ឃាត់ខ្លួន ដោយចោទប្រកាន់ថា មិនមានការបង្ហាញដីកាចាប់ខ្លួនទេ មន្ត្រីជូនដំណឹងដល់គាត់ សួរនាំថា "ប៉ូលិសលួចចូលគណនីហ្វេសប៊ុករបស់គាត់"។[150] ប្រសិនបើជាការពិត វាមិនច្បាស់ថាមូលដ្ឋាន ច្បាប់សម្រាប់ "ការលួចចូល" នេះជាអ្វីនោះទេ ទោះបីជាវាត្រូវបានកត់សម្គាល់ថាការឃ្លាំមើលទូរគមនាគមន៍ទាំងអស់ រួមទាំងការផ្ញើសារឯកជនអាចអនុញ្ញាតបាន ប្រសិនបើធ្វើឡើងដោយមានការយល់ព្រមពី "អាជ្ញាធរស្របច្បាប់" ក្រោមច្បាប់ ស្តីអំពីទូរគមនាគមន៍។[151]

កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ មានសេចក្តីរាយការណ៍មកថា សកម្មជនទាំងបីនាក់កំពុងប្រឈមមុខនឹងការចោទប្រកាន់បន្ថែមពី បទ «រួមគំនិតក្បត់ » តាមមាត្រា ៤៥៣ នៃក្រមព្រហ្មទណ្ឌពាក់ព័ន្ធនឹងសំណុំរឿងដែលកំពុងបន្តប្រឆាំងនឹងសកម្មជន៤

---

[149] អង្គការលីកាដូ 'សកម្មជនបរិស្ថានដែលត្រូវបានកាត់ទោសពីបទញុះញង់ឱ្យមានផែនការធ្វើបាតុកម្មដោយសន្តិវិធី' ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២១ មាននៅ៖ https://www.licadho-cambodia.org/flashnews.php?perm=287&english សារព័ត៌មាន VOD 'អ្នកការពារបរិស្ថានមាតាធម្មជាតិត្រូវបានរកឃើញថាមានទោសពីបទញុះញង់' ថ្ងៃទី៥ ខែឧសភា ឆ្នាំ ២០២១ មាននៅ៖ https://vodenglish.news/mother-nature-environmentalists-found-guilty-of-incitement/

[150] AL KHM 8/2020 ទំព័រទី៦

[151] មាត្រា ៩៧ ច្បាប់ស្តីពីទូរគមនាគមន៍ ។ មិនមាននិយមន័យនៃអ្វីដែលបង្កើតជា "អាជ្ញាធរស្របច្បាប់" ឬមធ្យោបាយដែលអាជ្ញាធរមានសមត្ថកិច្ច ដើម្បីអនុម័តការឃ្លាំមើលនោះទេ។ សូមមើលផងដែរ៖ លីកាដូ 'ច្បាប់ទូរគមនាគមន៍កម្ពុជា៖ ការវិភាគផ្នែកច្បាប់' ខែមីនា ឆ្នាំ២០១៦ មាននៅ៖ https://www.licadho-cambodia.org/reports.php?perm=214

នាក់ផ្សេងទៀត មកពីអង្គការមាតាធម្មជាតិកម្ពុជា។[152]រឿងនេះបានកើតឡើងបន្ទាប់ពីចៅក្រមស៊ើបសួរបាននាំពួកគេម្នាក់ៗទៅតុលាការដើម្បីសាកសួរដោយគ្មានវត្តមាន មេធាវីរបស់ពួកគេ។ ប្រសិនបើត្រូវបានផ្តន្ទាទោស ពួកគេអាចប្រឈមមុខនឹងការជាប់ពន្ធនាគាររយៈពេល១០ឆ្នាំ បន្ថែមពីលើ ១៨ និង ២០ ខែដែលពួកគេកំពុងជាប់ពន្ធនាគារពីបទ "ញុះញង់" ។[153]

*ទម្រង់ផ្សេងទៀតនៃការបញ្ចេញមតិ និងខ្លឹមសារដែលមិនពេញចិត្ត*

ក្នុងខែមិថុនា ឆ្នាំ២០២០ **គង់ រ៉ៃយ៉ា** សកម្មជនយុវជនម្នាក់ដែលធ្លាប់មានទំនាក់ទំនងជាមួយគណបក្សសង្គ្រោះជាតិ ត្រូវបានតុលាការផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេលពីរឆ្នាំ តាមមាត្រា៤៩៤ និង៤៩៥ ពីបទលក់អាវយឺតមានរូបភាពលោក កែម ឡី តាមហ្វេសប៊ុក ។[154] លោក កែម ឡី ជាអ្នកអត្ថាធិប្បាយនយោបាយ និងជាអ្នកការពារសិទ្ធិមនុស្សដ៏លេចធ្លោម្នាក់ ត្រូវបានគេបាញ់សម្លាប់កាលពីខែកក្កដា ឆ្នាំ២០១៦។[155] អាវយឺតមានសម្រង់សម្តីដ៏ល្បីរបស់លោក កែម ឡី ចំនួនពីរ ប៉ុន្តែមិនមានការអំពាវនាវឲ្យមានអំពើ

[152] សារព័ត៌មាន CamboJA News 'សកម្មជនមាតាធម្មជាតិបីនាក់ដែលត្រូវបាន កាត់ទោសឲ្យជាប់គុកត្រូវបានចោទប្រកាន់បន្ថែមពីបទរួមគំនិតក្បត់' ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ មាននៅ៖ https://cambojanews.com/three-convicted-mother-nature-activists-handed-an-additional-plotting-charge/ សកម្មជនបីនាក់ផ្សេងទៀត និងសហស្ថាបនិកអង្គការមាតាធម្មជាតិ ដែលបន្តនៅក្រៅប្រទេស កំពុងត្រូវបានចោទប្រកាន់តាមមាត្រា ៤៥៣ និង ៤៣៧ នៃក្រមព្រហ្មទណ្ឌ ដោយចោទពីបទ ឯកសាររបស់ពួកគេថា ទឹកស្អុយបានចូលទៅក្នុងទន្លេសាប ក្បែរព្រះបរមរាជវាំង។ សូមមើល ក្រុមឃ្លាំមើលសិទ្ធិមនុស្ស ' ប្រទេសកម្ពុជា៖ សូមដោះលែងសកម្មខាងបរិស្ថាន' ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២១ មាននៅ៖ https://www.hrw.org/news/2021/06/23/cambodia-free-environmental-activists

[153] អង្គការលើកលែងទោសអន្តរជាតិ "ប្រទេសកម្ពុជា៖ សកម្មជនបរិស្ថានប្រឈមមុខនឹងការចោទប្រកាន់បន្ថែម" ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១ មាននៅ៖ https://www.amnesty.ca/ua-urgent-action/cambodia-environmental-activists-face-additional-charges/ RFA 'កម្ពុជាចោទប្រកាន់សកម្មជនមាតាធម្មជាតិបីនាក់ដោយការឃុបឃិត' ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ មាននៅ៖ https://www.rfa.org/english/news/cambodia/activists-charged-07212021185348.html

[154] សារព័ត៌មាន Khmer Post Asia 'គង់ រ៉ៃយ៉ា ត្រូវបានកាត់ទោសឲ្យជាប់គុកពីរឆ្នាំ' ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០ មាននៅ៖ https://en.khmerpostasia.com/2020/06/23/kong-raiya-sentenced-to-two-years/

[155] ICJ បានសហការជាមួយអង្គការសិទ្ធិមនុស្សផ្សេងទៀតបានចេញសេចក្តីថ្លែងការណ៍មួយកាលពី ខែកក្កដា ឆ្នាំ២០២០ ដោយអំពាវនាវឱ្យគណៈកម្មការស៊ើបអង្កេតឯករាជ្យមួយធ្វើការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព និងមិនលម្អៀងលើការស្លាប់របស់លោក កែម ឡី។ សេចក្តីថ្លែងការណ៍ក៏បានកត់សម្គាល់ផងដែរអំពីកាលៈទេសៈជុំវិញការកាត់ទោស គង់ រ៉ៃយ៉ា។ ICJ 'ប្រទេសកម្ពុជា៖ បួនឆ្នាំហើយ គ្មានការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព លើការសម្លាប់លោក កែម ឡី' ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២០ មាននៅ៖ https://www.icj.org/cambodia-4-years-on-no-effective-investigation-into-kem-leys-unlawful-killing/ ICJ 'ប្រទេសកម្ពុជា៖ គ្មានយុត្តិធម៌ ក្នុងខួប៥ឆ្នាំនៃការស្លាប់របស់លោក កែម ឡី' ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២១ មាននៅ៖ https://www.icj.org/cambodia-no-justice-at-5-year-anniversary-of-kem-leys-death/

ហិង្សា ឬភាពវឹកវរអ្វីឡើយ។[156] លោក គង់ រ៉ៃយ៉ា ធ្លាប់ត្រូវបានតុលាការកាត់ទោសឲ្យជាប់ពន្ធនាគារ ១៨ខែកាលពី ឆ្នាំ២០១៥ ពីបទញុះញង់ដោយចេតនាទាក់ទងនឹងការបង្ហោះតាមហ្វេសប៊ុកដែលរិះគន់រដ្ឋាភិបាល។[157]

ការផ្តន្ទាទោសលោក គង់ រ៉ៃយ៉ា ធ្វើឡើងបន្ទាប់ពីមានការអំពាវនាវកាលពីខែកក្កដា ឆ្នាំ ២០១៩ ពីអ្នកជំនាញក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិជាច្រើន បន្ទាប់ពីលោក គង់ រ៉ៃយ៉ា ត្រូវបានចាប់ខ្លួន ឃាត់ខ្លួន និងចោទប្រកាន់ សុំឲ្យដោះលែងលោក ពីការឃុំខ្លួន និងទម្លាក់ចោលរាល់ការចោទប្រកាន់មកលើរូបលោក ដោយបារម្ភថា "ការចាប់ខ្លួន ការឃុំខ្លួន និងការចោទប្រកាន់ព្រហ្មទណ្ឌ ... អាចជាការរិតត្បិត ដោយមិនចាំបាច់ និងមិនសមាមាត្រទៅនឹងសិទ្ធិសេរីភាពនៃគំនិត និងការបញ្ចេញមតិ សិទ្ធិក្នុងការចូលរួមជាសាធារណៈ សេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងការបង្កើតសមាគម និងការការពារសិទ្ធិមនុស្ស"។[158] អ្នកជំនាញក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ រួមមាន ក្រុមការងារស្តីពីការឃុំខ្លួនតាមអំពើចិត្ត អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា អ្នករាយការណ៍ពិសេសស្តីពីការកាត់ទោសក្រៅប្រព័ន្ធតុលាការ ឬការកាត់ទោសតាមអំពើចិត្ត និងលឿន អ្នករាយការណ៍ពិសេសស្តីពីការលើកកម្ពស់ និងការការពារសិទ្ធិសេរីភាពនៃគំនិត និង ការបញ្ចេញមតិ អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាព ក្នុងការជួបប្រជុំដោយសន្តិវិធី និងការបង្កើតសមាគម និងអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពអ្នកការពារសិទ្ធិមនុស្ស។[159]

---

[156] *Ibid* សម្រង់សំដីពីរគឺ "ជូតទឹកភ្នែករបស់អ្នក ហើយបន្តដំណើររបស់អ្នក" និង "ទោះបីជាអ្នកមិនធ្វើអ្វីសោះ ក៏គង់នឹងត្រូវរងគ្រោះដែរ គ្រាន់តែមិនទាន់ដល់វេនរបស់អ្នកប៉ុណ្ណោះ"។

[157] *Ibid*

[158] *អាណត្តិនៃក្រុមការងារស្តីពីការឃុំខ្លួនតាមអំពើចិត្ត អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា អ្នករាយការណ៍ពិសេសស្តីពីការកាត់ទោសក្រៅប្រព័ន្ធតុលាការ ឬការកាត់ទោសតាមអំពើចិត្ត និងលឿន អ្នករាយការណ៍ពិសេសស្តីពីការលើកកម្ពស់ និងការពារសិទ្ធិសេរីភាពនៃគំនិត និងការបញ្ចេញមតិ អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងការបង្កើតសមាគម និងអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពអ្នកការពារសិទ្ធិមនុស្ស* ឯកសារយោង AL KHM 4/2019 ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ ទំព័រទី២មាននៅ៖ https://spcommreports.ohchr.org/TMResultsBase/DownLoadPublicCommunicationFile?gId=24758 ។ អ្នកជំនាញក៏បានសម្តែងការព្រួយបារម្ភចំពោះការឃុំខ្លួន និងចោទប្រកាន់លោក សួង នាគព័ន្ធ ដែលបាន«ប៉ុនប៉ងចូលរួមក្នុងពិធីរំឭកខួប» នៅស្ថានីយប្រេងឥន្ធនៈកាល់តិចបូកគោ ដែលត្រូវបានឃាតកបាញ់សម្លាប់លោក កែម ឡី។

[159] *Ibid* ។ ជាការឆ្លើយតប បេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំការិយាល័យអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិ ផ្សេងទៀត នៅទីក្រុងហ្សឺណែវ បានបញ្ជាក់ថា សកម្មភាព Facebook របស់លោក គង់ រ៉ៃយ៉ា មានគោលបំណងញុះញង់ឲ្យមាន ចលាចល និងស្អប់ខ្ពើមក្នុងសង្គម ហើយសំណុំរឿងព្រហ្មទណ្ឌរបស់លោក

បន្ថែមពីលើការជ្រៀតជ្រែកតាមអំពើចិត្តលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិរបស់ គង់ រ៉ៃយ៉ា តាមរយៈការដាក់ទណ្ឌកម្មព្រហ្មទណ្ឌដែលមិនសមហេតុផល[160] ការកាត់ទោស លោក គង់ រ៉ៃយ៉ា ក៏បានលើកឡើងពីការព្រួយបារម្ភថាតើសិទ្ធិរបស់គាត់ ក្នុងការកាត់ក្ដី ដោយយុត្តិធម៌ និងការសម្រេចចិត្តដោយហេតុផលត្រឹមត្រូវ ត្រូវបានគេគោរពនៅក្នុងដំណើរការសវនាការដែរឬទេ ។ យោងតាម មជ្ឈមណ្ឌលមេធាវីអាមេរិក សម្រាប់សិទ្ធិមនុស្ស ដែលបានតាមដាន ការកាត់ក្ដីព្រហ្មទណ្ឌ របស់លោក គង់ រ៉ៃយ៉ា ព្រះរាជអាជ្ញាបានបរាជ័យក្នុងការ "បន្ថែមភស្តុតាងណាមួយដើម្បីបង្ហាញថា អាវត្រូវបានយល់ថាជាការអំពាវនាវឲ្យមានចលាចលខាងសង្គម ហើយអាវអាចមានឥទ្ធិពលនៃការបង្កើតចលាចលខាងសង្គម ឬថាលោក រ៉ៃយ៉ា មានចេតនាបែបនេះ"។ យ៉ាងណាក៏ដោយ សាលាដំបូងរាជធានីភ្នំពេញបានដោះស្រាយរាល់ការសង្ស័យតាមការអនុគ្រោះរបស់អយ្យការ និងផ្ដន្ទាទោសលោក គង់ រ៉ៃយ៉ា។[161] តុលាការក៏ត្រូវបានគេរាយការណ៍ថាបានផ្ដល់ "ហេតុផលតិចតួចសម្រាប់សាលក្រមរបស់ខ្លួន ដោយលុបចោលការពន្យល់អំពីមូលហេតុដែលខ្លួនបានបដិសេធទឡ្ហីករណ៍ការពារក្ដី ស្ដីពីសេរីភាពនៃការបញ្ចេញមតិ និង មូលហេតុដែលបានរកឃើញថាលោក រ៉ៃយ៉ា មានចេតនាចាំបាច់"។[162]

---

ស្ថិតនៅក្រោមអំណាចតុលាការ គឺជាស្ថាប័នឯករាជ្យ" ហើយថា គង់ រ៉ៃយ៉ា មានសិទ្ធិការពារក្ដីដោយមេធាវីតាមជម្រើសរបស់ខ្លួន និងមានសិទ្ធិប្ដឹងឧទ្ធរណ៍ទៅតុលាការជាន់ខ្ពស់ ស្របតាមច្បាប់ជាធរមាន ក្នុងករណីដែលពួកគេមិនពេញចិត្តនឹងការសម្រេចចិត្តរបស់តុលាការ" *បេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំការិយាល័យអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិដទៃទៀត នៅទីក្រុងហ្សឺណែវ* ឯកសារយោង 2019/09/328 ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ មាននៅ៖ https://spcommreports.ohchr.org/TMResultsBase/DownLoadFile?gId=34874

[160] ស្រដៀងនឹងករណីខាងលើនៃមាត្រា ៤៩៤ និង ៤៩៥ សុន្ទរកថាតាមអ៊ីនធឺណិតរបស់ គង់ រ៉ៃយ៉ា ត្រូវបានការពារនៅក្រោមមាត្រា ១៩ នៃ ICCPR ហើយក្នុងករណីដែលគ្មានភស្តុតាងច្បាស់លាស់ណាមួយដែលថាគាត់មានបំណងញុះញង់ឱ្យមានអំពើហិង្សា ឬអរិភាព មិនអាចត្រូវបានដាក់កំហិតដោយស្របច្បាប់នោះទេ ។ ទោះបីជាក្នុងការស្វែងរកគោលបំណងស្របច្បាប់ក្រោមមាត្រា ១៩ (៣) ឬ២០ នៃ ICCPR ក៏ដោយ ទណ្ឌកម្មព្រហ្មទណ្ឌគឺមិនសមាមាត្រ និងមិនចាំបាច់នោះទេ ។

[161] មជ្ឈមណ្ឌលមេធាវីអាមេរិកសម្រាប់សិទ្ធិមនុស្ស *ប្រទេសកម្ពុជា v. គង់ រ៉ៃយ៉ា* ខែវិច្ឆិកា ឆ្នាំ២០២០ ទំព័រទី ២–៤, ១៩–២១, មាននៅ៖ https://www.americanbar.org/content/dam/aba/administrative/human_rights/trialwatch/fair_trial_report_cambodia_kong_raiya.pdf

[162] *Ibid*

ការកាត់ទោស និងផ្តន្ទាទោសអ្នកការពារសិទ្ធិមនុស្ស និងសកម្មជនអាចស្ថិតនៅក្នុងនិន្នាការកាន់តែទូលំទូលាយនៃការបំភិតបំភ័យ និងការយាយីដល់សកម្មជនសង្គមស៊ីវិល និងអ្នកការពារសិទ្ធិមនុស្ស ដើម្បីបំបិទមាត់ការមិនពេញចិត្ត និងការបញ្ចេញមតិមិនពេញចិត្តផ្សេងទៀត ដែលផ្ទុយពីសិទ្ធិរបស់ពួកគេក្នុងការបញ្ចេញមតិ ការជួបប្រជុំដោយសន្តិវិធី សមាគម និងការចូលរួមនយោបាយ។[163] នៅខែកញ្ញា ឆ្នាំ២០២០ អ្នកនាំពាក្យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សបានចេញសន្និសីទសារព័ត៌មានស្តីពី "ការមិនអត់ឱនចំពោះមតិជំទាស់របស់រដ្ឋាភិបាល ... ដែលផ្តោតសំខាន់ទៅលើអង្គការសិទ្ធិមនុស្ស អ្នកការពារបរិស្ថាន និងអ្នកការពារសិទ្ធិមនុស្ស" ដោយកត់សម្គាល់ *ក្នុងចំណោមផ្សេងៗទៀត* របៀបដែល "ចំនួននៃអង្គការផ្សេងទៀតបានទទួលការចុះមកសួរនាំដោយមន្ត្រី ពិនិត្យការចុះឈ្មោះ អត្តសញ្ញាណ និងឯកសារផ្សេងទៀតរបស់ពួកគេ ខណៈពេលដែលកំពុងជួបប្រទះការឃ្លាំមើលជាបន្តបន្ទាប់"។[164]កាលពីថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២០ ក្រសួងមហាផ្ទៃបានចេញសេចក្តីថ្លែងការណ៍មួយដោយថ្កោលទោសអង្គការ មាតាធម្មជាតិកម្ពុជា និងខ្មែរថាវរៈថាជាអង្គការគ្មានការអនុញ្ញាត ដោយអំពាវនាវឱ្យអាជ្ញាធរមានសមត្ថកិច្ចធ្វើការកាត់ទោសពួកគេ ដោយការសន្មត់ស្ថិតនៅក្រោមច្បាប់មិនអនុលោមតាមសិទ្ធិមនុស្ស ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (LANGO)។ [165]

---

[163] សេចក្តីថ្លែងការណ៍របស់ ICJ ខែកញ្ញា ឆ្នាំ២០២០

[164] OHCHR 'សន្និសីទសារព័ត៌មានស្តីពីកម្ពុជាដោយអ្នកនាំពាក្យនៃឧត្តមស្នងការសិទ្ធិមនុស្ស' ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០ មាននៅ៖ https://cambodia.ohchr.org/en/news/press-briefing-cambodia-spokesperson-high-commissioner-human-rights .

[165] សេចក្តីថ្លែងការណ៍របស់ ICJ ខែកញ្ញា ឆ្នាំ២០២០ អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងសមាគមបានសម្តែងការព្រួយបារម្ភចំពោះច្បាប់ LANGO ក្នុងការទំនាក់ទំនងជាមួយរដ្ឋាភិបាលកម្ពុជា។ សូមមើល៖ *អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងការបង្កើតសមាគម* ឯកសារយោង OL KHM 2/2015 ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៥ មាននៅ៖ https://spcommreports.ohchr.org/TMResultsBase/DownLoadPublicCommunicationFile?gId=20323

## *ii. ការគៀបសង្កត់លើអ្នកសារព័ត៌មាន និងកម្មវិធីប្រព័ន្ធផ្សព្វផ្សាយ*

អាជ្ញាធរកម្ពុជាបានបន្តកំណត់គោលដៅលើអ្នកសារព័ត៌មាន និងកម្មវិធីប្រព័ន្ធផ្សព្វផ្សាយ ដោយគ្រាន់តែអនុវត្តភារកិច្ចវិជ្ជាជីវៈរបស់ខ្លួនក្នុងការស៊ើបអង្កេត និងចែកចាយព័ត៌មានដល់សាធារណជនក្នុងវិស័យឌីជីថល។

នៅកម្ពុជា អ្នកសារព័ត៌មានឯករាជ្យត្រូវបានសម្លុតបំភ័យ ពីអាជ្ញាធរជាយូរមកហើយ ជាពិសេស នៅពេលរាយការណ៍រិះគន់រដ្ឋាភិបាល។[166] យោងតាមសមាគមសម្ព័ន្ធអ្នកសារព័ត៌មាន កម្ពុជា ករណីសម្លុតបំភ័យអ្នកសារព័ត៌មានចំនួន ៣៥ករណី លើអ្នកសារព័ត៌មានចំនួន ៧២ នាក់ ត្រូវបានចងក្រងជាឯកសារក្នុងឆ្នាំ ២០២០ ដែលក្នុងនោះអ្នកកាសែតជាង ៤២នាក់ ត្រូវបានឃុំខ្លួន ដើម្បីសាកសួរ ឬ ដាក់ពន្ធនាគារ។ ពួកគេក៏បានកត់ត្រាករណីសម្លុតបំភ័យ ចំនួន ៣៥ ករណីប្រឆាំងនឹងអ្នកកាសែតចំនួន ៧២ នាក់ក្នុង ឆ្នាំ២០២០ ។ អ្នកកាសែតជាង ៤២នាក់ ដែលពាក់ព័ន្ធត្រូវបានឃុំខ្លួនដើម្បីសាកសួរ ឬដាក់ពន្ធនាគារ ។ យ៉ាងហោច ណាស់ អ្នកកាសែត ២២ នាក់ត្រូវបានវាយប្រហារ ឬគម្រាមកំហែងដោយហិង្សាក្នុងពេល បំពេញកាតព្វកិច្ច ។ អ្នកកាសែតម្នាក់បានស្លាប់ក្នុងអ្វីដែលប៉ូលិសសន្និដ្ឋានថាជាគ្រោះថ្នាក់ចរាចរណ៍ដោយគ្មានការស៊ើបអង្កេតត្រឹមត្រូវ។[167] ឧប្បត្តិហេតុនៃអំពើហិង្សាទាំងនេះ ហាក់ ដូចជាកើតឡើងជាមួយនិទណ្ឌភាព ដល់កម្រិតដែលវាខ្វះ "ការស៊ើបអង្កេតប្រកបដោយ ប្រសិទ្ធភាព ឯករាជ្យ តម្លាភាព និងការកាត់ទោសជនល្មើសស្របតាមស្តង់ដារសិទ្ធិ មនុស្សអន្តរជាតិ"។[168]

---

[166] ICJ *ការដាក់ស្នើ របស់គណៈកម្មាការអ្នកច្បាប់អន្តរជាតិទៅកាន់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ស្របតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ៤៥/១៨* ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២១ ('ICJ ការដាក់ស្នើទៅកាន់ OHCHR ស្តីអំពីអ្នកសារព័ត៌មាន') មាននៅ៖ https://www.icj.org/wp-content/uploads/2021/04/SoutheastAsia-ICJ-OHCHR-Submission-Journalists-Safety-2021-ENG.pdf ICJ ' កម្ពុជា៖ ICJ និងអង្គការចំនួន ៥៦ អំពាវនាវឱ្យអាជ្ញាធរដោះលែងអ្នកសារព័ត៌មាន និងបញ្ឈប់ការយាយីលើប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ' ថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ២០២០ មាននៅ៖ https://www.icj.org/cambodia-icj-and-56-organizations-call-on-authorities-to-release-journalists-and-cease-harassment-of-independent-media/

[167] សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា *របាយការណ៍ស្ថានភាពអ្នកសារព័ត៌មានកម្ពុជាឆ្នាំ ២០២០* ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២០ ('របាយការណ៍ស្ថានភាពអ្នកសារព័ត៌មានកម្ពុជា ឆ្នាំ២០២០') ទំព័រទី៤ មាននៅ៖ https://www.camboja.net/wp-content/uploads/2021/03/Cambodian-Journalism-Situation-Report-2020.pdf

[168] *សេចក្តីថ្លែងការណ៍រួម៖ ទិវាសេរីភាពសារព័ត៌មានពិភពលោក ការលើកកម្ពស់ និងការពារសេរីភាពសារព័ត៌មាន ធានាព័ត៌មានជាប្រយោជន៍សាធារណៈ* ថ្ងៃទី៣ ខែឧសភាឆ្នាំ ២០២១ ('សេចក្តីថ្លែងការណ៍រួមនៃទិវាសេរីភាពសារព័ត៌មានពិភពលោក') ទំព័រទី២

*ការកាត់ទោស និងផ្តន្ទាទោសអ្នកសារព័ត៌មាន*

**លោក សុខ ឧត្តម** ម្ចាស់ស្ថានីយវិទ្យុ និងគេហទំព័រ រិទ្ធីសែន ត្រូវបានផ្តន្ទាទោសកាលពីថ្ងៃទី ២២ ខែធ្នូ ឆ្នាំ២០២០ ឲ្យជាប់ពន្ធនាគាររយៈពេល ២០ខែ និងពិន័យជាប្រាក់ចំនួន ២០ លានរៀល(ប្រហែល៥,០០០ដុល្លា) ក្រោមមាត្រា៤៩៤ និង ៤៩៥។[169] ការចោទប្រកាន់នេះកើតចេញពីលោក សុខ ឧត្តម រាយការណ៍តាម Facebook Live អំពីជម្លោះដីធ្លីដែលកំពុងកើតមានរវាងពលរដ្ឋខេត្តកំពង់ឆ្នាំង និងយោធា។[170]

ការប្រើប្រាស់ទណ្ឌកម្មព្រហ្មទណ្ឌប្រឆាំងនឹងអ្នកសារព័ត៌មានសម្រាប់ការរាយការណ៍តាមអ៊ីនធឺណិតរបស់ពួកគេគឺស្របទៅនឹងនិន្នាការកាន់តែទូលំទូលាយនៃអ្នកកាសែតដែលត្រូវបានកាត់ទោស និងដាក់ពន្ធនាគារសម្រាប់ការអនុវត្តការងាររបស់ពួកគេ។[171] សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជាបានចងក្រងសំណុំរឿងចំនួន ១៥ករណី ពាក់ព័ន្ធនឹង អ្នកសារព័ត៌មានចំនួន ៣១នាក់ កំពុងជាប់ពន្ធនាគារក្នុងនោះ ១១ករណី ពាក់ព័ន្ធនឹង បទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋតាមមាត្រា ៤៩៤ និង ៤៩៥ និងជំរិតទារប្រាក់តាមមាត្រា ២៣២ នៃក្រមព្រហ្មទណ្ឌ។[172] ដោយឡែកអតីតអ្នកកាសែតវិទ្យុអាស៊ីសេរី **លោក យាង សុធារិន្ទ** និង **លោក អ៊ួន ឈិន** មានការប្តឹងឧទ្ធរណ៍របស់ពួកគេឱ្យបញ្ឈប់ការស៊ើបអង្កេតឡើងវិញលើសំណុំរឿងចារកម្ម ដែលត្រូវបានច្រានចោលដោយតុលាការកំពូលក្នុង ខែតុលា ឆ្នាំ២០២០ បន្ទាប់ពីបានការប្តឹងឧទ្ធរណ៍របស់ពួកគេ ឱ្យបញ្ឈប់ការស៊ើបអង្កេត ឡើងវិញលើសំណុំរឿងអាសអាភាស ក៏បានច្រានចោលដោយតុលាការកំពូលនៅក្នុង ខែកក្កដា ឆ្នាំ ២០២០ ។[173] ករណីរបស់ពួកគេត្រូវបានអង្គការសិទ្ធិមនុស្សមួយចំនួនពណ៌នាថា «ត្រូវបានផ្អឹបទុកឲ្យនៅក្នុងកម្រិតផ្លូវច្បាប់អស់រយៈពេលជាងបីឆ្នាំដោយមិនមានការ

---

មាននៅ៖ https://media.business-humanrights.org/media/documents/Joint_statement_World_Press_Freedom_Day.pdf

[169] របាយការណ៍ស្ថានភាពអ្នកសារព័ត៌មានកម្ពុជាឆ្នាំ២០២០ ទំព័រទី១៦

[170] *Ibid* អ្នកកាសែតជាច្រើននាក់ទៀតដែលចុះទៅយកព័ត៌មានជម្លោះដីធ្លីក្នុងថ្ងៃតែមួយមិនត្រូវបានគេចោទប្រកាន់ទេ ។ អាជ្ញាធរបាននិយាយថា សុខ ឧត្តម បានបំពានច្បាប់ដោយសារគាត់បានផ្សាយផ្ទាល់តាមការរាយការណ៍ផ្ទាល់ខ្លួន។

[171] មាត្រា ១៩ 'រដ្ឋាភិបាលកម្ពុជាគួរបញ្ឈប់ការបំបិទមាត់អ្នកសារព័ត៌មាន ប្រព័ន្ធផ្សព្វផ្សាយ' ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២០ មាននៅ៖ https://www.article19.org/resources/cambodias-government-should-stop-silencing-journalists-media-outlets/

[172] របាយការណ៍ស្ថានភាពអ្នកសារព័ត៌មានកម្ពុជាឆ្នាំ ២០២០ ទំព័រទី១៥

[173] វិទ្យុអាស៊ីសេរី 'តុលាការកំពូលរបស់កម្ពុជា ច្រានចោលការស្នើសុំរបស់អតីតអ្នកយកព័ត៌មាន RFA ឲ្យទម្លាក់ការស៊ើបអង្កេតពីបទចារកម្ម' ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ មាននៅ៖ https://www.rfa.org/english/news/cambodia/probe-10272020161213.html

ដោះស្រាយករណីរបស់ពួកគេនៅចំពោះមុខឡើយ»។[174] ICJ បានកត់សម្គាល់ពីមុនថា ការចោទប្រកាន់មិនសមហេតុផលទាំងនេះប្រឆាំងនឹងអ្នកកាសែត "ត្រូវបាននាំយកមកចោទប្រកាន់ក្នុងគោលបំណងតែមួយគត់គឺការបំបិទមាត់ការងាររបស់ពួកគេជាអ្នកសារព័ត៌មាន និងបិទសំឡេង ឯករាជ្យផ្សេងទៀតនៅក្នុងប្រទេសមិនឲ្យនិយាយ"។[175]

*ការដកហូតអាជ្ញាប័ណ្ណប្រព័ន្ធផ្សព្វផ្សាយ*

អាជ្ញាធរកម្ពុជាក៏បានដកហូតអាជ្ញាប័ណ្ណរបស់បណ្តាញសារព័ត៌មានឯករាជ្យដែលជារឿយៗរួមជាមួយនឹងការដាក់ទណ្ឌកម្មព្រហ្មទណ្ឌផងដែរលើអ្នកសារព័ត៌មានពីស្ថាប័នទាំងនោះ។

កាលពី ខែឧសភា ឆ្នាំ២០២០ ក្រសួងព័ត៌មានបានដកហូតអាជ្ញាប័ណ្ណប្រព័ន្ធផ្សព្វផ្សាយរបស់ **វិទ្យុសែន** ពីបទ «ផ្សាយព័ត៌មានបំផ្លើស ញុះញង់ឲ្យមានអំពើហិង្សា ញុះញង់ឲ្យប្រព្រឹត្ត ការរើសអើង និងញុះញង់បង្កអសន្តិសុខ និងភាពចលាចលក្នុងសង្គម» ប៉ុន្មានថ្ងៃមុនលោក សុខ ឧត្តម ម្ចាស់ក្រុមហ៊ុនត្រូវបានចោទប្រកាន់តាមមាត្រា ៤៩៤ និង ៤៩៥។[176] ក្នុងខែមេសា ឆ្នាំ២០២០ **ទូរទស្សន៍** CKV TV Online ជាសារព័ត៌មានអ៊ីនធឺណិតមួយត្រូវបានគេដកហូតអាជ្ញាប័ណ្ណដោយក្រសួងព័ត៌មានដោយចោទប្រកាន់ថា "រំលោភបំពានយ៉ាងធ្ងន់ធ្ងរលើវិស័យសារព័ត៌មានដែលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ"។[177]

---

[174] សេចក្តីថ្លែងការណ៍រួមនៃទិវាសេរីភាពសារព័ត៌មានពិភពលោក ទំព័រទី១

[175] ICJ 'កម្ពុជា៖ ការចោទប្រកាន់លើអ្នកកាសែត យាង សុធារិន និង អ៊ួន ឈិន ត្រូវតែទម្លាក់ចោលការចោទប្រកាន់' ថ្ងៃទី៤ ខែតុលា ឆ្នាំ២០១៩ មាននៅ៖ https://www.icj.org/cambodia-charges-against-journalists-yeang-sothearin-and-uon-chhin-must-be-dropped/

[176] សារព័ត៌មាន VOA Cambodia 'ម្ចាស់វិទ្យុខេត្តកំពង់ឆ្នាំងត្រូវបានចោទប្រកាន់ពីបទ «ញុះញង់» ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០ មាននៅ៖ https://www.voacambodia.com/a/kampong-chhnang-radio-owner-charged-for-incitement/5421115.html គណៈកម្មាធិការការពារអ្នកសារព័ត៌មាន 'អ្នកកាសែតកម្ពុជា សុខ ឧត្តម ត្រូវបានឃុំខ្លួន ក្រោមបទចោទប្រកាន់ញុះញង់' ថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០២០ មាននៅ៖ https://cpj.org/2020/05/cambodian-journalist-sok-oudom-detained-on-incitem/

[177] សារព័ត៌មាន VOA 'ចំពេលមានការដើរថយក្រោយលើសេរីភាពសារព័ត៌មាន រាជធានីភ្នំពេញអំពាវនាវឲ្យមានការរាយការណ៍ដោយវិជ្ជាជីវៈ' នៅថ្ងៃទី ២ ខែឧសភា ឆ្នាំ២០២០

ក្រសួងព័ត៌មានក៏បានដកហូតអាជ្ញាប័ណ្ណប្រព័ន្ធផ្សព្វផ្សាយរបស់ប្រព័ន្ធផ្សព្វផ្សាយមួយចំនួនទៀតសម្រាប់ការរាយការណ៍របស់ពួកគេអំពីជំងឺរាតត្បាត COVID-19 ដែលនឹងត្រូវបានពិពណ៌នាបន្ថែមខាងក្រោមនៅក្នុងផ្នែកទី VI (ii)។[178]

វាត្រូវបានកត់សម្គាល់ដោយអង្គការ Freedom House ថាដំណើរការនៃការដកហូត អាជ្ញាប័ណ្ណប្រព័ន្ធផ្សព្វផ្សាយ "មិនមានតម្លាភាព" ដោយ "មិនមានដំណើរការប្តឹងឧទ្ធរណ៍ច្បាស់លាស់" ហើយថា "ក្រសួងព័ត៌មានគឺជាអាជ្ញាធរតែមួយគត់សម្រាប់ការបែងចែក និងដកហូតអាជ្ញាប័ណ្ណប្រព័ន្ធផ្សព្វផ្សាយ"។[179]

ប្រព័ន្ធនៃការមានក្រសួងព័ត៌មានជាសិទ្ធិអំណាចផ្តាច់មុខសម្រាប់ការបែងចែក និងដកហូតអាជ្ញាប័ណ្ណប្រព័ន្ធផ្សព្វផ្សាយ គឺផ្ទុយនឹងការបញ្ជាក់របស់គណៈកម្មាធិការសិទ្ធិមនុស្សដែលថា រដ្ឋភាគីគួរតែ "បង្កើតអាជ្ញាធរឯករាជ្យ និងអាជ្ញាបណ្ណផ្សព្វផ្សាយសាធារណៈ ដែលមានអំណាចពិនិត្យកម្មវិធីផ្សាយ និងដើម្បីផ្តល់អាជ្ញាប័ណ្ណ" ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែល "សមហេតុផល និងគោលបំណង ច្បាស់លាស់ តម្លាភាព មិនរើសអើង និងបើមិនដូច្នេះទេ ត្រូវអនុលោមតាម [ICCPR]"។[180] ការដកហូតអាជ្ញាប័ណ្ណដោយ ផ្អែកលើដំណើរការមិនតម្លាភាព បង្កឱ្យមានការព្រួយបារម្ភថា តើការរិតត្បិតទាំងនេះស្របតាមគោលការណ៍នីត្យានុកូលភាព ដែលតម្រូវឲ្យការរិតត្បិតលើសេរីភាពនៃការបញ្ចេញមតិត្រូវ"ផ្តល់ដោយច្បាប់" យ៉ាងច្បាស់លាស់ និងមិនផ្តល់ "ការសម្រេចចិត្តដោយមិនមានការអនុញ្ញាត» ដើម្បីរិតត្បិតសេរីភាពនៃការបញ្ចេញមតិទេ។[181] កិច្ចការនេះក៏ធ្វើឱ្យខូច ដល់គោលការណ៍នីតិរដ្ឋ ដែលតម្រូវផងដែរនៅក្រោមច្បាប់សិទ្ធិមនុស្សថា គួរតែមាន នីតិវិធី

---

មាននៅ៖ https://www.voanews.com/press-freedom/amid-backsliding-press-freedoms-phnom-penh-calls-professional-reporting សារព័ត៌មាន VOD ' អ្នកកាសែតជាប់គុក អាជ្ញាប័ណ្ណប្រព័ន្ធផ្សព្វផ្សាយត្រូវបានដកហូតវិញ' ដោយចោទថាផ្សាយព័ត៌មាន បំផ្លើស' ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០ មាននៅ៖ https://vodenglish.news/journalist-jailed-media-license-revoked-over-exaggerated-coverage/

[178] សូមមើលការដាក់ស្នើ ICJ OHCHR ស្តីពីអ្នកសារព័ត៌មាន។

[179] អង្គការ Freedom House 'សេរីភាពនៅលើ Net 2020៖ ប្រទេសកម្ពុជា' ផ្នែកទី ខ៣ មាននៅ៖ https://freedomhouse.org/country/cambodia/freedom-net/2020

[180] ឯកសារ UN CCPR/C/GC/34 កថាខណ្ឌទី៣៩

[181] *IBID*. កថាខណ្ឌទី ២៥-២៦

បណ្ដឹងឧទ្ធរណ៍ដែលផ្ដល់ដោយ "អាជ្ញាធរមានសមត្ថកិច្ចខាងតុលាការ"[182] ដល់កម្រិតដែលមិនមានភាពច្បាស់លាស់ថាតើប្រព័ន្ធផ្សព្វផ្សាយដែលរងផលប៉ះពាល់អាចប្ដឹងឧទ្ធរណ៍ចំពោះការដកហូតអាជ្ញាប័ណ្ណរបស់ពួកគេឬអត់។

ជាក់ស្ដែងអ្នកសារព័ត៌មាន និងបណ្ដាញព័ត៌មានត្រូវបានរារាំងមិនឱ្យធ្វើការហើយត្រូវបានដាក់ទណ្ឌកម្មជាបន្តបន្ទាប់ចំពោះការងាររបស់ពួកគេដោយគ្រាន់តែខ្លាចការផ្សាយឬការផ្សាយព័ត៌មានដែលរិះគន់រដ្ឋាភិបាល ឬបើមិនដូច្នេះទេ ការមិនពេញចិត្ត ។ ក្នុងកម្រិតដែលជាគោលបំណងត្រូវបានកំណត់ វត្ថុបំណងបែបនេះមិនស្របច្បាប់ទេ ។ ដូចដែលបានបញ្ជាក់ដោយ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប វាមិនស្របទៅនឹងមាត្រា ១៩ (៣) នៃ ICCPR ក្នុងការដាក់ទោស ឬ "ហាមឃាត់គេហទំព័រ ឬ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានពីការបោះពុម្ពផ្សាយព័ត៌មានផ្សេងៗដោយផ្អែកលើ មូលដ្ឋាន រិះគន់ រដ្ឋាភិបាល" ។ [183]

ដូច្នេះវិធានការទាំងនេះបានរិតត្បិតដោយខុសច្បាប់នូវកាតព្វកិច្ចវិជ្ជាជីវៈរបស់អ្នកសារព័ត៌មាន និងកម្មវិធីប្រព័ន្ធផ្សព្វផ្សាយ ក្នុងការស៊ើបអង្កេត និងផ្ដល់ព័ត៌មានដល់សាធារណជនដែលជាមូលដ្ឋានគ្រឹះសម្រាប់បុគ្គលក្នុងប្រទេសកម្ពុជាដើម្បីអនុវត្តសិទ្ធិមនុស្សដែលត្រូវបានការពារជាអន្តរជាតិរបស់ពួកគេ។ ដូចដែលបានគូសបញ្ជាក់ដោយឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស នៅខែវិច្ឆិកា ឆ្នាំ២០២០ "ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យដែលមានអំណាច ដើម្បីស៊ើបអង្កេតបញ្ហា និងដកស្រង់ទស្សនៈសំខាន់ៗគឺជាគន្លឹះដើម្បីធានាថាអភិបាលកិច្ច និងស្ថាប័នមានតម្លាភាព និងគណនេយ្យភាព" នៅពេលពួកគេ ដើរតួក្នុងនាមជា អ្នកឃ្លាំមើល និងប្រព័ន្ធព្រមានជាមុន សម្រាប់ភាពមិនប្រក្រតីដែលអាចកើតមានឡើង"។ [184]

ក្នុងកម្រិតដែលការរិតត្បិតអាចត្រូវបាននាំឆ្ពោះទៅរកការបញ្ចប់ដោយស្របច្បាប់ដូចជាការការពារសណ្ដាប់ធ្នាប់សាធារណៈ ឬ សន្តិសុខជាតិដែលពួកវាពិតជាមិនចាំបាច់ និង

---

[182] ឯកសារ UN A/HRC/17/27
គោលការណ៍នេះអនុវត្តនៅពេលដែលមាតិកាអនឡាញត្រូវបានដាក់កម្រិតតាមរយៈការទាមទារឱ្យដកចេញពីអាជ្ញាធរ។ វាជាហេតុផលដែលគោលការណ៍ដូចគ្នាគួរតែអនុវត្តស្រដៀងគ្នាទៅនឹងការដកហូតអាជ្ញាប័ណ្ណប្រព័ន្ធផ្សព្វផ្សាយ។

[183] ឯកសារ UN CCPR/C/GC/34 កថាខណ្ឌទី៤២ - ៤៣

[184] ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស "សេចក្ដីថ្លែងការណ៍ក្នុងសន្និសីទសកលសម្រាប់សេរីភាពប្រព័ន្ធផ្សព្វផ្សាយ" ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ មាននៅ៖ https://www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=26508&LangID=E

សមាមាត្រក្នុងអវត្តមាននៃការប្រព្រឹត្តណាមួយរបស់អ្នកសារព័ត៌មាននិងប្រព័ន្ធផ្សព្វផ្សាយដើម្បីញុះញង់ឱ្យមានអំពើហិង្សា ។ យោងតាមគណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ការដាក់ទណ្ឌកម្មលើប្រព័ន្ធផ្សព្វផ្សាយ ឬ អ្នកសារព័ត៌មានដែលគ្រាន់តែរិះគន់រដ្ឋាភិបាល" មិនអាចត្រូវបានចាត់ទុកថាជាការរិតត្បិតចាំបាច់នៃសេរីភាពក្នុងការបញ្ចេញមតិ" នោះទេ ។[185]

## *iii. ការកំណត់គោលដៅលម្អៀងយេនឌ័រលើស្ត្រីនៅលើប្រព័ន្ធកម្មវិធីផ្សព្វផ្សាយសង្គម*

អាជ្ញាធរកម្ពុជាបានជ្រៀតជ្រែកតាមអំពើចិត្តចំពោះសេរីភាពនៃការបញ្ចេញមតិលើអ៊ីនធឺណិតរបស់ស្ត្រី ជាពិសេសជម្រើសសម្លៀកបំពាក់របស់ពួកគេ ក្នុងលក្ខណៈរើសអើងក្រោមការអំពាវនាវដ៏ទូលំទូលាយពេកក្នុងការការពារប្រពៃណី និងគុណតម្លៃរបស់កម្ពុជា។

មានសេចក្តីរាយការណ៍ថា ក្នុងខែមេសា ឆ្នាំ២០២០ **Ven Rachana** ដែលត្រូវបានគេស្គាល់តាមអ៊ិនឡាញថា ថៃ ស្រីនាង ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលប្រាំមួយខែតាម មាត្រា ៣៨ និង ៣៩ នៃច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការធ្វើអាជីវកម្ម ផ្លូវភេទ និងតាមមាត្រា ២៤៩ នៃក្រមព្រហ្មទណ្ឌ។[186] ការកាត់ទោសរបស់នាងត្រូវបានគេរាយការណ៍ថាត្រូវបានកាត់បន្ថយមកត្រឹមរយៈពេល ២ខែ និង ១៥ថ្ងៃ ហើយត្រូវបានគេចោទប្រកាន់ថាការកាត់ទោស មិនមានមេធាវីទេ ។[187]

---

[185] ឯកសារ UN CCPR/C/GC/34 កថាខណ្ឌទី៤២

[186] សារព័ត៌មាន VOA 'អ្នកលក់អ៊ិនឡាញដែលត្រូវបានកាត់ទោសពីបទ "ផលិតរូបភាពអាសអាភាស" ផ្តល់ការព្យួរទោស' ថ្ងៃទី១ ខែឧសភា ឆ្នាំ២០២០ មាននៅ៖ https://www.voacambodia.com/a/online-seller-convicted-for-producing-pornography-given-a-suspended-sentence-/5400505.html *អាណត្តិរបស់អ្នករាយការណ៍ពិសេសស្តីពីអំពើហិង្សាលើស្ត្រី មូលហេតុ និងផលវិបាករបស់វា អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា អ្នករាយការណ៍ពិសេសស្តីពីការលើកកម្ពស់ និងការពារសិទ្ធិសេរីភាពនៃគំនិត និងការបញ្ចេញមតិ អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងការបង្កើតសមាគម អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពអ្នកការពារសិទ្ធិមនុស្ស អ្នកជំនាញឯករាជ្យលើការការពារប្រឆាំងនឹងអំពើហិង្សា និងការរើសអើងដោយផ្អែកលើនិន្នាការផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ និងក្រុមការងារស្តីពីការរើសអើងលើស្ត្រី និងកុមារី* ឯកសារយោង៖ AL KHM 2/2020 ថ្ងៃទី១ ខែឧសភា ឆ្នាំ២០២០ ('AL KHM 2/2020') ទំព័រទី២ –៣មាននៅ៖ https://spcommreports.ohchr.org/TMResultsBase/DownLoadPublicCommunicationFile?gId=25225

[187] *Ibid.*

Ven Rachana ត្រូវបានផ្តន្ទាទោសពាក់ព័ន្ធនឹងវីដេអូ និងរូបថតរបស់នាងនៅលើហ្វេសប៊ុកលក់សម្លៀកបំពាក់ ដែលត្រូវបានអាជ្ញាធរចាត់ទុកថាសិចស៊ីពេក និងបំពានបទដ្ឋានវប្បធម៌ខ្មែរ។[188] ការផ្តន្ទាទោសនេះ ធ្វើឡើងបន្ទាប់ពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន តាមសេចក្តីរាយការណ៍ បានបញ្ជាឱ្យអាជ្ញាធរក្នុងខែកុម្ភៈ ឆ្នាំ ២០២០ តាមដាន អ្នកលក់តាម Facebook ដែលស្លៀក [ខ្លី] លក់ទំនិញដូចជាសម្លៀកបំពាក់ និងផលិតផលថែរក្សាសម្ផស្ស» ព្រោះថាពួកគេបាន «រំលោភលើវប្បធម៌ និងប្រពៃណីខ្មែរ» ដោយអះអាងថា អាកប្បកិរិយាបែបនេះ «បានរួមចំណែកដល់ការរំលោភបំពានផ្លូវភេទ និងអំពើហិង្សាលើស្ត្រី»។[189]

មាត្រា ៣៨ និង ៣៩ ដាក់ទោសព្រហ្មទណ្ឌ៖

- ចែកចាយ លក់ ជួល ដាក់តាំង បញ្ចាំង ឬបង្ហាញរូបភាពអាសអាភាសតាមទីសាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ថ្ងៃ ទៅ ១ខែ និងពិន័យជាប្រាក់ពី ១០០,០០០រៀល ទៅ ២០០,០០០រៀល (ប្រហែល ២៥ ទៅ ៥០ ដុល្លារ)
- កាន់កាប់ ដឹកជញ្ជូន នាំចូល ឬនាំចេញរូបភាពអាសអាភាស ក្នុងគោលបំណងប្រើប្រាស់ក្នុងបទល្មើសខាងលើ ដោយផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ថ្ងៃ ទៅ ១ខែ និងពិន័យជាប្រាក់ពី ១០០,០០០រៀល ទៅ ២០០,០០០រៀល (ប្រហែល ២៥ ទៅ ៥០ ដុល្លារ) និង
- ផលិតរូបភាពអាសអាភាសក្នុងគោលបំណងប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើសណាមួយក្នុងកថាខណ្ឌទាំងពីរខាងលើ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយខែដល់មួយឆ្នាំ និងពិន័យជាប្រាក់ពី ២០ម៉ឺនរៀលទៅ ២លានរៀល (ប្រហែល ៥០ ទៅ ៥០០ ដុល្លារ)។[190]

---

[188] *Ibid.*

[189] សារព័ត៌មាន Reuters ‵ ពាក់ឲ្យជិតៗ បើមិនអញ្ចឹងទេត្រូវរងការត្រួតពិនិត្យ៖ ប្រទេសកម្ពុជាបញ្ជាកុំឲ្យស្លៀកពាក់សិចស៊ីនៅក្នុង Facebook′ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ មាននៅ៖ https://www.reuters.com/article/us-cambodia-women-internet-trfn/cover-up-or-be-censored-cambodia-orders-women-not-look-sexy-on-facebook-idUSKBN20D278

[190] មាត្រា ៣៨ និង ៣៩ ច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨ មាននៅ៖ https://sherloc.unodc.org/cld/uploads/res/document/khm/2008/law_on_suppression_of_human_trafficking_and_sexual_exploitation_html/Cambodia_03_-_Law-on-Suppression-of-Human-Trafficking-and-2010-pdf. ។ មាត្រាទី៣៨ កំណត់ ‶រូបអាសអាភាស″ ជា ‶សម្ភារៈដែលអាចមើលឃើញ ដូចជារូបថត ឬវីដេអូ រួមទាំងសម្ភារៈក្នុងទម្រង់អេឡិចត្រូនិក បង្ហាញប្រដាប់បន្តពូជ ឬរូបអាសអាភាសស្រដៀងគ្នាផ្សេងទៀត ដែលធ្វើឲ្យរំភើប ឬជំរុញចំណង់ផ្លូវភេទ។″

មាត្រា ២៤៩ ដាក់ទោសបទឧក្រិដ្ឋ "ការបង្ហាញអាសអាភាសដល់អ្នកដទៃ នៅកន្លែងសាធារណៈ" ដោយផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ថ្ងៃ ទៅ ៣ខែ និងពិន័យជាប្រាក់ពី ១០០,០០០ រៀល ទៅ ៥០០,០០០ រៀល (ប្រហែល ២៥ ទៅ ១២៥ ដុល្លារ) ។[191]

ក្រុមអ្នកជំនាញនៃក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ រួមមាន អ្នករាយការណ៍ពិសេសស្តីពីអំពើហិង្សាលើស្ត្រី សិក្សាយពីមូលហេតុនិងផលវិបាករបស់វា អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា អ្នករាយការណ៍ ពិសេសស្តីពីការលើកកម្ពស់ និងការពារ សិទ្ធិសេរីភាពនៃគំនិត និងការបញ្ចេញមតិ អ្នករាយការណ៍ពិសេស ស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធីនិងសមាគម អ្នករាយការណ៍ពិសេសស្តីពី ស្ថានភាព អ្នកការពារ សិទ្ធិមនុស្ស អ្នកជំនាញឯករាជ្យលើការការពារប្រឆាំងនឹងអំពើហិង្សា និង ការរើសអើងដោយផ្អែកលើនិន្នាការផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ និងក្រុមការងារ ស្តីពីការរើសអើងប្រឆាំងនឹងស្ត្រី និងកុមារី បានសម្តែងការព្រួយបារម្ភថា "ការកំណត់គោលដៅដែលបានរាយការណ៍ និង កំណត់ជ្រើសរើសលើស្ត្រីដែលប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមតំណាងឱ្យការប្រើប្រាស់ខុសជាក់ស្តែងនៃច្បាប់ព្រហ្មទណ្ឌស្តីពីរូបភាពអាសអាភាស និងការកេងប្រវ័ញ្ចផ្លូវភេទនៅក្នុងវិធីដែលលំអៀងខាងយេនឌ័រ ដែលនឹងបណ្តាលឱ្យមានការរើសអើង និងអំពើហិង្សាប្រឆាំងនឹងស្ត្រី"។[192] អ្នកជំនាញបានគូសបញ្ជាក់បន្ថែមថា 'ការភ្ជាប់ទំនាក់ទំនងនៃអំពើហិង្សាផ្លូវភេទ និង ការជួញដូរមនុស្សរបស់អាជ្ញាធរទៅនឹងការជ្រើសរើសសម្លៀកបំពាក់របស់ស្ត្រីគឺផ្ទុយទៅនឹងកាតព្វកិច្ចរបស់ខ្លួន

[191] មាត្រា ២៤៩ ក្រមព្រហ្មទណ្ឌ

[192] AL KHM 2/2020 ទំព័រទី៤

ក្រោមអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី (CEDAW) ដើម្បី លុបបំបាត់ការរើសអើងដែលបង្កគ្រោះថ្នាក់ និងទប់ស្កាត់ ការរើសអើង និងអំពើហិង្សាលើស្ត្រី។[193]

193 *Ibid*

## VI. ការឆ្លើយតបរបស់រដ្ឋចំពោះ កូវីដ-១៩ និង "ព័ត៌មានមិនពិត"

អាជ្ញាធរកម្ពុជាបានប្រើប្រាស់បញ្ហាសុខភាពសាធារណៈជាហេតុផលដើម្បីទប់ស្កាត់ការផ្សព្វផ្សាយព័ត៌មានមិនពិតអំពីជំងឺកូវីដ-១៩ តាមអ៊ីនធឺណិត ហើយ រិតត្បិតសេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិទទួលបានព័ត៌មាន។ អាជ្ញាធរបានដាក់ទណ្ឌកម្ម ឬគំរាមដាក់ទណ្ឌកម្មអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម អ្នកសារព័ត៌មាន និងកម្មវិធីប្រព័ន្ធផ្សព្វផ្សាយ និងបុគ្គលដែលមានទំនាក់ទំនងជាមួយគណបក្សនយោបាយប្រឆាំង ដោយមិនគិតពីបទប្បញ្ញត្តិនៃការមិនរើសអើង នីត្យានុកូលភាព ភាពចាំបាច់ និងសមាមាត្រ។

ការរិតត្បិតាមអំពើចិត្តទាំងនេះត្រូវបានអនុវត្តជាចម្បងដោយអនុលោមតាមបទប្បញ្ញត្តិច្បាប់មួយចំនួននៅក្រោមក្រមព្រហ្មទណ្ឌរួមទាំងមាត្រា៣០៧ (ការប្រមាថជា សាធារណៈ) ៤២៥ (ព័ត៌មានមិនពិត) ៤៣៧*(ស្ទួន) (ប្រមាថអង្គព្រះមហាក្សត្រ)* ៤៥៣ (បទរួមគំនិតក្បត់) និង ៤៩៤ និង ៤៩៥ (ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ ឬរឹករវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម) និងមាត្រា ១១ នៃច្បាប់ការពារជំងឺកូវីដ-១៩ ថ្មី។ គួរកត់សម្គាល់ថានៅក្នុងខែកុម្ភៈ ឆ្នាំ២០២១ អ្នកនាំពាក្យ ក្រសួងយុត្តិធម៌បានប្រកាសថាការផ្សព្វផ្សាយ "ព័ត៌មានមិនពិត" អំពី កូវីដ-១៩ នឹងត្រូវបានចាត់ថ្នាក់ជាការ "ញុះញង់" តាមមាត្រា ៤៩៤ និង៤៩៥ នៃក្រមព្រហ្មទណ្ឌ។[194]

ទោះបីជា ICJ ទទួលស្គាល់ពីភាពចាំបាច់ក្នុងការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃ "ព័ត៌មានមិនពិត" តាមប្រពន្ធ័អ៊ីនធឺណិត ដើម្បីការពារសុខភាពសាធារណៈ និងសិទ្ធិទទួលបានសុខភាពរបស់មនុស្សក្នុងអំឡុងពេលជំងឺរាតត្បាតកូវីដ-១៩ ក៏ដោយ ក៏គោលបំណងនេះ ត្រូវស្របតាមលក្ខខណ្ឌនៃការកំណត់ក្នុងមាត្រា ១៩(៣) នៃ ICCPR អាចត្រូវបានអនុវត្តដោយប្រើមធ្យោបាយមានការជ្រៀតជ្រែកតិចបំផុតជាជាងងាកទៅប្រើវិធានការដែលមិនចាំបាច់ និងមិនសមាមាត្រ ដូចជាការចាប់ខ្លួន ការឃុំខ្លួន ការកាត់ទោសព្រហ្មទណ្ឌ និងការផាកពិន័យច្រើនសន្ធឹកសន្ធាប់។[195] ឧទាហរណ៍ ការឆ្លើយបដិសេធទាន់

---

[194] ការដាក់ស្នើ ICJ OHCHR លើអ្នកសារព័ត៌មាន កថាខណ្ឌទី១១ ក  សារព័ត៌មាន ខ្មែរថាមស៍ 'ការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយអំពីវ៉ាក់សាំង C-19 ចាត់ទុកថាជា 'ការញុះញង់' ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ មាននៅ៖ https://www.khmertimeskh.com/50816839/spreading-fake-news-on-c-19-vaccines-considered-incitement/

[195] ICJ ' អាស៊ីអាគ្នេយ៍៖ រដ្ឋត្រូវគោរព និងការពារសិទ្ធិក្នុងការប្រយុទ្ធប្រឆាំងនឹងព័ត៌មានមិនពិតតាមអ៊ីនធឺណិតទាក់ទងនឹង COVID-19' ថ្ងៃទី១ ខែមេសា ឆ្នាំ២០២០ មាននៅ៖ https://www.icj.org/southeast-asia-states-must-respect-and-protect-rights-in-combating-misinformation-online-relating-to-covid-19/

រង្ស៊ី ត្រូវបានចោទប្រកាន់ម្តងទៀត តាមមាត្រា ៤៣៧ (ស្ទួន) កាលពីខែកញ្ញា ឆ្នាំ២០១៩ ចំពោះការលើកឡើងថា ព្រះមហាក្សត្រជាអាយ៉ងរបស់នាយករដ្ឋមន្ត្រីក្នុងបទសម្ភាសន៍ជាមួយវិទ្យុអាស៊ីសេរី[257] បន្ទាប់មកសាលាដំបូងរាជធានីភ្នំពេញបានចេញដីកាចាប់ខ្លួនដាក់ឃុំមុនជំនុំជម្រះ។[258]

*ការឆ្លើយតបរបស់រដ្ឋាភិបាលកម្ពុជា*

ជាការឆ្លើយតបទៅនឹងការអំពាវនាវរបស់អនុរដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិកឱ្យរដ្ឋាភិបាលកម្ពុជាទម្លាក់ "ការចោទប្រកាន់ដោយចេតនានយោបាយ លើសមាជិក គណបក្សប្រឆាំង អ្នកសារព័ត៌មាន និងសកម្មជន" នៅក្នុងខែមិថុនា ឆ្នាំ២០២១[259] រដ្ឋាភិបាលកម្ពុជាបានការពារថាការត្រួតពិនិត្យលើសំណុំរឿងនេះ គឺស្ថិតនៅក្នុងរង្វង់ សមត្ថកិច្ចរបស់តុលាការ។ រដ្ឋាភិបាលបានអះអាងថា "សង្គមដែលប្រកាន់ខ្ជាប់នូវ លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ តុលាការគឺជាស្ថាប័នឯករាជ្យ ដែលមិនអាចស្តាប់បង្គាប់អ្នក ណាម្នាក់បានទេ"។[260] ការឆ្លើយតបនេះគឺស្រដៀងទៅនឹងការអះអាងពីមុនរបស់ រដ្ឋាភិបាលដែលថា "ការកាត់ទោស និងផ្ទន្ទាទោសជនល្មើសដោយអាជ្ញាធរស្របច្បាប់ ដើម្បីផលប្រយោជន៍ យុត្តិធម៌ មិនគួរត្រូវបានមើលឃើញថាជាការគំរាមកំហែងដល់ លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនោះទេ ប៉ុន្តែជាការអនុវត្តច្បាប់ ... ការប្រកាន់យកច្បាប់មានន័យថាអ្នកប្រព្រឹត្តល្មើសទទួលខុសត្រូវចំពោះការប្រព្រឹត្តរបស់ខ្លួន" ។[261]

ការឆ្លើយតបនេះមិនបានធ្វើឲ្យប្រទេសកម្ពុជារួចពីការ ទទួលខុសត្រូវរបស់ខ្លួនចំពោះការរំលោភសិទ្ធិមនុស្សអន្តរជាតិឡើយ ដោយយោងតាមកាតព្វកិច្ចផ្លូវច្បាប់អន្តរជាតិរបស់ខ្លួន។ កាតព្វកិច្ចសិទ្ធិមនុស្សរបស់រដ្ឋត្រូវតែប្រកាន់ខ្ជាប់គ្រប់វិស័យរបស់រដ្ឋ រួមទាំងប្រព័ន្ធ តុលាការ

---

257 សារព័ត៌មាន ភ្នំពេញប៉ុស្តិ៍ 'លោក សម រង្ស៊ី ត្រូវបានចោទប្រកាន់ពីបទ 'ប្រមាថអង្គព្រះមហាក្សត្រ' ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៩ មាននៅ៖ https://www.phnompenhpost.com/national-politics/rainsy-charged-insulting-king

258 សារព័ត៌មាន ភ្នំពេញប៉ុស្តិ៍ 'ដីកាចាប់ខ្លួន លោកសម រង្ស៊ី ត្រូវបានបញ្ជូនទៅកាន់អាស៊ាន' ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ មាននៅ៖ https://www.phnompenhpost.com/national-politics/rainsy-asean-arrest-warrants-sent

259 ក្រសួងការបរទេសសហរដ្ឋអាមេរិក 'ដំណើរទស្សនកិច្ចរបស់អនុរដ្ឋមន្ត្រីការបរទេស Wendy Sherman មកកាន់ប្រទេសកម្ពុជា' ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២១ មាននៅលើ៖ https://www.state.gov/deputy-secretary-of-state-wendy-shermans-visit-to-cambodia/

260 សារព័ត៌មាន ខ្មែរថាមស៍ 'CPP និយាយថា 'គ្មានអ្នកទោសនយោបាយ' នៅកម្ពុជា' ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២១មាននៅ៖ https://www.khmertimeskh.com/50867226/cpp-says-no-political-prisoners-in-cambodia/

261 ICJ 'កម្ពុជា៖ ការប្រើប្រាស់ច្បាប់ខុសឆ្គងជាបន្តបន្ទាប់ ដើម្បីបំបិទមាត់គូបដិបក្ខ កាន់តែស៊ីជម្រៅថែមទៀតនិទណ្ឌភាព និងធ្វើឱ្យខូចដល់នីតិរដ្ឋ' ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៧ មាននៅ៖ https://www.icj.org/cambodia-ongoing-misuse-of-law-to-silence-opponents-further-deepens-impunity-and-undermines-the-rule-of-law/

សកម្មភាពនេះក៏អាចនឹងបំពានលើកាតព្វកិច្ចរបស់កម្ពុជាក្នុងការការពារសិទ្ធិទទួលបានសុខភាពតាមមាត្រា ១២ នៃ ICESCR។ គណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច វប្បធម៌ និងសង្គម (CESCR) បានគូសបញ្ជាក់អំពីកាតព្វកិច្ច ជាបន្ទាន់ក្នុងការបដិសេធពីការត្រួតពិនិត្យ ដកហូតទុក ឬការបំភាន់ដោយចេតនា នូវព័ត៌មានទាក់ទងនឹងសុខភាព និងការការពារការចូលរួមរបស់ប្រជាជនក្នុងគ្រប់បញ្ហាដែលទាក់ទងនឹងសុខភាព។[198] វិធីសាស្ត្ររបស់ប្រទេសកម្ពុជារហូតមកដល់ពេលនេះបានប្រថុយនឹងការជំរុញបរិយាកាសនៃការត្រួតពិនិត្យខ្លួនឯង ដែលប្រជាជនភ័យខ្លាចក្នុងការចែករំលែកព័ត៌មានសំខាន់ៗ ឬ ការព្រួយបារម្ភអំពីជំងឺកូវីដ-១៩ ដោយភ័យខ្លាចថាត្រូវបានរដ្ឋកំណត់គោលដៅសម្រាប់ការផ្សព្វផ្សាយដោយចោទប្រកាន់ថា "ព័ត៌មានមិនពិត" តាមអ៊ីនធឺណិត។

### *i. ទណ្ឌកម្មឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម*

អាជ្ញាធរបានដាក់ឬគំរាមដាក់ទណ្ឌកម្មឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមមួយចំនួនសម្រាប់សកម្មភាពប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់ពួកគេទាក់ទងនឹងការរាតត្បាតនៃជំងឺកូវីដ-១៩។

គួរកត់សម្គាល់ថា នៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០២១ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានទាមទារឱ្យបញ្ឈប់ជាបន្ទាន់នូវការបង្ហោះតាមប្រព័ន្ធផ្សព្វផ្សាយសង្គមដែលមានគោលបំណង "បង្កចលាចល និងបង្កភាពវឹកវរ" នៅក្នុងបរិបទនៃការរាតត្បាតនៃជំងឺកូវីដ-១៩ ដោយសំដៅទៅលើការបង្ហោះបែបនេះថាជា "សកម្មភាពវាយប្រហារ" ដែលត្រូវតែដាក់ទោស។[199] សេចក្តីប្រកាសព័ត៌មានមិនបានផ្តល់យុត្តិកម្មផ្លូវច្បាប់ណាមួយ សម្រាប់ការរិតត្បិតដែលអាចកើតមានទាំងនេះលើសិទ្ធិសេរីភាពនៃការបញ្ចេញមតិនោះទេ។[200] លើសពីនេះ ក្រសួងព័ត៌មានបានប្រកាសក្នុងខែមករា ឆ្នាំ២០២១ ថាខ្លួនកំពុងត្រួតពិនិត្យយ៉ាងសកម្ម ទាំងកម្មវិធីប្រភពបើកចំហ (Facebook, YouTube, Twitter និង TikTok) និងកម្មវិធីប្រភពបិទ (WhatsApp Telegram និង Messenger) សម្រាប់

---

198 ឯកសារ UN E/C.12/2000/4 កថាខណ្ឌទី៣៥

199 សេចក្តីថ្លែងការណ៍រួមរបស់ ICJ ស្តីពីការអត្ថាធិប្បាយរិះគន់លើ COVID-19។

200 *Ibid*

"ព័ត៌មានមិនពិត" ស្តីពី កូវីដ-១៩ និងវ៉ាក់សាំង ដែលបង្កើនការព្រួយបារម្ភបន្ថែមអំពីសិទ្ធិឯកជនភាពរបស់អ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម។[201]

*ការចាប់ខ្លួន ការឃុំខ្លួន និងការកាត់ទោស*

កាលពីខែមេសា ឆ្នាំ២០២១ អ្នកនាំពាក្យអគ្គស្នងការនគរបាលជាតិបានប្រកាសថា មនុស្សយ៉ាងតិច៣០នាក់ត្រូវបានចាប់ខ្លួន ក្រោមការចោទប្រកាន់ពីបទញុះញង់ រិះគន់ រដ្ឋាភិបាល ចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០២១ ចំពេលមានរលកនៃការឆ្លងជំងឺកូវីដ-១៩ ថ្មីបំផុត នៅក្នុងប្រទេស។[202] កន្លងមក ក្នុងខែមិថុនា ឆ្នាំ២០២០ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស និងអង្គការឃ្លាំមើលសិទ្ធិមនុស្ស ធ្លាប់បានចងក្រងឯកសារថា មនុស្ស៣០នាក់ត្រូវបានចាប់ខ្លួនពីបទបង្ហាញទស្សនៈរបស់ពួកគេលើជំងឺកូវីដ-១៩ ក្នុងនោះ ១៤នាក់ត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។[203] ជាពិសេស **កុយ សំអាត** និង **ឡឹក ស៊ាងលី** ត្រូវបានចាប់ខ្លួន និងចោទប្រកាន់តាមមាត្រា ៤៩៤ និង ៤៩៥ សម្រាប់ ការបង្ហោះនៅលើ Facebook និង TikTok រៀងៗខ្លួន អំពីជំងឺកូវីដ-១៩។[204]

កាលពីខែធ្នូ ឆ្នាំ២០២០ សាលាដំបូងរាជធានីបានចោទប្រកាន់ **នី ណាក់** ចំពោះ "ការប្រមាថជាសាធារណៈ" និង "ការញុះញង់ឱ្យមានការរើសអើង" តាមមាត្រា ៣០៧ ។[205]

---

[201] សារព័ត៌មាន UCA News 'កម្ពុជាពង្រីកការត្រួតពិនិត្យ' ព័ត៌មានក្លែងក្លាយ' ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ មាននៅ៖ https://www.ucanews.com/news/cambodia-expands-monitoring-of-fake-news/91186

[202] វិទ្យុអាស៊ីសេរី ' លោក ហ៊ុន សែន របស់កម្ពុជា ដាក់ទីក្រុងភ្នំពេញ ដាច់ចេញពីតាខ្មៅ បន្ទាប់ពីប្រជាពលរដ្ឋ មិនអើពើនឹងបទបញ្ជាបិទខ្ទប់' ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២១ មាននៅ៖ https://www.rfa.org/english/news/cambodia/lockdown-04162021182510.html ។ ចំនួននេះទំនងជារួមមាន ធន់ រដ្ឋា និងឈុន វៀន ដែលត្រូវបានចាប់ខ្លួនពីបទ "ញុះញង់" ពាក់ព័ន្ធនឹងការអត្ថាធិប្បាយរបស់ពួកគេអំពីវ៉ាក់សាំង COVID-19 ។ សូមមើល សារព័ត៌មាន VOD 'ការស្លាប់ពីរនាក់ត្រូវបានកំណត់ថាមិនទាក់ទងនឹងវ៉ាក់សាំង Covid ចាប់ខ្លួនពីរនាក់ចំពោះការបង្ហោះ' មាននៅ ៖ https://vodenglish.news/two-deaths-ruled-unrelated-to-vaccine-covid-two-arrested-over-posts/

[203] ការដាក់ស្នើ ICJ OHCHR ស្តីអំពីអ្នកសារព័ត៌មាន កថាខណ្ឌទី១០ក OHCHR 'Asia: Bachelet ព្រួយបារម្ភដោយការគៀបសង្កត់លើសេរីភាពនៃការបញ្ចេញមតិក្នុងអំឡុងពេល COVID-19' ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២០មាននៅ៖ https://www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=25920 អង្គការឃ្លាំមើលសិទ្ធិមនុស្ស, 'បញ្ជីការចាប់ខ្លួន និងអ្នកនៅក្នុងឃុំឃាំងសម្រាប់បទល្មើសពាក់ព័ន្ធ COVID-19' ថ្ងៃទី២៣ខែមីនា ឆ្នាំ២០២០ ('បញ្ជីការចាប់ខ្លួន និងការឃុំខ្លួនរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស') មាននៅ៖ https://www.hrw.org/video-photos/interactive/2020/03/23/list-arrests-and-persons-detention-covid-19-related-offenses

[204] បញ្ជីការចាប់ខ្លួន និងការឃុំខ្លួនរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស។

[205] មាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌចែងថា "គ្រប់ពាក្យប្រមាថ គ្រប់ពាក្យមើលងាយ ឬគ្រប់ពាក្យទ្រគោះដែលគ្មានការទំលាក់កំហុសទៅលើអំពើណាមួយគឺជាការប្រមាថ ។ បទជេរប្រមាថដែលប្រព្រឹត្តឡើងតាមមធ្យោបាយណាមួយដូចតទៅត្រូវពិន័យជាប្រាក់ពីមួយសែនរៀនទៅដប់លានរៀល ៖ (១)តាមពាក្យសំដីទោះជាប្រភេទណាក៏ដោយដែលបញ្ចេញនៅទីសាធារណៈ ឬនៅពេលប្រជុំ

៤៩៤ និង ៤៩៦[206] នៃក្រមព្រហ្មទណ្ឌ។[207] ការចោទប្រកាន់នេះកើតចេញពីការបង្ហោះតាមហ្វេសប៊ុកដែលលោកបានចោទថាបានចំអកការចែកម៉ាស់របស់រដ្ឋាភិបាល និងលិខិតរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្វាយព្រះមហាក្សត្រអំពីការប្រកាសដាក់ប្រទេសក្នុងភាពអាសន្ន។[208] ការបង្ហោះនេះត្រូវបានគេចោទថាបានប្រមាថលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយប្រយោល។[209] ការចោទប្រកាន់ទាំងនេះពីបទ «ប្រមាថ» លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបំពានលើកាតព្វកិច្ចសិទ្ធិមនុស្សរបស់កម្ពុជា ខណៈ ដែលគណៈកម្មាធិការសិទ្ធិមនុស្សបានសង្កត់ធ្ងន់ថា «ការពិតដែលទម្រង់នៃការបញ្ចេញមតិ ត្រូវបានចាត់ទុកថាជាការប្រមាថដល់បុគ្គលសាធារណៈ គឺមិនគ្រប់គ្រាន់ដើម្បីបង្ហាញ អំពី ភាពត្រឹមត្រូវនៃការដាក់ទោសទេ" ក្នុងនាមជាប្រមុខរដ្ឋ និងរដ្ឋាភិបាល "ជាកម្មវត្ថុស្របច្បាប់ចំពោះការរិះគន់ និងការប្រឆាំងនយោបាយ"។[210]

នៅខែមេសា ឆ្នាំ២០២១ **គង់ សម្បត្តិ នូវ ក្លឹម** និង **ផាន់ សុភី** ត្រូវបានចាប់ខ្លួន និងចោទប្រកាន់តាមមាត្រា ១១ នៃច្បាប់ការពារជំងឺ កូវីដ-១៩ ដែលមិនច្បាស់លាស់ និងទូលំទូលាយ ពីបទរារាំងការអនុវត្តវិធានការ កូវីដ-១៩ ទាក់ទងនឹងវីដេអូ TikTok ដែលពួកគេបាន បញ្ចេញទស្សនៈរបស់ពួកគេលើយុទ្ធនាការចាក់វ៉ាក់សាំង កូវីដ-១៩ របស់រដ្ឋាភិបាល។[211]

---

សាធារណៈ (២) តាមលិខិត ឬគំនូរ ទោះជាប្រភេទណាក៏ដោយដែលផ្សព្វផ្សាយនៅក្នុងចំណោមសាធារណៈជន ឬដាក់តាំងឲ្យសាធារណៈជនមើល (៣) តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់សាធារណជន ។

[206] មាត្រា ៤៩៦ នៃក្រមព្រហ្មទណ្ឌចែងថា៖ « អំពើញុះញង់ដោយផ្ទាល់ដោយមធ្យោបាយណាមួយដែលមានចែងក្នុងមាត្រា ៤៩៤ (លក្ខខណ្ឌអត្ថិភាពនៃការញុះញង់) នៃក្រមនេះ ឲ្យប្រព្រឹត្តការរើសអើង ការគុំកួន ឬហិង្សាចំពោះបុគ្គលណាម្នាក់ ឬក្រុមណាមួយដោយមូលហេតុបុគ្គលនេះ ជាសមាជិក ឬមិនមែនជាសមាជិកនៃជាតិពន្ធ ក្រុមជាតិ ពូជសាសន៍ ឬនៃសាសនាណាមួយជាក់លាក់ណាត់នោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ពីរលាន ទៅប្រាំមួយលានរៀល ប្រសិនបើការញុះញង់នេះគ្មានប្រសិទ្ធភាពទេ »។

[207] សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ' សាលាដំបូងរាជធានីភ្នំពេញ ចោទប្រកាន់បុរសម្នាក់ ពីបទ 'ចំអក' នាយករដ្ឋមន្ត្រី ក្នុងហ្វេសប៊ុក' ថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ២០២០ មាននៅ៖ https://www.phnompenhpost.com/national/capital-court-charges-man-over-mocking-pm-facebook-post

[208] *Ibid*

[209] *Ibid*

[210] ឯកសារ UN CCPR/C/GC/34 កថាខណ្ឌទី៣៨

[211] CamboJA News 'អ្នកប្រើប្រាស់ TikTok ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទផ្សព្វផ្សាយព័ត៌មានក្លែងក្លាយអំពីវ៉ាក់សាំង COVID-19' ថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ មាននៅ៖ https://cambojanews.com/tiktok-users-arrested-and-charged-with-spreading-fake-news-about-covid-19-vaccines/ សេចក្តីថ្លែងការណ៍រួមរបស់ ICJ ស្តីពីការអត្ថាធិប្បាយរិះគន់លើ COVID-19។

*ការចុះហត្ថលេខាលើការសន្យាមិនផ្សព្វផ្សាយ "ព័ត៌មានមិនពិត"*

អាជ្ញាធរកម្ពុជាក៏បានដាក់សម្ពាធជាប្រចាំដល់បុគ្គលឲ្យចុះហត្ថលេខាលើការសន្យាមិនឲ្យបង្ហោះខ្លឹមសារមិនពេញចិត្តនៅលើបណ្ដាញសង្គម ។ ការសន្យាទាំងនេះសំដៅទៅលើការគំរាមកំហែងនៃទណ្ឌកម្មផ្លូវច្បាប់ និង ការជ្រៀតជ្រែកហួសហេតុចំពោះសេរីភាពនៃការបញ្ចេញមតិ ប្រសិនបើអនុលោមតាមទេ ទំនងនឹងនាំឱ្យមានការពិន័យព្រហ្មទណ្ឌដែលមិនសមស្របនឹងគោលការណ៍នៃភាពចាំបាច់ និងសមាមាត្រ។

នៅក្នុងខែមីនា ឆ្នាំ២០២០ អង្គការឃ្លាំមើលសិទ្ធិមនុស្សបានចងក្រងឯកសារ ករណីបុគ្គលចំនួន១៤នាក់ដែលត្រូវបានចាប់ខ្លួន ផ្ដល់ការព្រមានជាផ្លូវការ ហើយក្រោយមកត្រូវបានដោះលែង នៅពេលចុះហត្ថលេខាលើការសន្យា "ដើម្បីបញ្ឈប់ការផ្សព្វផ្សាយដែលត្រូវបានរដ្ឋាភិបាលចាត់ទុកថាជា "ព័ត៌មានក្លែងក្លាយ" ស្ដីអំពីជំងឺ កូវីដ-១៩ នៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម។[212] មនុស្សទាំង ១៤នាក់ នេះរួមមាន **ម៉ែន ចាន់នឿន អឿង ជីង សិរីរតនៈ ជុង ចេន ស្វាយ ស្រីមុំ កាន់ សុភ័ក្រ្ត ម៉ុត សាមៀន ទេព ផល្លា ថៃ ឆ័រយឿន ជួង ភារម្យ ង៉ៅ ការតុង ម៉ៅ សុខា អឿន សំអាត** និង **ជឿន ដា** ។[213] ក្មេងស្រីអាយុ១៤ឆ្នាំម្នាក់ក៏ត្រូវបានចាប់ខ្លួន និងដោះលែងវិញផងដែរ បន្ទាប់ពីធ្វើការសុំទោសជាសាធារណៈចំពោះការបង្ហោះនៅលើ Facebook ថាសិស្សបីនាក់នៅសាលាភាសាចិនរបស់នាងបានឆ្លងជំងឺកូវីដ-១៩ ។[214]

និន្នាការនេះបានបន្តចំពេលរលកថ្មីបំផុតនៃការឆ្លង ជំងឺកូវីដ-១៩ នៅក្នុងប្រទេស។ ឧទាហរណ៍នៅក្នុងខែឧសភា ឆ្នាំ២០២១ ត្រូវបានគេរាយការណ៍ថា **តែ សុង** កសិករម្នាក់ដែលបានបង្ហោះរូបថតនៅលើ Facebook នៃការបំផ្លាញបន្លែជាលទ្ធផលនៃការបិទផ្សារក្នុងអំឡុងពេលបិទខ្ទប់នោះ ត្រូវបានបង្ខំឲ្យ "ចុះកិច្ចសន្យាថាគាត់នឹងបញ្ឈប់" ដោយផ្អែកលើមូលដ្ឋានថារូបថតអាច "ញុះញង់ឱ្យមានការរើសអើង"[215] សន្ទត់តាមមាត្រា ៤៩៦

[212] បញ្ជីរាយនាមការចាប់ខ្លួន និងការឃុំខ្លួនរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស។

[213] *Ibid*

[214] *Ibid*

[215] យោងតាមប្រភពព័ត៌មាន លិខិតនោះបានបញ្ជាក់ថា កសិករ "ត្រូវផ្ដល់ព័ត៌មានដល់អាជ្ញាធរមូលដ្ឋានជាមុនសិន មិនត្រូវផ្សព្វផ្សាយជាសាធារណៈ" ដើម្បី "ជៀសវាងការចែករំលែកព័ត៌មានមិនពេញលេញ បំភ័ន្តសាធារណជន និងធ្វើឱ្យប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងរបស់មន្ត្រី"។ សារព័ត៌មាន VOD 'អាជ្ញាធរខេត្តកណ្ដាលព្រមានកសិករកុំបង្ហោះរូបភាពអវិជ្ជមាន' ថ្ងៃទី៤ ខែឧសភា

នៃក្រមព្រហ្មទណ្ឌ ។ វាមិនច្បាស់ទេពីសេចក្ដីថ្លែងការណ៍អំពីរបៀបដែលរូបថតនៃការបំផ្លាញបន្លែទាំងនេះនឹង "ញុះញង់ឱ្យមានការរើសអើង" ឬ ប្រឆាំងនឹងអ្នកដែលពួកគេនឹង "ញុះញង់ឱ្យមានការរើសអើង" ។

## *ii. ការបង្ក្រាបលើអ្នកសារព័ត៌មាន និងវេទិកាសារព័ត៌មាន*

អាជ្ញាធរក៏បានកំណត់គោលដៅលើអ្នកសារព័ត៌មានយ៉ាងហោចណាស់បួននាក់ជាមួយនឹងទណ្ឌកម្មមិនសមាមាត្រ និងមិនចាំបាច់ ឬការគំរាមកំហែងនៃទណ្ឌកម្មទាំងនេះសម្រាប់ការបំពេញមុខងាររាយការណ៍វិជ្ជាជីវៈរបស់ពួកគេទាក់ទងនឹងជំងឺរាតត្បាតកូវីដ-១៩។ ការរិតត្បិតតាមអំពើចិត្តទាំងនេះធ្វើឱ្យខូចដល់តួនាទីដ៏សំខាន់នៃប្រព័ន្ធផ្សព្វផ្សាយក្នុងការត្រួតពិនិត្យប្រតិបត្តិការ និងសម្របសម្រួលគណនេយ្យភាពនៅក្នុងប្រព័ន្ធសុខាភិបាល។[216] ទំនួលខុសត្រូវនេះគឺមានសារៈសំខាន់ជាពិសេសក្នុងអំឡុងពេលជំងឺរាតត្បាត[217] ជាប្រព័ន្ធផ្សព្វផ្សាយដោយសេរី និងឯករាជ្យអាចជួយកំណត់អត្តសញ្ញាណចំណុចក្ដៅ ឬផ្ទុះមេរោគតាមដានការឆ្លើយតបជាតិ និងអន្តរជាតិ និងលើកកម្ពស់តម្លាភាព និងគណនេយ្យភាពក្នុងការផ្ដល់សេវាសុខភាពសាធារណៈចាំបាច់។[218]

---

ឆ្នាំ២០២០ មាននៅ៖ https://vodenglish.news/kandal-authorities-warn-farmers-to-not-upload-negative-pictures/ ; សេចក្ដីថ្លែងការណ៍រួមរបស់ ICJ ស្ដីពីការអត្ថាធិប្បាយរិះគន់លើ COVID-19។

[216] *របាយការណ៍របស់អ្នករាយការណ៍ពិសេស ស្ដីពីសិទ្ធិរបស់មនុស្សគ្រប់រូប ដើម្បីទទួលបានការរីករាយជាមួយនឹងស្តង់ដារសុខភាពផ្លូវកាយ និងផ្លូវចិត្តខ្ពស់បំផុតដែលអាចសម្រេចបាន* ឯកសារ UN. A/63/263 ថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៨ កថាខណ្ឌទី១១

[217] OHCHR ' Bachelet មានការភ័យព្រួយដោយការបង្ក្រាបប្រព័ន្ធផ្សព្វផ្សាយ ដោយនិយាយថាសាធារណៈជនមានសិទ្ធិដឹងអំពី COVID-19' ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០ មាននៅ៖ https://www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=25823&LangID=E

[218] សេចក្ដីថ្លែងការណ៍រួមរបស់ ICJ ស្ដីពីការអត្ថាធិប្បាយរិះគន់លើ COVID-19។

*ការដាក់ទោសអ្នកសារព័ត៌មានចំពោះការរាយការណ៍អំពីជំងឺរាតត្បាត*

នៅថ្ងៃទី៥ ខែតុលា ឆ្នាំ២០២០ **សុវណ្ណ រិទ្ធី** អគ្គនាយកទូរទស្សន៍ អ៊ិនទ្បាញ TVFB ត្រូវបានតុលាការកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេល១៨ខែ តាមមាត្រា៤៩៤ និងមាត្រា៤៩៥ ពីបទរាយការណ៍តាមការណែនាំពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ថាអ្នករត់ម៉ូតូឌុបលក់ម៉ូតូ ប្រសិនបើពួកគេជួបការលំបាកផ្នែកហិរញ្ញវត្ថុ។[219] ក្រសួងព័ត៌មានក៏បានដកហូតអាជ្ញាប័ណ្ណប្រព័ន្ធផ្សព្វផ្សាយរបស់ TVFB ផងដែរ។[220] នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២០ **រស់ សុខេត** អ្នកបោះពុម្ពផ្សាយកាសែតជាតិខ្មែរ ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគាររយៈពេល១៨ខែ តាមមាត្រា៤៩៤ និង៤៩៥ ចំពោះការបង្ហោះតាមហ្វេសប៊ុករបស់លោកដែលរិះគន់ការឆ្លើយតបរបស់រដ្ឋាភិបាលចំពោះជំងឺរាតត្បាត។[221]

ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ **សេន កៃដុង** និពន្ធនាយកនៃសារព័ត៌មានចិន Angkor Today ត្រូវបានចាប់ខ្លួន និងនិរទេសទៅប្រទេសចិន បន្ទាប់ពីលោកបានចោទប្រកាន់ថា "ផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ" និង "បង្កភាពចលាចលក្នុងសង្គម" សម្រាប់ការរាយការណ៍ថា ជនជាតិចិននៅកម្ពុជាត្រូវបានផ្តល់ឱកាសឲ្យទិញការចាក់វ៉ាក់សាំង កូវីដ-១៩ ។ ក្រសួងព័ត៌មានក៏បានដកអាជ្ញាប័ណ្ណ Angkor Today ដែលធ្វើប្រតិបត្តិការក្នុងប្រទេស។[222]

កាលពីថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២១ ក្រសួងព័ត៌មានបានចេញលិខិតព្រមានអ្នកសារព័ត៌មាន កុំឱ្យផ្សព្វផ្សាយព័ត៌មានដែលអាច "បង្កចលាចលក្នុងសង្គម" និងគំរាមចាត់

---

[219] ការដាក់ស្នើ ICJ OHCHR លើអ្នកសារព័ត៌មាន កថាខណ្ឌទី៩ក សារព័ត៌មាន CamboJA News 'អ្នកកាសែត ត្រូវបានកាត់ទោស១៨ខែ ពីបទញុះញង់' ថ្ងៃទី៥ ខែតុលា ឆ្នាំ២០២០ មាននៅ៖ https://cambojanews.com/journalist-handed-18-month-sentence-for-incitement/

[220] ការដាក់ស្នើ ICJ OHCHR លើអ្នកសារព័ត៌មាន កថាខណ្ឌទី៩ក សារព័ត៌មាន ASEAN Today 'កម្ពុជាពង្រីកការត្រួតពិនិត្យប្រព័ន្ធផ្សព្វផ្សាយ សង្គមដល់កម្មវិធីផ្ញើសារឯកជនដោយដកស្រង់ព័ត៌មានក្លែងក្លាយ' ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ មាននៅ៖ https://www.aseantoday.com/2021/02/cambodia-expands-monitoring-of-social-media-to-private-messaging-apps-citing-fake-news/

[221] ការដាក់ស្នើ ICJ OHCHR លើអ្នកសារព័ត៌មាន កថាខណ្ឌទី៩ក សេចក្តីថ្លែងការណ៍រួម ICJ ស្តីពីការអត្ថាធិប្បាយរិះគន់លើ COVID-19; CPJ 'កម្ពុជាដាក់គុកអ្នកកាសែត រស់ សុខេត ពីបទរិះគន់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន' ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២០ មាននៅ៖ https://cpj.org/2020/11/cambodia-jails-journalist-ros-sokhet-for-criticizing-prime-minister-hun-sen/

[222] ការដាក់ស្នើ ICJ OHCHR លើអ្នកសារព័ត៌មាន កថាខណ្ឌទី៩ក សារព័ត៌មាន CPJ 'កម្ពុជាបាននិរទេសអ្នកកាសែតចិន Shen Kaidong ចំពោះ 'ព័ត៌មានក្លែងក្លាយ' ស្តីពីការលក់វ៉ាក់សាំង COVID-19' ថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១មាននៅ៖ https://cpj.org/2021/03/cambodia-deports-chinese-journalist-shen-kaidong-for-fake-news-on-covid-19-vaccine-sales/

វិធានការផ្លូវច្បាប់ចំពោះអ្នកដែលមិនគោរពតាម។[223] លិខិតនេះបានធ្វើឡើង បន្ទាប់ពីវីដេអូផ្សាយផ្ទាល់ពីបណ្តាញព័ត៌មាន Facebook ជាច្រើន ចំពោះការតម្រង់ជួរដ៏វែងរបស់អ្នកជំងឺ កូវីដ-១៩ នៅខាងក្រៅមណ្ឌលព្យាបាលរបស់រដ្ឋាភិបាល។[224]

នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ **កៅ ពិសិដ្ឋ** អ្នកឆ្លើយឆ្លងព័ត៌មានរបស់គេហទំព័រព័ត៌មាន Siem Reap Tannhektar ត្រូវបានចាប់ខ្លួន។[225] ក្រោយមកគាត់ត្រូវបានដាក់ឱ្យឃុំខ្លួនបណ្តោះអាសន្ន និងត្រូវបានចោទប្រកាន់ពីបទ "ញុះញង់" តាមមាត្រា ៤៩៤ និង ៤៩៥ ក៏ដូចជា "រារាំងវិធានការអនុវត្តច្បាប់" តាមមាត្រា ១១ នៃច្បាប់ទប់ស្កាត់ជំងឺកូវីដ-១៩។[226] លោកត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងការបង្ហោះតាមហ្វេសប៊ុករបស់លោកនៅថ្ងៃទី ២៧ ខែមិថុនា ដោយរិះគន់ការសម្រេចចិត្តរបស់រដ្ឋាភិបាល ក្នុងការប្រើប្រាស់វ៉ាក់សាំង Sinopharm និង Sinovac។[227]

### *ការដកហូតអាជ្ញាប័ណ្ណប្រព័ន្ធផ្សព្វផ្សាយ*

អាជ្ញាធរកម្ពុជាក៏បានដកអាជ្ញាប័ណ្ណប្រព័ន្ធផ្សព្វផ្សាយរបស់ប្រព័ន្ធផ្សព្វផ្សាយយ៉ាងហោចណាស់ចំនួនប្រាំផងដែរសម្រាប់ការរាយការណ៍អំពីជំងឺរាតត្បាតកូវីដ-១៩[228] ជាញឹកញាប់រួមជាមួយនឹងការប្រើទណ្ឌកម្មព្រហ្មទណ្ឌប្រឆាំងនឹងអ្នកយកព័ត៌មានដែលជាប់ពាក់ព័ន្ធនឹងបណ្តាញព័ត៌មានទាំងនេះ។ បណ្តាញព័ត៌មានជាច្រើនទាំងនេះដំណើរការលើអ៊ីនធឺណិតជាជាងបោះពុម្ពផ្សព្វផ្សាយ។

---

[223] សេចក្តីថ្លែងការណ៍រួម ICJ ស្តីពីការអត្ថាធិប្បាយរិះគន់លើ COVID-19 សារព័ត៌មាន CamboJA News 'ក្រសួងព័ត៌មានព្រមានអ្នកសារព័ត៌មាន កុំឲ្យមានការដេញតាមរថយន្តសង្គ្រោះបន្ទាន់' បន្ទាប់ពីវីដេអូនៃការរង់ចាំយូរសម្រាប់អ្នកជំងឺ COVID-19 ផ្ទុះល្បីខ្លាំង' ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២១ មាននៅ៖ https://cambojanews.com/information-ministry-warns-journalists-against-ambulance-chasing-after-video-of-long-waits-for-covid-19-patients-goes-viral/

[224] *Ibid*

[225] អង្គការអ្នកកាសែតគ្មានព្រំដែន 'អ្នកយកព័ត៌មានកម្ពុជាប្រឈមមុខនឹងការជាប់ពន្ធនាគាររយៈពេលប្រាំឆ្នាំសម្រាប់ការអត្ថាធិប្បាយអំពីវ៉ាក់សាំង' ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ មាននៅ៖ https://rsf.org/en/news/cambodian-reporter-facing-five-years-prison-comment-about-vaccines

[226] *Ibid*

[227] *Ibid*

[228] សារព័ត៌មាន CamboJA News 'ទីប្រឹក្សាក្រសួងព័ត៌មានត្រូវបានដកហូតតំណែង និងអាជ្ញាប័ណ្ណផ្សាយព័ត៌មាន' ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ មាននៅ៖ https://cambojanews.com/information-ministry-advisor-stripped-of-position-news-outlet-license/

នៅខែមីនា ឆ្នាំ២០២១ សារព័ត៌មាន San Prum News និង **សមាគមអ្នកសារព័ត៌មានកម្ពុជា** ត្រូវបានដកហូតអាជ្ញាប័ណ្ណដោយក្រសួងព័ត៌មាន បន្ទាប់ពី **ព្រំ សាន** ដែលជាម្ចាស់បានបង្ហោះរូបភាពដែលគេចោទថាបំភាន់បង្ហាញថាបុគ្គលម្នាក់បានស្លាប់ដោយសារ កូវីដ-១៩ នៅលើទំព័រហ្វេសប៊ុកផ្ទាល់ខ្លួនរបស់គាត់។ មានសេចក្ដីរាយការណ៍ថារូបភាពនោះត្រូវបានដកចេញក្នុងរយៈពេល ១០នាទី បន្ទាប់ពីលោក ព្រំ សាន ដឹងថា រូបភាព និងអត្ថបទនេះមិនត្រឹមត្រូវ។[229] លោក ព្រំ សាន ដែលជាទីប្រឹក្សាក្រសួងព័ត៌មាន ក៏ត្រូវបានបណ្ដេញចេញពីតំណែងក្នុងក្រសួងដែរ។[230] សារព័ត៌មាន TVFB និង Angkor Today ក៏ត្រូវបានដកហូតអាជ្ញាប័ណ្ណប្រព័ន្ធផ្សព្វផ្សាយរបស់ពួកគេផងដែរ បន្ទាប់ពី សុវណ្ណ រិទ្ធី និង សេន កៃដុង ត្រូវបានដាក់ពិន័យសម្រាប់ការរាយការណ៍អំពីជំងឺកូវីដ-១៩។[231]

*ការរិតត្បិតផ្សេងទៀតលើការរាយការណ៍ឯករាជ្យ*

នៅខែឧសភា ឆ្នាំ២០២១ អាជ្ញាធរកម្ពុជាបានដាក់ ការហាមប្រាមជាក់ស្ដែងលើការរាយការណ៍ឯករាជ្យនៅក្នុង "តំបន់ក្រហម"របស់ទីក្រុងភ្នំពេញ—តំបន់ដែលត្រូវបានគេចាត់ទុកថាមានហានិភ័យខ្ពស់ចំពោះការឆ្លងជំងឺកូវីដ-១៩។ នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២១ ក្រសួងព័ត៌មានបានប្រកាសថាមានតែប្រព័ន្ធផ្សព្វផ្សាយរដ្ឋឬអ្នកសារព័ត៌មានដែលត្រូវបានអញ្ជើញដោយរដ្ឋាភិបាលប៉ុណ្ណោះ ត្រូវបានអនុញ្ញាតឱ្យរាយការណ៍ ពីតំបន់ ក្រហម។[232] គណៈកម្មាធិការសិទ្ធិមនុស្សបានបញ្ជាក់យ៉ាងច្បាស់ថា ជាធម្មតាវាមិនស្របគ្នានឹងមាត្រា ១៩(៣) នៃ ICCPR ក្នុងការ "រិតត្បិតសេរីភាពនៃចលនារបស់អ្នកសារព័ត៌មាននិងអ្នកស៊ើបអង្កេតសិទ្ធិមនុស្សនៅក្នុងរដ្ឋ[ដែនដី]"ទេ។[233] បើទោះជាអាជ្ញាធរកម្ពុជាបានផ្ដល់

---

229 *Ibid*

230 *Ibid*

231 ការដាក់ស្នើ ICJ OHCHR លើអ្នកសារព័ត៌មាន កថាខណ្ឌទី៩ក សារព័ត៌មាន ASEAN Today 'កម្ពុជាពង្រីកការត្រួតពិនិត្យប្រព័ន្ធផ្សព្វផ្សាយសង្គមដល់កម្មវិធីផ្ញើសារឯកជនដោយទាញហេតុផល ព័ត៌មានក្លែងក្លាយ' ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ ២០២១ មាននៅ៖ https://www.aseantoday.com/2021/02/cambodia-expands-monitoring-of-social-media-to-private-messaging-apps-citing-fake-news/ ។ សារព័ត៌មាន CPJ 'កម្ពុជាបាននិរទេសអ្នកកាសែតចិន Shen Kaidong ចំពោះ 'ព័ត៌មានក្លែងក្លាយ' ស្ដីពីការលក់វ៉ាក់សាំង COVID-19' ថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១មាននៅ៖ https://cpj.org/2021/03/cambodia-deports-chinese-journalist-shen-kaidong-for-fake-news-on-covid-19-vaccine-sales/

232 សេចក្ដីថ្លែងការណ៍រួម ICJ ស្ដីពីការអត្ថាធិប្បាយរិះគន់លើ COVID-19 សារព័ត៌មាន VOD 'ការរាយការណ៍ព័ត៌មានតំបន់ក្រហមគឺសម្រាប់អ្នកដែលត្រូវបានអញ្ជើញតែប៉ុណ្ណោះ ៖ ក្រសួងព័ត៌មាន' ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២១ មាននៅ៖ https://vodenglish.news/red-zone-news-reporting-is-invite-only-information-ministry/

233 ឯកសារ UN CCPR/C/GC/34 កថាខណ្ឌទី៤៥

ហេតុផលត្រឹមត្រូវ លើមូលដ្ឋាននៃ "សុខភាពសាធារណៈ" ក៏ដោយ ។[234] ការពិត ដែលថា "[មានតែ] អ្នកសារព័ត៌មានដែលធ្វើការឱ្យប្រព័ន្ធផ្សព្វផ្សាយរដ្ឋ ឬក្រោមក្រសួងព័ត៌មានប៉ុណ្ណោះ នឹងទទួលបានការអនុញ្ញាតឱ្យចូលទៅក្នុងតំបន់ក្រហម"[235] ណែនាំថា ការរិតត្បិតទាំងនេះកំពុងត្រូវបានអនុវត្តក្នុងលក្ខណៈរើសអើងដែលធ្វើឲ្យប្រព័ន្ធផ្សព្វផ្សាយឯកជន និងឯករាជ្យ "ចាញ់ប្រៀបបើធៀបទៅនឹងប្រព័ន្ធផ្សព្វផ្សាយ សាធារណៈក្នុងបញ្ហាដូចជាការទទួលបានមធ្យោបាយផ្សព្វផ្សាយ/ការចែកចាយ និងការទទួលបានព័ត៌មាន"។[236]

### *iii. ការកំណត់គោលដៅបុគ្គលដែលមានទំនាក់ទំនងជាមួយគណបក្សនយោបាយប្រឆាំង*

អាជ្ញាធរកម្ពុជាមានប្រវត្តិយូរអង្វែងក្នុងការគាបសង្កត់អ្នកប្រឆាំងនយោបាយតាមរយៈការប្រើអាវុធដ៏មានប្រសិទ្ធភាពនៃច្បាប់មិនគោរពសិទ្ធិមនុស្សប្រឆាំងនឹងពួកគេ។[237] ស្ថានភាពនេះកាន់តែអាក្រក់ទៅៗក្នុងអំឡុងការរាតត្បាតនៃជំងឺកូវីដ-១៩ ដោយសារអាជ្ញាធរ តែងតែចាប់ខ្លួន ឃាត់ខ្លួន និងចោទប្រកាន់អ្នកប្រឆាំងនយោបាយតាមមាត្រា ៤២៥ ៤៣៧(ស្ទួន) ៤៥៣ ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌសម្រាប់ការបញ្ចេញមតិតាមអ៊ីនធឺណិតរបស់ពួកគេ។

*មាត្រា ៤២៥ (ព័ត៌មានមិនពិត) ៤៥៣ (ការរួមគំនិតក្បត់) និង ៤៩៤ និង ៤៩៥ (ការញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ ឬ បង្កឲ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម)*

កាលពីខែមិថុនា ឆ្នាំ២០២០ អង្គការឃ្លាំមើលសិទ្ធិមនុស្សបានរាយការណ៍ពីការចាប់ខ្លួនបុគ្គលចំនួន១២នាក់ ដែលមានទំនាក់ទំនងជាមួយគណបក្សសង្គ្រោះជាតិ ចាប់តាំងពីខែ

---

[234] សារព័ត៌មាន VOD 'ការរាយការណ៍ព័ត៌មានតំបន់ក្រហមគឺសម្រាប់អ្នកដែលត្រូវបានអញ្ជើញតែប៉ុណ្ណោះ ៖ ក្រសួងព័ត៌មាន' ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២១មាននៅ៖ https://vodenglish.news/red-zone-news-reporting-is-invite-only-information-ministry/

[235] *Ibid*

[236] CCPR/C/GC/34 កថាខណ្ឌទី៤១

[237] *អាណត្តិរបស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា និងអ្នករាយការណ៍ពិសេសស្តីពីការលើកកម្ពស់ និងការពារសិទ្ធិសេរីភាពនៃគំនិត និងការបញ្ចេញមតិ* ឯកសារយោង៖ AL KHM 1/2019 ថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩ មាននៅ៖ https://spcommreports.ohchr.org/TMResultsBase/DownLoadPublicCommunicationFile?gId=24531 អង្គការឃ្លាំមើលសិទ្ធិមនុស្ស 'អ្នកទោសនយោបាយកម្ពុជា' ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២០ មាននៅ៖ https://www.hrw.org/video-photos/interactive/2020/01/24/political-prisoners-cambodia ICJ 'កម្ពុជា៖ ការប្រើប្រាស់ច្បាប់ខុសជាបន្តបន្ទាប់ដើម្បីបំបិទមាត់គូបដិបក្ខ កាន់តែស៊ីជម្រៅថែមទៀត និទណ្ឌភាព និងធ្វើឱ្យខូចដល់នីតិរដ្ឋ' ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៧ មាននៅ៖ https://www.icj.org/cambodia-ongoing-misuse-of-law-to-silence-opponents-further-deepens-impunity-and-undermines-the-rule-of-law/

មករា ឆ្នាំ២០២០។[238] ក្នុងចំណោមការចាប់ខ្លួនទាំង ១២នាក់នេះ យ៉ាងហោចណាស់ ៧ នាក់ទំនងជាពាក់ព័ន្ធនឹងការបង្ហោះតាមប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់ពួកគេអំពី COVID-19 ។[239] ប្រាំមួយនាក់ត្រូវបានចោទប្រកាន់ក្រោមមាត្រា ៤៩៣ ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌដែលមានលក្ខណៈទូលំទូលាយពេក និង មិនច្បាស់លាស់រួមមាន **យុត ជឿក ងិន យៀន កែវ ថៃ សាត ស្រស់ យឹម សារ៉េត** និង **ហ៊ីន ចាន់** ។[240]

អ្នកចុងក្រោយក្នុងចំណោមអ្នកចាប់ខ្លួន៧នាក់នោះគឺ **ពុទ្ធ ថុនា ឡុន** ដែលត្រូវបានគេស្គាល់ថាជាឈ្មោះ ឡុន លី ដែលក្រោយមកត្រូវបានសាលាដំបូងខេត្តសៀមរាប ចោទប្រកាន់តាមមាត្រា ៤២៥ នៃក្រមព្រហ្មទណ្ឌ ពីបទផ្សាយព័ត៌មានមិនពិត។[241] លោកបានបង្ហោះវីដេអូចំនួនពីរនៅលើគណនីហ្វេសប៊ុករបស់លោក ដោយចោទសួរថា តើរដ្ឋាភិបាលកម្ពុជាត្រូវការជំនួយពីរដ្ឋាភិបាលវៀតណាម ដើម្បីដឹងអំពីការមកដល់ ប្រទេសកម្ពុជា ដែលក្រោយមកបានធ្វើតេស្តមានវិជ្ជមាន ជំងឺកូវីដ-១៩។[242] មានការព្រួយបារម្ភអំពីថាតើសិទ្ធិឯកជនភាពរបស់គាត់អាចត្រូវបានរំលោភឬអត់ ដូចដែលគាត់ ត្រូវបានគេចោទប្រកាន់ថា ប៉ូលិសបានត្រួតពិនិត្យគណនី Facebook របស់គាត់ មួយសប្តាហ៍មុនពេលចាប់ខ្លួនគាត់ ដោយមិនត្រូវបានគេជូនដំណឹងអំពីមូលដ្ឋានច្បាប់ សម្រាប់ការឃ្លាំមើលបែបនេះទេ។[243]

និន្នាការនេះបានបន្តបន្ទាប់ពី ខែមិថុនា ឆ្នាំ២០២០ ដោយមានរបាយការណ៍មួយចំនួននៃបុគ្គលដែលមានទំនាក់ទំនងជាមួយគណបក្សសង្គ្រោះជាតិត្រូវបានចាប់ខ្លួន ឃាត់ខ្លួន និងចោទប្រកាន់ពីបទបញ្ចេញមតិតាមអ៊ីនធឺណិត។ នៅក្នុង ខែកុម្ភៈ ឆ្នាំ២០២០ ត្រូវបានគេរាយការណ៍ថា **ថន ចន្ថា** និង **ម៉ី សុភ័ណ្ឌ** ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទ "ញុះញង់" ចំពោះ "ព័ត៌មានមិនពិតដែលញុះញង់ឱ្យមនុស្សយល់ច្រឡំអំពីបញ្ហា [កូវីដ-

---

[238] បញ្ជីរាយនាមការចាប់ខ្លួន និងការឃុំខ្លួនរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស

[239] *Ibid*

[240] *Ibid*

[241] *Ibid* សូមមើលផងដែរ សារព័ត៌មាន Al Jazeera 'កម្ពុជាដែលត្រូវបានចោទប្រកាន់ពីបទគៀបនយោបាយចំពេលមានការផ្ទុះឡើងនៃមេរោគឆ្លង' ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ មាននៅ៖ https://www.aljazeera.com/news/2020/3/24/cambodia-accused-of-political-clampdown-amid-coronavirus-outbreak

[242] *Ibid*

[243] *Ibid* គួរកត់សំគាល់ថា ការឃ្លាំមើលទូរគមនាគមន៍ទាំងអស់គឺអាចអនុញ្ញាតបាន ប្រសិនបើធ្វើឡើងដោយមានការយល់ព្រមពី "អាជ្ញាធរស្របច្បាប់" ក្រោមច្បាប់ស្តីពីទូរគមនាគមន៍ តាមមាត្រា ៩៧នៃច្បាប់ស្តីពីទូរគមនាគមន៍។

១៩]"។[244] លោក ចុន ចន្ថា បានបង្ហោះនៅលើ Facebook ចោទប្រកាន់ថា ពលរដ្ឋខ្មែរកំពុងត្រូវបានបង្ខំឲ្យចាក់វ៉ាក់សាំង កូវីដ-១៩ ហើយលោក ម៉ី សុភ័ណ្ឌ បានបង្ហោះក្នុងហ្វេសប៊ុកថា មិនចាំបាច់ប្រញាប់ប្រញាល់ចាក់វ៉ាក់សាំងទេ ព្រោះកម្ពុជា មិនមានករណីឆ្លងកូវីដ-១៩ ច្រើនទេ។[245] នៅខែមីនា ឆ្នាំ២០២១ **ថន គឹមសាន** ត្រូវបាន គេរាយការណ៍ថាត្រូវបានចាប់ខ្លួនដោយសារសេចក្តីថ្លែងតាម Facebook ស្តីពីសុវត្ថិភាពនៃវ៉ាក់សាំងដែលផលិតនៅប្រទេសចិន ដោយសារសេចក្តីថ្លែងបែបនេះ ត្រូវបានអាជ្ញាធរចោទប្រកាន់ថាបានធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសង្គមយ៉ាងធ្ងន់ធ្ងរ និង បង្កើតជា "ការញុះញង់ឱ្យបង្កើតភាពចលាចលក្នុងសង្គម និងការយល់ច្រឡំ"។[246] នៅ ខែមេសា ឆ្នាំ២០២១ លោក **សម រង្ស៊ី** អតីតប្រធានគណបក្សសង្គ្រោះជាតិ ដែលបាននិរទេសខ្លួនទៅប្រទេសបារាំងតាំងពីឆ្នាំ២០១៥[247] ត្រូវបានចោទប្រកាន់ពីបទ «ញុះញង់» ហើយមានដីកាចាប់ខ្លួនលោកចំពោះការអត្ថាធិប្បាយរបស់លោកក្នុងបទសម្ភាសន៍ជាមួយ វិទ្យុអាស៊ីសេរី អំពីការបិទខ្ទប់ប្រទេសដោយសារជំងឺ កូវីដ-១៩ អំពើពុករលួយរបស់រដ្ឋាភិបាល និងកង្វះជំនួយពីរដ្ឋាភិបាល។[248]

[244] សារព័ត៌មាន VOA 'បុគ្គលពីរនាក់ដែលជាប់ពាក់ព័ន្ធ CNRP ត្រូវបានឃុំខ្លួនដោយសារមតិយោបល់អំពីវ៉ាក់សាំង COVID-19' ថ្ងៃទី១ ខែមីនា ឆ្នាំ២០២១ មាននៅ៖ https://www.voacambodia.com/a/two-cnrp-linked-individuals-detained-for-covid-19-vaccine-comments-/5796877.html

[245] *Ibid*

[246] វិទ្យុអាស៊ីសេរី 'សកម្មជនខ្មែរត្រូវបានចាប់ខ្លួនពីបទរិះគន់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ របស់ចិន' ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ មាននៅ៖ https://www.rfa.org/english/news/cambodia/vaccine-03152021183359.html

[247] សារព័ត៌មាន Al Jazeera "ការមើលងាយយុត្តិធម៌"៖ លោក សម រង្ស៊ី ជាប់ពន្ធនាគារ ២៥ឆ្នាំ' ថ្ងៃទី២ ខែមីនា ឆ្នាំ២០២១ មាននៅ៖ https://www.aljazeera.com/news/2021/3/2/mockery-of-justice-cambodias-rainsy-gets-25-year-jail-time

[248] សារព័ត៌មាន វិទ្យុអាស៊ីសេរី ' តុលាការចេញដីកាចាប់ខ្លួនលោក សម រង្ស៊ី ប្រធានបក្សប្រឆាំង' ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ មាននៅ៖ https://www.rfa.org/english/news/cambodia/samrainsy-04282021173607.html

*មាត្រា ៤៣៧ (ស្ទួន)៖ ប្រមាថអង្គព្រះមហាក្សត្រ*[249]

ចាប់តាំងប្រកាសឲ្យប្រើប្រាស់ មាត្រា ៤៣៧(ស្ទួន) កាលពីខែធ្នូ ឆ្នាំ ២០១៨ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានចងក្រងឯកសារបុគ្គលចំនួន ៨នាក់ ដែលត្រូវបានចោទប្រកាន់ក្រោមលក្ខខណ្ឌរបស់ច្បាប់នេះដោយបីនាក់ត្រូវបានកាត់ទោសគិតត្រឹម ខែកុម្ភៈ ឆ្នាំ ២០២១ ដែលក្នុងនោះយ៉ាងហោចណាស់បីនាក់ មានទំនាក់ទំនងជាមួយគណបក្សសង្គ្រោះជាតិ។[250]

នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ មានសេចក្តីរាយការណ៍ថា សាលាដំបូងរាជធានីបានចោទប្រកាន់លោក **សម រង្ស៊ី** តាមមាត្រា ៤៣៧ *(ស្ទួន)* នៃក្រមព្រហ្មទណ្ឌ។[251] ការចោទប្រកាន់នេះធ្វើឡើងផ្អែកលើហ្វេសប៊ុករបស់លោក សម រង្ស៊ី កាលពីថ្ងៃទី២០ និង២៥ ខែធ្នូ ឆ្នាំ២០២១ ដែលរិះគន់ផែនការចាក់វ៉ាក់សាំង ជំងឺកូវីដ១៩ របស់រដ្ឋាភិបាល និងសម្តែងមតិថា ព្រះមហាក្សត្រជាអាយ៉ងដែលធ្វើតាមអ្វីដែលលោក ហ៊ុន សែន ប្រាប់។[252]

ជាការកត់សម្គាល់ អ្នកនាំពាក្យក្រសួងយុត្តិធម៌ បានបញ្ជាក់ថា «ការប្រមាថអង្គព្រះមហាក្សត្រមិនស្ថិតនៅក្រោមសិទ្ធិសេរីភាពនៃការបញ្ចេញមតិទេ ប៉ុន្តែជាបទល្មើសព្រហ្មទណ្ឌដែលមានចែងក្នុងច្បាប់»។[253] ដូចដែលបានកត់សម្គាល់លក្ខខណ្ឌនៃមាត្រា ៤៣៧ *(ស្ទួន)* និង *ការប្រមាថអង្គព្រះមហាក្សត្រ* គឺជាបញ្ញត្តិដែលមានលក្ខណៈមិនស្របទៅនឹងកាតព្វកិច្ចសិទ្ធិមនុស្សរបស់កម្ពុជា។[254] លើសពីនេះ កាតព្វកិច្ចរបស់កម្ពុជាក្រោម ICCPR ចែងថា "ផលប្រយោជន៍សាធារណៈជាកម្មវត្ថុ នៃការរិះគន់គួរតែត្រូវបានទទួល

---

[249] សម្រាប់សេចក្តីសង្ខេប និងថេរវេលានៃករណីមាត្រា ៤៣៧ (ស្ទួន) សូមមើល៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា 'ការប្រកាសឲ្យប្រើប្រាស់ រយៈពេលបីឆ្នាំ នៃច្បាប់ ប្រមាថអង្គព្រះមហាក្សត្រ' ខែកុម្ភៈ ឆ្នាំ២០២១ មាននៅ៖ https://cchrcambodia.org/admin/media/newsletter/newsletter/english/Lese%20Majeste%20Snapshot_Final_Eng.pdf
.

[250] *Ibid*

[251] សារព័ត៌មាន Cambodianess 'តុលាការក្រុងភ្នំពេញ កាត់ទោស លោក សម រង្ស៊ី ពីបទប្រមាថអង្គព្រះមហាក្សត្រ នរោត្តម សីហមុនី' ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ មាននៅ៖ https://cambodianess.com/article/phnom-penh-court-indicts-rainsy-for-insulting-king-norodom-sihamoni

[252] *Ibid*

[253] សារព័ត៌មាន Cambodianess 'តុលាការក្រុងភ្នំពេញ កាត់ទោស លោក សម រង្ស៊ី ពីបទប្រមាថអង្គព្រះមហាក្សត្រ នរោត្តម សីហមុនី' ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ២០២០ មាននៅ៖ https://cambodianess.com/article/phnom-penh-court-indicts-rainsy-for-insulting-king-norodom-sihamoni

[254] ឯកសារ UN CCPR/C/GC/34 កថាខណ្ឌទី៣៨

ស្គាល់ថាជាការការពារ″ ចំពោះបណ្តឹងបរិហារកេរ្តិ៍ ដែលមានវិសាលភាពដល់ករណីនៃការបរិហារកេរ្តិ៍អង្គព្រះមហាក្សត្រ។[255]

នេះជាលើកទី៣ហើយដែលលោក សម រង្ស៊ី ត្រូវបានចោទប្រកាន់តាមមាត្រា ៤៣៧ *(ស្ទួន)* ។ នៅខែឧសភា ឆ្នាំ២០១៩ លោក សម រង្ស៊ី ត្រូវបានរកឃើញថាមានទោស *កំបាំងមុខ* ដោយសាលាដំបូងរាជធានីភ្នំពេញចោទពីបទ *ប្រមាថអង្គព្រះមហាក្សត្រ* ផ្តន្ទាទោស ដាក់ពន្ធនាគាររយៈពេល ៤ឆ្នាំ និងពិន័យជាប្រាក់ ១០លានរៀល(២,៥០០ ដុល្លារ)សម្រាប់ការបង្ហោះនៅលើហ្វេសប៊ុកថាព្រះរាជសាររបស់ព្រះមហាក្សត្រ សីហមុនី អំពីការចូលរួមបោះឆ្នោតគឺ ″ក្លែងក្លាយ ឬត្រូវបានធ្វើឡើងដោយមានការរៀបសង្កត់″។[256] ក្រោយមក នៅខែកញ្ញា ឆ្នាំ២០១៩ លោក សម រង្ស៊ី ត្រូវបានចោទប្រកាន់ម្តងទៀត តាមមាត្រា ៤៣៧ *(ស្ទួន)* កាលពីខែកញ្ញា ឆ្នាំ២០១៩ ចំពោះការលើកឡើងថា ព្រះមហាក្សត្រជាអាយ៉ងរបស់នាយករដ្ឋមន្ត្រីក្នុងបទសម្ភាសន៍ជាមួយវិទ្យុអាស៊ីសេរី[257] បន្ទាប់មកសាលាដំបូងរាជធានីភ្នំពេញបានចេញដីកាចាប់ខ្លួនដាក់ឃុំមុនជំនុំជម្រះ។[258]

## *ការឆ្លើយតបរបស់រដ្ឋាភិបាលកម្ពុជា*

ជាការឆ្លើយតបទៅនឹងការអំពាវនាវរបស់អនុរដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិកឱ្យរដ្ឋាភិបាលកម្ពុជាទម្លាក់ ″ការចោទប្រកាន់ដោយចេតនានយោបាយ លើសមាជិកគណបក្សប្រឆាំង អ្នកសារព័ត៌មាន និងសកម្មជន″ នៅក្នុងខែមិថុនា ឆ្នាំ២០២១ [259] រដ្ឋាភិបាលកម្ពុជាបានការពារថាការត្រួតពិនិត្យលើសំណុំរឿងនេះ គឺស្ថិតនៅក្នុងរង្វង់

---

[255] ឯកសារ UN CCPR/C/GC/34 កថាខណ្ឌទី៤៧

[256] លោក សម រង្ស៊ី ជាប់គុក ៤ឆ្នាំ *ការប្រមាថអង្គព្រះមហាក្សត្រ* និងបួនឆ្នាំទៀត ពីបទញុះញង់ទាហានមិនគោរពបទបញ្ជា សារព័ត៌មាន khmer Times 'លោក សម រង្ស៊ី ជាប់គុក ៤ ឆ្នាំ ពីបទប្រមាថអង្គព្រះមហាក្សត្រ' ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៩ មាននៅ៖ https://www.khmertimeskh.com/600094/court-finds-sam-rainsy-guilty-in-two-cases/ សារព័ត៌មាន វិទ្យុអាស៊ីសេរី' តុលាការកម្ពុជាកោះហៅលោក សម រង្ស៊ី អតីតប្រធានបក្សប្រឆាំង ការចោទប្រកាន់ពីបទប្រមាថអង្គព្រះមហាក្សត្រ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨ មាននៅ៖ https://www.rfa.org/english/news/cambodia/summons-06202018161940.html

[257] សារព័ត៌មាន ភ្នំពេញប៉ុស្តិ៍ 'លោក សម រង្ស៊ី ត្រូវបានចោទប្រកាន់ពីបទ 'ប្រមាថអង្គព្រះមហាក្សត្រ' ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៩ មាននៅ៖ https://www.phnompenhpost.com/national-politics/rainsy-charged-insulting-king

[258] សារព័ត៌មាន ភ្នំពេញប៉ុស្តិ៍ 'ដីកាចាប់ខ្លួន លោកសម រង្ស៊ី ត្រូវបានបញ្ជូនទៅកាន់អាស៊ាន' ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ មាននៅ៖ https://www.phnompenhpost.com/national-politics/rainsy-asean-arrest-warrants-sent

[259] ក្រសួងការបរទេសសហរដ្ឋអាមេរិក 'ដំណើរទស្សនកិច្ចរបស់អនុរដ្ឋមន្ត្រីការបរទេស Wendy Sherman មកកាន់ប្រទេសកម្ពុជា' ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២១ មាននៅលើ៖ https://www.state.gov/deputy-secretary-of-state-wendy-shermans-visit-to-cambodia/

សមត្ថកិច្ចរបស់តុលាការ។ រដ្ឋាភិបាលបានអះអាងថា "សង្គមដែលប្រកាន់ខ្ជាប់នូវលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ តុលាការគឺជាស្ថាប័នឯករាជ្យ ដែលមិនអាចស្តាប់បង្គាប់អ្នកណាម្នាក់បានទេ"។[260] ការឆ្លើយតបនេះគឺស្រដៀងទៅនឹងការអះអាងពីមុនរបស់រដ្ឋាភិបាលដែលថា "ការកាត់ទោស និងផ្តន្ទាទោសជនល្មើសដោយអាជ្ញាធរស្របច្បាប់ដើម្បីផលប្រយោជន៍ យុត្តិធម៌ មិនគួរត្រូវបាន មើលឃើញថាជាការគំរាមកំហែងដល់លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនោះទេ ប៉ុន្តែជាការអនុវត្តច្បាប់ … ការប្រកាន់យកច្បាប់មានន័យថាអ្នកប្រព្រឹត្តល្មើសទទួលខុសត្រូវចំពោះការប្រព្រឹត្តរបស់ខ្លួន" ។[261]

ការឆ្លើយតបនេះមិនបានធ្វើឲ្យប្រទេសកម្ពុជារួចពីការ ទទួលខុសត្រូវរបស់ខ្លួនចំពោះការរំលោភសិទ្ធិមនុស្សអន្តរជាតិឡើយ ដោយយោងតាមកាតព្វកិច្ចផ្លូវច្បាប់អន្តរជាតិរបស់ខ្លួន។ កាតព្វកិច្ចសិទ្ធិមនុស្សរបស់រដ្ឋត្រូវតែប្រកាន់ខ្ជាប់គ្រប់វិស័យរបស់រដ្ឋ រួមទាំងប្រព័ន្ធតុលាការ ហើយការធ្វើសកម្មភាព និងការខកខានមិនបានធ្វើ គ្រប់ផ្នែកទាំងអស់ ពាក់ព័ន្ធការទទួលខុសត្រូវរបស់រដ្ឋ។[262] នេះបើតាមការបញ្ជាក់របស់គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ "ផ្នែកនីតិប្រតិបត្តិដែលជាធម្មតាតំណាងឱ្យរដ្ឋភាគីអន្តរជាតិ [… ] មិនអាច ចង្អុលបង្ហាញពីការពិតដែលថាសកម្មភាពមិនស្របគ្នានឹងបទប្បញ្ញត្តិនៃកតិកាសញ្ញា ត្រូវបានអនុវត្តដោយផ្នែកមួយដទៃទៀត របស់រដ្ឋាភិបាល ជាមធ្យោបាយនៃការស្វែងរក ការបន្ធូរបន្ថយការទទួលខុសត្រូវរបស់រដ្ឋ ចំពោះសកម្មភាព និងលទ្ធផលមិនស៊ីសង្វាក់គ្នា" ។[263]

---

[260] សារព័ត៌មាន ខ្មែរថាមស៍ 'CPP និយាយថា 'គ្មានអ្នកទោសនយោបាយ' នៅកម្ពុជា' ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២១មាននៅ៖ https://www.khmertimeskh.com/50867226/cpp-says-no-political-prisoners-in-cambodia/

[261] ICJ 'កម្ពុជា៖ ការប្រើប្រាស់ច្បាប់ខុសឆ្គងជាបន្តបន្ទាប់ ដើម្បីបំបិទមាត់គូបដិបក្ខ កាន់តែស៊ីជម្រៅថែមទៀត និទណ្ឌភាព និងធ្វើឱ្យខូចដល់នីតិរដ្ឋ' ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៧ មាននៅ៖ https://www.icj.org/cambodia-ongoing-misuse-of-law-to-silence-opponents-further-deepens-impunity-and-undermines-the-rule-of-law/

[262] ឯកសារ UN CCPR/C/GC/34 កថាខណ្ឌទី៨ ឯកសារ UN. CCPR/C/21/Rev.1 /Add.13 កថាខណ្ឌទី៤ និង ១៥

[263] ឯកសារ UN CCPR/C/21/Rev.1 / Add.13 កថាខណ្ឌទី៤

ICJ ធ្លាប់បានលើកឡើងពីការសង្ស័យរឿង កង្វះប្រព័ន្ធ តុលាការឯករាជ្យ និងមិនលំអៀងតាមហេតុការណ៍ពិត បើទោះបីជាតាមផ្លូវ *ច្បាប់* ធានានៅក្នុងច្បាប់ក្នុងប្រទេស និងបង្ហាញការប្តេជ្ញាចិត្តដែលបានបញ្ជាក់ក្នុងការប្រកាន់ខ្ជាប់នូវស្តង់ដារអន្តរជាតិ។[264] លើសពីនេះនីតិរដ្ឋមិនត្រឹមតែពង្រីកដល់ការអនុវត្តច្បាប់ក្នុងស្រុកប៉ុណ្ណោះទេ ថែមទាំងធានាថា ច្បាប់ត្រូវបានបរិយាយ និងអនុវត្តស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។[265] ដូចដែលបានកត់សម្គាល់ខាងលើ ច្បាប់ភាគច្រើននៃ "ការចោទប្រកាន់ដោយហេតុផលនយោបាយ" ត្រូវបានផ្អែកលើ ការមិនអនុលោមតាមសិទ្ធិមនុស្សតាំងពីដំបូងមក។

## *iv. ការរឹតត្បិតការចូលប្រើការបញ្ចេញមតិ និងព័ត៌មានអ៊ីនធឺណិតដែលមិនពេញចិត្ត*

នៅខែធ្នូ ឆ្នាំ២០១៩ ICJ បានលើកឡើងពីរបៀបដែល *ប្រកាស* អន្តរក្រសួង ហាក់ដូចជាអនុញ្ញាតឱ្យមានការបិទគេហទំព័រនៅក្នុងខែកក្កដា ឆ្នាំ២០១៨ មុនពេល ការបោះឆ្នោតទូទៅរួមទាំងគេហទំព័ររបស់ស្ថាប័នព័ត៌មានឯករាជ្យផងដែរ។[266] និន្នាការនៃការរឹតត្បិតការចូលប្រើខ្លឹមសារលើអ៊ីនធឺណិតកាន់តែខ្លាំងក្នុងអំឡុងពេលជំងឺរាតត្បាត កូវីដ-១៩ ហើយត្រូវបានពង្រីកទៅដល់កម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គម។

រដ្ឋាភិបាលកម្ពុជាបានបិទការចូលទៅគេហទំព័រព័ត៌មានសម្រាប់អត្ថបទរបស់ខ្លួនអំពីជំងឺកូវីដ-១៩ ។ ក្នុងខែមីនា ឆ្នាំ២០២០ **មនោរម្យ** គេហទំព័រព័ត៌មានជាភាសាខ្មែរ ដែលមានមូលដ្ឋាន នៅប្រទេសបារាំង ត្រូវបានបិទ ដោយសារការផ្សាយព័ត៌មានអំពី ជំងឺរាតត្បាត។[267] កាលពីខែមេសា ឆ្នាំ២០២០ បន្ទាប់ពីការចាប់ខ្លួនលោក សុវណ្ណ រិទ្ធី

---

[264] ICJ *ការសម្រេចបាននូវយុត្តិធម៌សម្រាប់ការរំលោភសិទ្ធិមនុស្សនៅកម្ពុជា៖ ការសិក្សាមូលដ្ឋាន ខែតុលា ឆ្នាំ២០១៧* ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៧ ទំព័រទី១៧–១៩ មាននៅ៖ https://www.icj.org/wp-content/uploads/2017/10/Cambodia-GRA-Baseline-Study-Publications-Reports-Thematic-reports-2017-ENG.pdf
ចំពោះការរិះគន់ថ្មីៗអំពីឥទ្ធិពលនយោបាយដែលមាននៅក្នុងប្រព័ន្ធតុលាការកម្ពុជា សូមមើលវិទ្យុអាស៊ីសេរី 'តុលាការកម្ពុជាបង្ហាញគំរូនៃឥទ្ធិពលនយោបាយ ស្តង់ដារទ្វេនៃយុត្តិធម៌' ថ្ងៃទី២១ ឧសភា ឆ្នាំ២០២១ មាននៅ៖ https://www.rfa.org/english/news/cambodia/justice-05212021193839.html

[265] ICJ ' កម្ពុជា៖ ការប្រើប្រាស់ច្បាប់ខុសឆ្គងជាបន្តបន្ទាប់ ដើម្បីបំបិទមាត់គូបដិបក្ខ កាន់តែស៊ីជម្រៅថែមទៀត និទណ្ឌភាព និងធ្វើឱ្យខូចដល់នីតិរដ្ឋ' ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៧ មាននៅ៖ https://www.icj.org/cambodia-ongoing-misuse-of-law-to-silence-opponents-further-deepens-impunity-and-undermines-the-rule-of-law/

[266] របាយការណ៍ ICJ ការកំណត់ឲ្យអ៊ីនធឺណិតធ្វើតាម ឆ្នាំ២០១៩ ទំព័រទី១១៤ – ១១៥

[267] អ្នករាយការណ៍គ្មានព្រំដែន '# CollateralFreedom: RSF ការដាក់ឲ្យដំណើរការវិញនូវ គេហទំព័រចំនួនប្រាំបីដែលត្រូវបានត្រួតពិនិត្យអំឡុងពេលជំងឺរាតត្បាត' ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២០មាននៅ៖ https://rsf.org/en/news/collateralfreedom-rsf-unblocks-eight-sites-censored-during-pandemic សារព័ត៌មាន VOA ' កំឡុងពេលការត្រួតពិនិត្យ COVID គេហទំព័រសារ

និងការដកហូតអាជ្ញាប័ណ្ណផ្សាយរបស់ TVFB និយតករទូរគមនាគមន៍កម្ពុជាបានប្រកាសថាខ្លួននឹងរារាំងចំនួនពីរនៃ គេហទំព័ររបស់ **TVFB**។[268] វាត្រូវបានបញ្ជាក់ថា tvfb.com.kh និង fbtv.news នឹងត្រូវបិទ។ នៅពេលសរសេររបាយការណ៍នេះ ICJ មិនអាចចូលប្រើ URL ទាំងពីរបានទេ។

លើសពីនេះ រដ្ឋាភិបាលកម្ពុជាបានព្យាយាមផ្អាកទំព័រ Facebook និងគណនីដោយចោទថាបានផ្សព្វផ្សាយព័ត៌មានមិនពិតអំពីជំងឺកូវីដ-១៩ ។ កាលពីខែឧសភា ឆ្នាំ២០២០ អ្នកនាំពាក្យក្រសួងព័ត៌មានបានបញ្ជាក់ថា "ក្រសួងបានជូនដំណឹងដល់ Facebook អំពី Facebook Page និងគណនីផ្ទាល់ខ្លួនជាង ៣០ ដែលចោទប្រកាន់ថា "ផ្សព្វផ្សាយព័ត៌មានមិនពិត" ហើយថា "ផេកខ្លះត្រូវបានដកចេញ" ។[269] កាន់តែទូលំទូលាយ វាត្រូវបានគេរាយការណ៍ថា ក្នុងឆ្នាំ២០២០ រដ្ឋាភិបាល បានចាត់វិធានការប្រឆាំងនឹង "គណនី Facebook ប្រហែល ២០០" សម្រាប់ការចោទប្រកាន់ថាបានចែករំលែក "ព័ត៌មានមិនពិត" និងញុះញង់ឱ្យមានអំពើហិង្សាដោយ "គណនីមួយចំនួនត្រូវបានរាយការណ៍ទៅប៉ូលិសជាតិ ខណៈដែលគណនីផ្សេងទៀត ត្រូវបានរាយការណ៍ដោយផ្ទាល់ទៅ Facebook និងទៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ដើម្បីលុបចោល" ។[270]

ព័ត៌មានស្វែងរកវិធីដើម្បីបន្តនៅលើអ៊ីនធឺណិត' ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០ មាននៅ៖ https://www.voanews.com/press-freedom/amid-covid-censorship-news-websites-find-ways-stay-online

[268] សារព័ត៌មាន VOD 'គេហទំព័រព័ត៌មានត្រូវបានបិទ អ្នកកាសែតត្រូវជាប់គុកបន្ទាប់ពីដកស្រង់សម្ដីលោក ហ៊ុន សែន' ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០ មាននៅ៖
https://vodenglish.news/news-site-blocked-journalist-jailed-after-quoting-hun-sen/

[269] សារព័ត៌មាន Cambodianess 'COVID-19 ពិសោធន៍ ការប្រយុទ្ធប្រឆាំងរបស់ Facebook ប្រឆាំង "ព័ត៌មានក្លែងក្លាយ" នៅក្នុងប្រទេសកម្ពុជា' ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០ មាននៅ៖ https://cambodianess.com/article/covid-19-challenges-facebooks-fight-against-fake-news-in-cambodia

[270] សារព័ត៌មាន UCA News 'កម្ពុជាពង្រីកការត្រួតពិនិត្យ ព័ត៌មានក្លែងក្លាយ' ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ មាននៅ៖
https://www.ucanews.com/news/cambodia-expands-monitoring-of-fake-news/91186

ទោះបីជាមានការកត់សម្គាល់ក្នុងការស្វែងរកគោលបំណងស្របច្បាប់នៃការការពារ សុខភាពសាធារណៈក៏ដោយក៏វាហាក់បីដូចជាការរិតត្បិតនេះមិនត្រូវបានអនុវត្ត តាមបញ្ញាដោយអាជ្ញាធរតុលាការឯករាជ្យ និងមិនលំអៀង ស្របតាមដំណើរការត្រឹមត្រូវ ជាមួយនឹងការធានាយ៉ាងច្បាស់លាស់នៃសិទ្ធិដើម្បីប្តឹងឧទ្ធរណ៍នោះទេ។[271]

[271] ឯកសារ UN. A/HRC/38/35 កថាខណ្ឌទី ៦៦

## VII. តួនាទីរបស់ "ក្រុមហ៊ុនបច្ចេកវិទ្យាធំៗ"

ការឆ្លើយតបរបស់រដ្ឋាភិបាលកម្ពុជាចំពោះជំងឺរាតត្បាតកូវីដ-១៩ បានធ្វើឱ្យមានការព្រួយបារម្ភថ្មីអំពីតួនាទីរបស់ក្រុមហ៊ុនបច្ចេកវិទ្យាធំៗ ជាពិសេស Facebook និងវិសាលភាពដែលពួកគេមានការសមគំនិត ក្នុងការត្រួតពិនិត្យ លើអ៊ីនធឺណិតរបស់អាជ្ញាធរកម្ពុជា។

មជ្ឈមណ្ឌលតម្លាភាពរបស់ Facebook បានរាយការណ៍អំពីករណីចំនួន ១២ នៃខ្លឹមសារដែលត្រូវបានរិតត្បិតនៅក្នុងប្រទេសកម្ពុជា ដោយផ្អែកលើច្បាប់ក្នុងស្រុកនៅ ចន្លោះខែកក្កដា និងខែធ្នូ ឆ្នាំ២០២០ បន្ទាប់ពីមិនមានករណីនៅចន្លោះខែមករា និងខែមិថុនា ឆ្នាំ២០២០ ។[272] មជ្ឈមណ្ឌលតម្លាភាពបានកត់សម្គាល់ថា ការរិតត្បិតទាំង ១២នេះ មិនទាក់ទងនឹងខ្លឹមសារស្តីពី កូវីដ-១៩ នោះទេ។[273] ទទួលយកនូវអ្វីដែលកើតឡើង វាហាក់ដូចជាមិនស៊ីសង្វាក់គ្នានឹងរបាយការណ៍របស់ក្រសួងព័ត៌មាន។ ក្នុងខែឧសភា ឆ្នាំ២០២០ ក្រសួងព័ត៌មាន "បានជូនដំណឹងដល់ Facebook អំពី Facebook Pages និងគណនីផ្ទាល់ខ្លួនជាង ៣០ ដែលត្រូវបានចោទប្រកាន់ថាបានផ្សព្វផ្សាយព័ត៌មានមិនពិត" អំពីជំងឺកូវីដ-១៩ ហើយថា "ផេកទាំងនេះមួយចំនួនត្រូវបានដកចេញតាំងពីពេលនោះមក"។[274] នៅក្នុងខែមករា ឆ្នាំ២០២១ ត្រូវបានគេរាយការណ៍ថា ក្នុងឆ្នាំ២០២០ រដ្ឋាភិបាលបានចាត់វិធានការ ប្រឆាំងនឹង គណនី Facebook ចំនួន ២០០ សម្រាប់ការចោទប្រកាន់ថាបានចែករំលែក "ព័ត៌មានមិនពិត" និងញុះញង់ឱ្យមានអំពើហិង្សាដោយ "គណនីមួយ ចំនួនត្រូវបានរាយការណ៍ទៅ ប៉ូលិសជាតិ ខណៈដែលគណនីផ្សេងទៀតត្រូវបានរាយការណ៍ដោយផ្ទាល់ទៅកាន់ Facebook និងទៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ដើម្បីលុបចេញ"។[275]

---

[272] មជ្ឈមណ្ឌលតម្លាភាព Facebook 'កម្ពុជា៖ ការរិតត្បិតខ្លឹមសារផ្អែកលើច្បាប់ក្នុងស្រុក' មាននៅ៖ https://transparency.fb.com/data/content-restrictions/country/KH

[273] *Ibid.* Facebook បានដាក់កំហិតការចូលប្រើប្រាស់ទម្រង់ចំនួន ១២ និងទំព័រអ្នកគាំទ្រប្រធានាធិបតីប្រេស៊ីល Bolsonaro រួមទាំងនៅក្នុងប្រទេសកម្ពុជាផងដែរ បន្ទាប់ពីមានដីកាពីតុលាការកំពូលប្រេស៊ីល។

[274] សារព័ត៌មាន Cambodianess, ' COVID-19 សាកល្បង ការប្រយុទ្ធប្រឆាំង "ព័ត៌មានក្លែងក្លាយ" របស់ Facebook' នៅក្នុងប្រទេសកម្ពុជា' ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០ មាននៅ៖ https://cambodianess.com/article/covid-19-challenges-facebooks-fight-against-fake-news-in-cambodia

[275] សារព័ត៌មាន UCA News 'កម្ពុជាពង្រីកការត្រួតពិនិត្យ 'ព័ត៌មានក្លែងក្លាយ' ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ មាននៅ៖ https://www.ucanews.com/news/cambodia-expands-monitoring-of-fake-news/91186

វាអាចទៅរួចដែលថាករណីនៃការរិតត្បិតខ្លឹមសារទាំងនេះត្រូវបានដាក់បញ្ចូលក្រោម ឧទាហរណ៍នៃស្តង់ដារសហគមន៍របស់ Facebook ផ្ទាល់ដែលកំពុងត្រូវបានអនុវត្ត ដែល Facebook និយាយថា ខ្លួនមិនបែងចែកដោយផ្អែកលើប្រទេសទេ។ ស្តង់ដារសហគមន៍របស់ Facebook បង្ហាញថា៖ (i) ពួកគេលុបព័ត៌មានមិនពិតចេញពីបច្ចេកវិទ្យា Facebook នៅពេលដែល "ព័ត៌មានមិនពិតអាចបង្កឱ្យមានគ្រោះថ្នាក់ដល់រាងកាយ" ដូចជា "ការអះអាងមិនពិតអំពីជំងឺ កូវីដ-១៩ និងវ៉ាក់សាំងដែលអង្គការសុខភាពឈានមុខគេបានលុបចោល" (ii) ពួកគេកាត់បន្ថយការចែកចាយខ្លឹមសារ ដែលវាយតម្លៃថាមិនពិតដោយដៃគូត្រួតពិនិត្យការពិតរបស់ពួកគេ និង (iii) ពួកគេអនុវត្តការជូនដំណឹងចំពោះការបង្ហោះដែលបានត្រួតពិនិត្យការពិតហើយធ្វើការជូនដំណឹងទៅមនុស្សដែលបង្ហោះវា។[276] វិធីសាស្រ្តនេះត្រូវបានបញ្ជាក់ដើម្បីអនុវត្តនៅក្នុងប្រទេសកម្ពុជាដោយនាយកគោលនយោបាយសាធារណៈរបស់ Facebook ប្រចាំតំបន់អាស៊ីអាគ្នេយ៍ ដែលបាននិយាយថា មតិយោបល់ និងការបង្ហោះអំពីជំងឺ កូវីដ-១៩ ត្រូវបានលុបចេញពីកម្មវិធីចំពោះព័ត៌មានដែលអាចនាំឱ្យមានគ្រោះថ្នាក់ដល់រាងកាយ ប៉ុន្តែបានកត់សម្គាល់ថា គាត់មិនមានស្ថិតិជាក់លាក់ដើម្បីចែករំលែកសម្រាប់កម្ពុជាទេ។[277]

ទាំងអស់នេះបង្ហាញពីកង្វះតម្លាភាពគ្រប់គ្រាន់នៅផ្នែករបស់ Facebook ទាក់ទងនឹងវិសាលភាពដែលខ្លួនកំពុងផ្សព្វផ្សាយព័ត៌មានអំពីតម្រូវការដែលខ្លួនបានទទួលពីរដ្ឋាភិបាលកម្ពុជាក្នុងការរិតត្បិតខ្លឹមសារនៅលើកម្មវិធីរបស់ខ្លួន និងរបៀបឆ្លើយតប។ ការបដិសេធនេះប្រឈមមុខនឹងទំនួលខុសត្រូវសិទ្ធិមនុស្សរបស់ខ្លួនក្នុងការផ្តល់នូវ "ទិន្នន័យលម្អិតអំពីប្រភេទនៃសំណើដែលទទួលបាន [ពីរដ្ឋ] និងសកម្មភាពដែលបានធ្វើឡើង" ជាមួយនឹង "ឧទាហរណ៍ជាក់លាក់ [ត្រូវបានផ្តល់ជូន] ឱ្យបានញឹកញាប់តាមដែលអាចធ្វើទៅបាន" ។[278]

---

[276] មជ្ឈមណ្ឌលតម្លាភាព Facebook 'វិធីសាស្រ្តរបស់យើងចំពោះព័ត៌មានមិនពិត' ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២១ មាននៅ៖ https://transparency.fb.com/features/approach-to-misinformation/

[277] សារព័ត៌មាន ភ្នំពេញ ប៉ុស្តិ៍ ' Facebook បញ្ជាក់ការលុបការបង្ហោះគួរឱ្យសង្ស័យរឿង Covid-19' ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ មាននៅ៖ https://phnompenhpost.com/national/facebook-confirms-deleting-dubious-covid-19-postings

[278] ឯកសារ UN A/HRC/38/35 កថាខណ្ឌទី៥២

ដូចដែលបានរៀបរាប់ខាងលើ អាជ្ញាធរកម្ពុជាបានរួមបញ្ចូលករណីពិតនៃ "ព័ត៌មានមិនពិត" និងការព្រួយបារម្ភស្របច្បាប់ដែលត្រូវបានបង្ហាញអំពីជំងឺកូវីដ-១៩ ហើយបានកំណត់លក្ខណៈទាំងពីរថាជា "ព័ត៌មានមិនពិត" ដែលគួរតែត្រូវបានរិតត្បិត។ វាទំនងជាថា វិធីសាស្ត្រនេះត្រូវបានពង្រីកស្រដៀងគ្នាទៅនឹងការទាមទាររបស់រដ្ឋាភិបាលចំពោះ Facebook ក្នុងការរិតត្បិតខ្លឹមសារនៃ កូវីដ-១៩។ នេះអាចបណ្ដាលឱ្យមាន ការបញ្ចេញមតិដែលត្រូវបានការពារ ពាក់ព័ន្ធនឹងការរិះគន់ និងការព្រួយបារម្ភអំពី ការឆ្លើយតបរបស់រដ្ឋាភិបាលនៃជំងឺ កូវីដ-១៩ សូម្បីតែក្នុងករណីដែលមិនមានផលប៉ះពាល់ដល់រាងកាយ ក៏ដោយក៏ត្រូវបានរិតត្បិតនៅលើ Facebook ដោយមិនត្រឹមត្រូវផងដែរ។ ទោះយ៉ាងណាក៏ដោយ វានៅតែមានបញ្ហាប្រឈមក្នុងការផ្ទៀងផ្ទាត់រឿងនេះឱ្យបានពេញលេញក្នុងករណីដែលគ្មានព័ត៌មានជាសាធារណៈ។

ICJ មានការព្រួយបារម្ភថា Facebook មិនបានអនុវត្តការត្រួតពិនិត្យឲ្យបានហ្មត់ចត់ ដើម្បីជៀសវាងការរំលោភលើសិទ្ធិសេរីភាពនៃការបញ្ចេញមតិទេ ដោយគ្រាន់តែរិតត្បិតលើខ្លឹមសារតាមបញ្ជាដោយអាជ្ញាធរតុលាការឯករាជ្យ និងមិនលំអៀង។[279] ដូចដែលបានកត់សម្គាល់ពីមុន *ប្រកាស* អន្តរក្រសួង អនុញ្ញាតឱ្យរដ្ឋាភិបាលជៀសវាង តុលាការ និងរិតត្បិតដោយផ្ទាល់នូវខ្លឹមសារដែលមិនពេញចិត្ត។ ប្រសិនបើ *ប្រកាស* អន្តរក្រសួងគឺជាមូលដ្ឋានច្បាប់ដែលរដ្ឋាភិបាលកម្ពុជាកំពុងទាមទារឱ្យមានការរិតត្បិតលើខ្លឹមសារនៅលើ Facebook នោះ Facebook រួមគំនិតអនុញ្ញាតឱ្យមានការត្រួតពិនិត្យនៅលើ អ៊ីនធឺណិតរបស់រដ្ឋាភិបាលកម្ពុជា ដោយអនុវត្តតាមការទាមទារទាំងនេះ ប្រកបដោយប្រសិទ្ធភាព។

ជាចុងក្រោយ គួរបញ្ជាក់ផងដែរថា Facebook ធ្លាប់បានចាត់តាំងក្រុមហ៊ុន ធុរកិច្ចសម្រាប់ការទទួលខុសត្រូវខាងសង្គម ដែលជាអង្គការមិនរកប្រាក់ចំណេញសកល ដើម្បីធ្វើការវាយតម្លៃផលប៉ះពាល់សិទ្ធិមនុស្សនៃប្រតិបត្តិការរបស់ Facebook នៅកម្ពុជាក្នុងខែធ្នូ ឆ្នាំ ២០១៩។[280]

---

[279] *IBID*., កថាខណ្ឌទី៦៦

[280] សេចក្ដីសង្ខេបប្រតិបត្តិនៃការវាយតម្លៃអាចរកបាននៅទីនេះ៖ BSR *ការវាយតម្លៃផលប៉ះពាល់សិទ្ធិមនុស្ស៖ ហ្វេសប៊ុកនៅកម្ពុជា* ខែធ្នូ ឆ្នាំ២០១៩ មាននៅ៖ https://about.fb.com/wp-content/uploads/2020/05/BSR-Facebook-Cambodia-HRIA_Executive-Summary2.pdf

យោងតាមការវាយតម្លៃមាន "ភ័ស្តុតាងតិចតួចនៃការលុបខ្លឹមសារចេញពី Facebook ដែលមិនគួរលុបចេញ"។[281] ដោយមិនគិតថាតើ ការវាយតម្លៃនេះត្រឹមត្រូវឬអត់នោះទេ វាហាក់បីដូចជាការសន្និដ្ឋាននេះមិនពិតទេនៅពេលប្រឈមមុខនឹង ការរាតត្បាតនៃជំងឺកូវីដ-១៩។

[281] ហ្វេសប៊ុក ការឆ្លើយតបរបស់ហ្វេសប៊ុក ៖ *ការវាយតម្លៃសិទ្ធិមនុស្សនៅកម្ពុជា* ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២០ ទំព័រទី ៣ មាននៅ៖ https://about.fb.com/wp-content/uploads/2021/03/FB-Response-Cambodia-HRIA.pdf

## VIII. អនុសាសន៍

កម្ពុជារក្សាច្បាប់ទាំងចាស់ និងថ្មីដែលមិនអនុលោមតាមច្បាប់ និងស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ និងជាពិសេសកាតព្វកិច្ចផ្លូវច្បាប់អន្តរជាតិរបស់ប្រទេសក្រោម ICCPR ។ រដ្ឋាភិបាលកម្ពុជាក៏កំពុងសម្លឹងមើលការអនុម័តច្បាប់ថ្មី ប្រសិនបើអនុវត្តនឹងបំពានកាតព្វកិច្ចសិទ្ធិមនុស្សរបស់ប្រទេសកម្ពុជា ហើយនឹងបន្តរិតត្បិតលំហាពលរដ្ឋតាមប្រពន្ធ័អ៊ីនធឺណិត។ ច្បាប់ទាំងនេះមិនអនុលោមតាមសិទ្ធិមនុស្សចំពោះសេចក្តីលើឯកសារច្បាប់ ហើយនៅក្នុងរបៀបដែលច្បាប់ទាំងនេះទំនងជាត្រូវអនុវត្តផងដែរ ច្បាប់ទាំងនេះ (i) មិនច្បាស់លាស់ និងទូលំទូលាយនៅក្នុងលក្ខខណ្ឌរបស់វា (ii) អនុញ្ញាតឱ្យមានការរិតត្បិតសម្រាប់គោលបំណងដែលមិនអាចអនុញ្ញាតបាន ឬ ប្រសិនបើគោលបំណងត្រូវបានអនុញ្ញាតអាចត្រូវបានអនុវត្តក្នុងលក្ខណៈដែលមិនចាំបាច់ចំពោះគោលបំណងនោះ (iii) កំណត់ទណ្ឌកម្មមិនសមាមាត្រ និងមិនចាំបាច់សម្រាប់ការមិនអនុលោមតាម និង (iv) ខ្វះការត្រួតពិនិត្យឯករាជ្យ រួមទាំងខាងប្រព័ន្ធតុលាការ។

កំហុសធ្ងន់ធ្ងរនៅក្នុងច្បាប់ទាំងនេះបានអនុញ្ញាតឱ្យពួកគេអនុវត្តកាន់តែខ្លាំងឡើងដើម្បីរារាំងការអនុវត្តសេរីភាពនៃការបញ្ចេញមតិ និង សេរីភាពជាមូលដ្ឋានផ្សេងទៀតរបស់ប្រជាជនតាមប្រពន្ធ័អ៊ីនធឺណិត ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះបានកើនឡើងកាន់តែខ្លាំងក្នុងការឆ្លើយតបទៅនឹងជំងឺរាតត្បាតកូវីដ-១៩ ។ ការព្រួយបារម្ភអំពីឯករាជ្យភាព និង ភាពមិនលំអៀងនៃប្រព័ន្ធតុលាការកម្ពុជា បានបង្ហាញឱ្យឃើញក្នុងទម្រង់នៃការកាត់ទោស និងការផ្តន្ទាទោស មិនសមហេតុផល និងមិនចាំបាច់ប្រឆាំងនឹងបុគ្គលដែលគ្រាន់តែអនុវត្តសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិតាមប្រពន្ធ័អ៊ីនធឺណិត។

តួនាទីរបស់ Facebook ក្នុងការអនុញ្ញាតឲ្យមានការត្រួតពិនិត្យលើប្រពន្ធ័អ៊ីនធឺណិតក៏តម្រូវឱ្យមានការត្រួតពិនិត្យបន្ថែមទៀតផងដែរ ។ អវត្តមាននៃព័ត៌មានជាសាធារណៈអំពីវិសាលភាពដែល Facebook បានទទួលការទាមទារឱ្យដកចេញពីរដ្ឋាភិបាល និងវិធីដែល Facebook បានឆ្លើយតប បង្ហាញថា មានការខ្វះតម្លាភាពក្នុងវិធីសាស្ត្រ របស់ Facebook ចំពោះការរិតត្បិតខ្លឹមសារ។

ដោយផ្អែកលើការព្រួយបារម្ភ និងបញ្ហាប្រឈមទាំងនេះ ICJ ផ្តល់អនុសាសន៍ដូចខាងក្រោម៖

<u>ជូនចំពោះ **សភាកម្ពុជា**៖</u>

- លុបចោល ឬកែប្រែ នូវបទប្បញ្ញត្តិផ្លូវច្បាប់ដែលដាក់ទោសឧក្រិដ្ឋ ឬរិតត្បិតសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ព័ត៌មាន សមាគម ការចូលរួមផ្នែកនយោបាយ និងសិទ្ធិផ្សេងទៀតទាំងក្នុងប្រព័ន្ធអ៊ីនធឺណិត និងក្រៅប្រព័ន្ធអ៊ីនធឺណិតរួមទាំងច្បាប់ភាពអាសន្ន ច្បាប់ការពារជំងឺកូវីដ-១៩ មាត្រា ៤២៥ ៤៣៧(ស្ទួន) ៤៥៣ ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីទូរគមនាគមន៍[282]

- បោះបង់ ឬ ធ្វើវិសោធនកម្មច្បាប់ពង្រាងដែលតាក់តែងឡើងដើម្បីដាក់ទោសឧក្រិដ្ឋឬរិតត្បិតហួសហេតុចំពោះសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ព័ត៌មាន សមាគម ការចូលរួមផ្នែកនយោបាយ និងសិទ្ធិផ្សេងទៀតទាំងក្នុងប្រព័ន្ធអ៊ីនធឺណិត និង ក្រៅប្រព័ន្ធអ៊ីនធឺណិតរួមទាំងសេចក្តីព្រាងច្បាប់ស្តីពីសណ្តាប់ធ្នាប់សាធារណៈ និងសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យា

- អនុម័តច្បាប់បន្ថែមទាក់ទងនឹងបទប្បញ្ញត្តិនៃការបញ្ចេញមតិ និងព័ត៌មានតាមអ៊ីនធឺណិត បង្កើតដំណើរការចូលរួមដើម្បី ទទួលបានមតិយោបល់ពីសាធារណជន រួមទាំងសង្គមស៊ីវិល អ្នកសិក្សា មេធាវី អ្នកជំនាញបច្ចេកវិទ្យា និងទីប្រឹក្សាគោលនយោបាយឯករាជ្យ ឬអ្នកជំនាញបច្ចេកទេសផ្សេងទៀត។[283]

<u>ជូនចំពោះស្ថាប័ននីតិប្រតិបត្តិនៃ**រដ្ឋាភិបាលកម្ពុជា** រួមទាំងក្រសួងព័ត៌មានផងដែរ៖</u>

- លុបចោល ឬធ្វើវិសោធនកម្មនូវបទបញ្ជា/បទប្បញ្ញត្តិដែលរិតត្បិតហួសហេតុចំពោះសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ព័ត៌មាន សមាគម ការចូលរួមផ្នែកនយោបាយ និងសិទ្ធិផ្សេងទៀតទាំងក្នុងប្រព័ន្ធអ៊ីនធឺណិត និងក្រៅប្រព័ន្ធ

---

[282] ឯកសារ UN A/HRC/38/35 កថាខណ្ឌទី៦៥

[283] *IBID*. កថាខណ្ឌទី៦៩

អ៊ីនធឺណិតរួមទាំងអនុក្រឹត្យNIGនិង*ប្រកាស*អន្តរក្រសួងផងដែរស្តីអំពីគេហទំព័រ

- បញ្ឈប់ការរិតត្បិត ឬការទប់ស្កាត់ខ្លឹមសារលើអ៊ីនធឺណិត លុះត្រាតែការសម្រេចចិត្តបិទត្រូវបានធ្វើឡើងបន្ទាប់ពីការវិភាគពេញលេញដែលអនុវត្តស្តង់ដារអន្តរជាតិនៃនីត្យានុកុលភាព គោលបំណងស្របច្បាប់ ភាពចាំបាច់ សមាមាត្រ និងការមិនរើសអើង ហើយត្រូវបានអនុញ្ញាត ដោយអនុលោមតាមបទបញ្ជាអំណាចតុលាការឯករាជ្យ និង មិនលំអៀង ស្របតាមដំណើរការត្រួតពិនិត្យត្រឹមត្រូវហ្មត់ចត់ជាមួយនឹងការធានាច្បាស់លាស់នៃសិទ្ធិប្តឹងឧទ្ធរណ៍[284]

- បដិសេធមិនទទួលយក និង អនុវត្តវិធានការដែលដាក់សម្ពាធហួសហេតុមិនត្រឹមត្រូវ ឬ ជំរុញឱ្យក្រុមហ៊ុនបច្ចេកវិទ្យាដកខ្លឹមសារអ៊ិនទ្បាញចេញដោយអ្នកប្រើប្រាស់កម្មវិធី ដែលស្មើនឹងការអនុវត្តសិទ្ធិរបស់អ្នកប្រើប្រាស់ស្របច្បាប់ចំពោះសេរីភាពនៃការបញ្ចេញមតិ និង ព័ត៌មានរួមទាំងតាមរយៈ *ប្រកាស* អន្តរក្រសួងផងដែរ[285]

- បញ្ឈប់ការសម្លុតបំភ័យ ឬការធ្វើទុក្ខបុកម្នេញលើបុគ្គលទាំងអស់ដោយគ្រាន់តែអនុវត្តសិទ្ធិរបស់ពួកគេក្នុងការបញ្ចេញមតិដោយសេរី ព័ត៌មាន និង ការជួបប្រជុំដោយសន្តិវិធីតាមប្រពន្ធ័អ៊ីនធឺណិត តាមរយៈ ការរំលោភបំពានច្បាប់ និង បទប្បញ្ញត្តិរដ្ឋបាល ដូចជាច្បាប់បង្ការជំងឺកូវីដ-១៩ និងមាត្រា ៤២៥ ៤៣៧ (ស្ទួន) ៤៥៣ ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌ

- ស្របតាមគោលការណ៍នៃតម្លាភាព ផ្សព្វផ្សាយជាសាធារណៈនូវរបាយការណ៍លម្អិតអំពីរាល់សំណើដែលទាក់ទងនឹងខ្លឹមសារពីអាជ្ញាធររដ្ឋដែលបានចេញឲ្យ

---

[284] *IBID* កថាខណ្ឌទី ៦៦

[285] *Ibid*

បុគ្គល ក្រុមហ៊ុនបច្ចេកវិទ្យា អន្តរការីអ៊ីនធឺណិត និងអ្នកផ្តល់សេវាអ៊ីនធឺណិត និងការធ្វើបច្ចុប្បន្នភាព ឬ ព័ត៌មានបន្ថែមលើសំណើពាក់ព័ន្ធ [286] ហើយ

- ធានា និង សម្របសម្រួលឱ្យមានសមភាពក្នុងការទទួលបានសំណងឱ្យបានគ្រប់គ្រាន់ មានប្រសិទ្ធភាព និង ឆាប់រហ័ស សម្រាប់បុគ្គលទាំងអស់ ដែលសិទ្ធិរបស់ពួកគេត្រូវបានប៉ះពាល់ដោយការសម្លុតបំភ័យ ឬ ធ្វើទុក្ខបុកម្នេញចំពោះការអនុវត្តសិទ្ធិមនុស្សនៅក្នុងប្រពន្ធ័អ៊ីនធឺណិត។

ជូនចំពោះ**តួអង្គក្នុងវិស័យយុត្តិធម៌** ៖

- ទម្លាក់ចោលការចោទប្រកាន់ទាំងអស់ ចេញដីកាមិនចោទប្រកាន់ និង បញ្ឈប់ការចោទប្រកាន់បន្ថែមទៀត ជាពិសេសនៅពេលចាប់ផ្តើមនៃបណ្តឹងនេះប្រឆាំងនឹងបុគ្គលណាម្នាក់ រួមទាំងអ្នកដែលមានឈ្មោះក្នុងរបាយការណ៍នេះប្រឈមមុខនឹងការកាត់ទោសពីបទរំលោភច្បាប់ដែលមិនអនុលោមតាមសិទ្ធិមនុស្សឬត្រូវបានអនុវត្តក្នុងលក្ខណៈមិនអនុលោមតាមសិទ្ធិមនុស្ស។ នេះរាប់បញ្ចូលទាំងច្បាប់ការពារជំងឺកូវីដ-១៩ និងមាត្រា៤២៥ ៤៣៧(ស្ទួន) ៤៥៣ ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌ។ ទាក់ទងនឹងករណីបុគ្គលដែលត្រូវបានចោទប្រកាន់ចំពោះបទល្មើសរៀបរាប់ខាងលើ ត្រូវបញ្ឈប់ការផ្តន្ទាទោសពួកគេ ហើយទាក់ទងនឹងបុគ្គលនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន បញ្ឈប់ការស៊ើបអង្កេតលើករណីរបស់ពួកគេ ។ ដោះលែងជនទាំងអស់ដែលត្រូវបានឃុំខ្លួនក្នុងការឃុំខ្លួនមុនការកាត់ទោសជាបន្ទាន់ ឬជាប់ពន្ធនាគារដោយសារការកាត់ទោសក្នុងករណីបែបនេះ។

ជូនចំពោះ **ក្រុមហ៊ុនបច្ចេកវិទ្យាក្នុងវិស័យទំនាក់ទំនង** ៖

- បញ្ជាក់ជាសាធារណៈនូវការប្តេជ្ញាចិត្តក្នុងការគោរព និងការពារសិទ្ធិមនុស្ស ហើយទាក់ទងនឹងការអនុវត្តស្តង់ដារសិទ្ធិមនុស្សអន្តរជាតិស្របតាមសន្ធិសញ្ញាសិទ្ធិមនុស្ស និងយុត្តិសាស្ត្ររបស់ពួកគេ និងការពណ៌នានៃគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និង សិទ្ធិមនុស្ស ហើយនិង

[286] *IBID* ., កថាខណ្ឌទី ៦៩

គោលការណ៍ណែនាំសិទ្ធិមនុស្សជាក់លាក់ក្នុងឧស្សាហកម្មដទៃទៀតដែល ត្រូវបានបង្កើតឡើងដោយសង្គមស៊ីវិល ដូចជាគំនិតផ្តួចផ្តើមបណ្តាញសកល[287]

- អនុម័ត និងអនុវត្តយន្តការការពារប្រកបដោយប្រសិទ្ធភាព ដើម្បីត្រួតពិនិត្យនិង ធានាថាផលិតផល និងសេវាកម្មរបស់ពួកគេអនុលោមតាមច្បាប់ និងស្តង់ដារ សិទ្ធិមនុស្សអន្តរជាតិ រួមទាំងប្រយោគនៃកិច្ចសន្យាដែលហាមឃាត់ការប្តូរតាម បំណង ការកំណត់គោលដៅ សេវាកម្ម ឬការប្រើប្រាស់យន្តការផ្សេងទៀត ដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិមនុស្ស ដោយរួមបញ្ចូល នូវការរចនាលក្ខណៈ ពិសេសដើម្បីកំណត់ទប់ស្កាត់ ឬ កាត់បន្ថយការប្រើប្រាស់ខុស និងដំណើរ ការសវនកម្មសិទ្ធិមនុស្ស និង[288]

- បោះពុម្ពនិងផ្សព្វផ្សាយរបាយការណ៍លម្អិតអំពីតម្លាភាពលើរាល់សំណើទាក់ទង នឹងខ្លឹមសារដែលចេញដោយអាជ្ញាធរកម្ពុជារួមទាំងរបាយការណ៍លម្អិត ស្តីពីសំណើលុបខ្លឹមសារ និងវិធានការរបស់ក្រុមហ៊ុនក្នុងការឆ្លើយតប។[289]

---

[287] ឯកសារ UN A/HRC/38/35 កថាខណ្ឌទី៧០

[288] *អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីការលើកកម្ពស់ និងការពារសិទ្ធិសេរីភាពនៃគំនិត និងការបញ្ចេញមតិ* ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៩ ឯកសារ UN. A/HRC/41/35 កថាខណ្ឌទី ៦៦ ដល់ ៦៩

[289] *អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីការលើកកម្ពស់ និងការពារសិទ្ធិសេរីភាពនៃគំនិត និងការបញ្ចេញមតិ* ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៦ ឯកសារ UN A/HRC/32/38 កថាខណ្ឌទី ៨៧ ដល់ ៩០

**Commission Members**
October 2020 (for an updated list, please visit www.icj.org/commission)

**President:**
Prof. Robert Goldman, United States
Vice-Presidents:
Prof. Carlos Ayala, Venezuela
Justice Radmila Dragicevic-Dicic, Serbia

**Executive Committee:**
Justice Sir Nicolas Bratza, UK
Dame Silvia Cartwright, New Zealand
(Chair) Ms Roberta Clarke, Barbados-Canada
Mr. Shawan Jabarin, Palestine
Ms Hina Jilani, Pakistan
Justice Sanji Monageng, Botswana
Mr Belisário dos Santos Júnior, Brazil

**Other Commission Members:**
Professor Kyong-Wahn Ahn, Republic of Korea
Justice Chinara Aidarbekova, Kyrgyzstan
Justice Adolfo Azcuna, Philippines
Ms Hadeel Abdel Aziz, Jordan
Mr Reed Brody, United States
Justice Azhar Cachalia, South Africa
Prof. Miguel Carbonell, Mexico
Justice Moses Chinhengo, Zimbabwe
Prof. Sarah Cleveland, United States
Justice Martine Comte, France
Mr Marzen Darwish, Syria
Mr Gamal Eid, Egypt
Mr Roberto Garretón, Chile
Ms Nahla Haidar El Addal, Lebanon
Prof. Michelo Hansungule, Zambia
Ms Gulnora Ishankanova, Uzbekistan
Ms Imrana Jalal, Fiji
Justice Kalthoum Kennou, Tunisia
Ms Jamesina Essie L. King, Sierra Leone
Prof. César Landa, Peru
Justice Qinisile Mabuza, Swaziland
Justice José Antonio Martín Pallín, Spain
Prof. Juan Méndez, Argentina
Justice Charles Mkandawire, Malawi
Justice Yvonne Mokgoro, South Africa
Justice Tamara Morschakova, Russia
Justice Willly Mutunga, Kenya
Justice Egbert Myjer, Netherlands
Justice John Lawrence O'Meally, Australia
Ms Mikiko Otani, Japan
Justice Fatsah Ouguergouz, Algeria
Dr Jarna Petman, Finland
Prof. Mónica Pinto, Argentina
Prof. Victor Rodriguez Rescia, Costa Rica
Mr Alejandro Salinas Rivera, Chile
Mr Michael Sfard, Israel
Prof. Marco Sassoli, Italy-Switzerland
Justice Ajit Prakash Shah, India
Justice Kalyan Shrestha, Nepal
Ms Ambiga Sreenevasan, Malaysia
Justice Marwan Tashani, Libya
Mr Wilder Tayler, Uruguay
Justice Philippe Texier, France
Justice Lillian Tibatemwa-Ekirikubinza, Uganda
Justice Stefan Trechsel, Switzerland
Prof. Rodrigo Uprimny Yepes, Colombia

International
Commission
of Jurists

P.O. Box 1740
Rue des Buis 3
CH 1211 Geneva 1
Switzerland

**t:** +41 22 979 38 00
**f:** +41 22 979 38 01
www.icj.org